

# មិលិន្ទបញ្ហា ទៀ ២

# មិលិន្ទបញ្ហា

ព្រះឧត្តមមុនី អ៊ុម - ស៊ូរ

អធិបតីរង ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែនិងរៀបរៀង

ខ្សែ ២

កុង្សីសេនាបតីបានអនុញ្ញាតហើយ

សម្តេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

| កន្លែងនេះ រូបត្រា |
|---|

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៧៧

គ.ស. ១៩៣៤

Websites: WatKhemaraRatanaram.org  or  WatKhmers.org

# MILINDAPAÑHĀ

**TRADUIT DU PĀLI EN CAMBODGIEN**

**PAR**

**PRÉAS UTTAMA MUNĪ OUM-SOU**
**VICE-PRÉSIDENT DE LA COMMISSION DU TRIPITAKA**

**VOL. II**

**CETTE PUBLICATION A RECÇU L'APPROBATION DU CONSEIL DES MINISTRES ET DES DEUX CHEFS DE SECTE**

កន្លែងនេះរូបត្រា

**PHNOM-PENH**
**EDITIONS DE LA BIBLIOTHEQUE ROYALE**
**-**
**1934**

Websites: WatKhemaraRatanaram.org or WatKhmers.org

# មាតិការឿង

ទំព័រ


## តតិយវគ្គ (ត)

វិញ្ញាណលក្ខណបញ្ហា ៗ ទី១២ ០០៥

វិតក្កលក្ខណបញ្ហា ៗ ទី១៣ ០០៦

វិចារលក្ខណបញ្ហា ៗ ទី១៤ ០០៧

## ចតុត្ថវគ្គ មានប្រស្នា ១០ ប្រការ

មនសិការបញ្ហា ៗ ទី១ ០០៨

ឯកភាវគតបញ្ហា ៗ ទី២ ០០៩

បញ្ចាយតនកម្មនិព្វត្តបញ្ហា ៗ ទី៣ ០១៦

កម្មនានាករណបញ្ហា ៗ ទី៤ ០១៧

បដិកច្ចេវវាយាមករណបញ្ហា ៗ ទី៥ ០២៥

បកតិអគ្គិតោនេរយគ្គិសំឧណ្ហាការបញ្ហា ៗ ទី៦ ០៣៣

បឋវីសណ្ឋារកបញ្ហា ៗ ទី៧ ០៤១

និរោធនិព្វានបញ្ហា ៗ ទី៨ ០៤២

និព្វានលភនបញ្ហា ៗ ទី៩ ០៤៤

និព្វានសុខភាវជាននបញ្ហា ៗ ទី១០ ០៤៥

## បញ្ចមវគ្គ មានប្រស្នា ១០ ប្រការ

ពុទ្ធអត្ថិនត្ថិភាវបញ្ហា ៗ ទី១ ០៤៧

ពុទ្ធានុត្តរភាវបញ្ហា ៗ ទី២ ០៥០

ពុទ្ធានុត្តរភាវជាននបញ្ហា ៗ ទី ៣ ០៥២

ធម្មទិដ្ឋិបញ្ហា ៗ ទី៤ ០៥៤


Websites: WatKhemaraRatanaram.org or WatKhmers.org

| | |
|---|---|
| នបសង្កមតិបដិសន្ធិគហណបញ្ហា ៗ ទី៥ | ០៥៥ |
| វេទគូបញ្ហា ៗ ទី៦ | ០៥៩ |
| ធម្មាកាយាអញ្ញំកាយំសំកមបញ្ហា ៗ ទី៧ | ០៥៩ |
| កម្មផលអត្ថិភាវបញ្ហា ៗ ទី៨ | ០៦២ |
| ឧប្បជ្ជដាននបញ្ហា ៗ ទី៨៩ | ០៦៥ |
| ពុទ្ធនិទស្សនបញ្ហា ៗ ទី១០ | ០៦៦ |


## ឆដ្ឋមវគ្គ មានប្រស្នា ១១


| | |
|---|---|
| កាយអប្បិយបញ្ហា ៗ ទី១ | ០៦៨ |
| សម្បត្តកាលបញ្ហា ៗ ទី២ | ០៧៣ |
| ទ្វត្តឹសមហាបុរិសលក្ខណបញ្ហា ៗ ទី៣ | ០៧៥ |
| ព្រហ្មចារិបញ្ហា ៗ ទី៤ | ០៧៩ |
| ឧបសម្បន្នបញ្ហា ៗ ទី៥ | ០៨២ |
| អស្សុបញ្ហា ៗ ទី៦ | ០៩៤ |
| រសបដិសំវេទិបញ្ហា ៗ ទី៧ | ០៩៦ |
| បញ្ញាយបដិដ្ឋានបញ្ហា ៗ ទី៨ | ០៩៩ |
| សំសារបញ្ហា ៗ ទី៩ | ១០០ |
| ចិរកតសរណបញ្ហា ៗ ទី១០ | ១០២ |
| សតិអភិជាននបញ្ហា ៗ ទី១១ | ១០៤ |


## សត្តមវគ្គ មានប្រស្នា ១៩


| | |
|---|---|
| សតិអាការបញ្ហា ៗ ទី១ | ១០៦ |
| វិស្សសតបញ្ហា ៗ ទី២ | ១១៨ |
| អនាគតបញ្ហា ៗ ទី៣ | ១២៣ |

| | |
|---|---|
| ទូរព្រហ្មលោកបញ្ហា ៗ ទី៤ | ១៣៣ |
| ព្រហ្មលោកកស្មិរនគរបញ្ហា ៗ ទី៥ | ១៣៥ |
| បរលោកគតនីលបីតាទិវណ្ណគតបញ្ហា ៗ ទី៦ | ១៤១ |
| មាតុកុច្ឆិបដិសន្ធិបញ្ហា ៗ ទី៧ | ១៤៦ |
| សត្វពោជ្ឈង្គបញ្ហា ៗ ទី៨ | ១៤៨ |
| បាបបុញ្ញពហុតរបញ្ហា ៗ ទី៩ | ១៦១ |
| ជាននអជាននបញ្ហា ៗ ទី១០ | ១៦៤ |
| ឧត្តរកុរុបញ្ហា ៗ ទី១១ | ១៦៦ |
| ទីឃអដ្ឋិកបញ្ហា ៗ ទី១២ | ១៦៨ |
| អស្សាសបស្សាសបញ្ហា ៗ ទី១៣ | ១៧០ |
| សមុទ្ទបញ្ហា ៗ ទី១៤ | ១៧២ |
| សុខុមឆេទនបញ្ហា ៗ ទី១៥ | ១៧៣ |
| បញ្ញាវិសេសបញ្ហា ៗ ទី១៦ | ១៧៤ |
| បញ្ញាទីនំនានត្តភាវបញ្ហា ៗ ទី១៧ | ១៧៥ |
| អរូបវវត្តភាវទុក្ករបញ្ហា ៗ ទី១៨ | ១៧៨ |
| ទុក្ករបញ្ហា ៗ ទី១៩ | ១៨១ |
| វិសេសបញ្ហា ឬ គោតមីវត្តទានបញ្ហា | ១៩០ |


Websites: WatKhemaraRatanaram.org or WatKhmers.org

# វិញ្ញាណលក្ខណបញ្ហា ៗ ទី ១២

ព្រះមហាក្សត្រ ស្តេចទ្រង់សួរទៅព្រះនាគសេនថេរថា បពិត្រលោកម្ចាស់ដ៏ចំរើន វិញ្ញាណដែលនឹងកើតឡើងនោះមានលក្ខណៈដូចម្តេចជាទីសម្គាល់លោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រមហារាជ វិញ្ញាណដែលនឹងកើតឡើងនោះ មានកិរិយាដឹងផ្សេង ៗ ជាលក្ខណៈជាទីសម្គាល់ សូមទ្រង់ជ្រាប ។

**ម.** សូមលោកម្ចាស់ ឧបមាបន្តិចមកមើល ។

**ន.** បពិត្រមហារាជ សេចក្តីនេះប្រៀបដូចជារាជបុរសជាអ្នករក្សានូវព្រះនគរ រាជបុរសនោះទៅអង្គុយឬឈរ នៅត្រង់ទីប្រជុំផ្លូវទាំង ៤ ទិស ក៏តែងបានឃើញ នូវមនុស្សម្នាមហាជនទាំងពួងដែលដើរមកអំពីទិស ខាងកើត, ខាងលិច, ខាងជើង, ខាងត្បូង គ្រប់ទាំង ៤ ទិសមិនខាន យ៉ាងណាមិញ បពិត្រមហារាជ សេចក្តីនេះប្រៀបដូចជាបុគ្គល ដែលឃើញនូវរូបដោយចក្ខុវិញ្ញាណ ឮនូវសំឡេងដោយសោតវិញ្ញាណ ធុំនូវក្លិនដោយ

ឃានវិញ្ញាណ ភ្លក់នូវរសដោយជិវ្ហាវិញ្ញាណ ពាល់នូវសម្ផស្ស ដោយកាយវិញ្ញាណ ដឹងនូវធម៌ដោយមនោវិញ្ញាណ យ៉ាងនេះឯង បពិត្រមហារាជ ឯវិញ្ញាណដែលមានលក្ខណៈដឹងផ្សេង ៗ នោះ ដូចសេចក្តីដែលពណ៌នាមកនេះ សូមមហាបពិត្រជ្រាប ។

**ម.** បួលបិត្តស្តាប់បានហើយ លោកម្ចាស់ ។

## វិតក្កលក្ខណបញ្ហា ៗ ទី ១៣

ព្រះមហាក្សត្រស្តេចទ្រង់សួរទៅព្រះនាគសេនថេរ ក្នុងវិតក្កបញ្ហានេះថា បពិត្រព្រះថេរដ៏ចម្រើន វិតក្កចេតសិកនោះ វេលាដែលនឹងកើតឡើងនោះ តើមានលក្ខណៈដូចម្តេច។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រមហារាជ វិតក្កចេតសិកនោះ វេលាដែលនឹងកើតឡើងនោះ មានកិរិយាអែបផ្ចិតនូវអារម្មណ៍ ឬតនូវអារម្មណ៍ជាលក្ខណៈ សូមទ្រង់ជ្រាប ។

**ម.** សូមលោកម្ចាស់ប្រៀបឧបមាបដិបមកមើល ។

**ន.** បពិត្រមហារាជ សេចក្តីនេះឧបមាដូចជាងឈើដែល

តឈើ ធម្មតាជាងឈើដែលនឹងភ្ជាប់ឈើតគ្នានោះ តែងធ្វើមុខដំណនោះឱ្យជិតស្និទ្ធល្អ យ៉ាងណាមិញ ឯវិតក្កចេតសិកនោះ ក៏តែងនឹងតភ្ជាប់នូវអារម្មណ៍ យ៉ាងនេះឯងជាលក្ខណៈ សូមមហាបពិត្រជ្រាប ។

**ម.** បួលបិត្តស្តាប់បាទហើយលោកម្ចាស់ ។

## វិចារលក្ខណបញ្ហា ទី ១៤

ព្រះបាទមិលិន្ទ ស្តេចទ្រង់សួរព្រះនាគសេនថេរ ក្នុងវិចារលក្ខណបញ្ហាទី ១៤ នេះតទៅទៀតថា បពិត្រព្រះនាគសេនម្ចាស់ ចុះវិចារចេតសិកនោះ តើមានលក្ខណៈយ៉ាងណាលោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ ឯវិចារចេតសិកនេះ វេលាដែលនឹងកើតនោះ មានកិរិយាបោសអង្អែល ឬមានកិរិយាត្រេចទៅតាមវិតក្កចេតសិកជាលក្ខណៈ សូមទ្រង់ជ្រាប ។

**ម.** សូមលោកម្ចាស់ប្រៀបឧបមាជាសេចក្តីបន្តិចមកមើល

ឥ. បពិត្រមហារាជ សេចក្ដីនេះប្រៀបដូចផ្ទៃនៃរគាំងដែល បុគ្គលយកដាវមកគោះហើយលាន់ឮជាសំឡេងតទៅ ឯត្រង់កន្លែងដែលគោះនោះ ប្រៀបដូចវិតក្កចេតសិក ត្រង់សំឡេងដែលលាន់ឮតទៅនោះ ប្រៀបដូចវិចារចេតសិក ៗ នេះតែងប្រព្រឹត្តទៅតាមវិតក្កចេតសិកជាធម្មតា ដូចជាសំឡេងដែលតែងប្រព្រឹត្តទៅឬកើតឡើង អំពីកិរិយាគោះនោះឯង សូមមហាបពិត្រជ្រាប ។

ម. ព្រះថេរម្ចាស់ឆ្លៀវឆ្លាសពេកណាស់ បេះប្រៀបឧបមាជាការងាយទូលាយគំនិតនឹងគិតតាមបាន ។

**បប់តតិយវគ្គ**

## ចតុត្ថវគ្គ មានប្រស្នា ១០ ប្រការ

## មនសិការបញ្ហា ។ ទី ១

ព្រះបាទមិលិន្ទ្រាធិរាជបរមក្សត្រ ស្ដេចទ្រង់ប្រារព្ធសួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី១ ក្នុងវគ្គទី៤នេះថា បពិត្រព្រះថេរដ៏ចំរើនមនសិការចេតសិកវេលាដែលនឹងកើតឡើងនោះតើមានបែបយ៉ាងដូចម្ដេច សម្រាប់សំគាល់ជាលក្ខណៈលោកម្ចាស់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រមហារាជ ឯមនសិការចេតសិក វេលាដែលនឹងកើតឡើងនោះ តែងក្រសាវរកនូវអារម្មណ៍ ឬនឹករកនូវអារម្មណ៍ជាលក្ខណៈជាបែបយ៉ាងសូមមហារាជស្ដេចជ្រាប ។

**ម.** លោកម្ចាស់ឆ្លាសមែន, ខ្ញុំប្អូលបិត្តហើយ ។

## ឯកភាវគតបញ្ហា ។ ទី ២

ព្រះមហាក្សត្រស្ដេចទ្រង់បុច្ឆា ចំពោះទៅព្រះនាគសេនថេរក្នុងប្រស្នាទី ២ តទៅទៀតថា បពិត្រព្រះនាគសេនដ៏ចម្រើនក៏ធម៌ទាំងឡាយមានផស្សជាដើមនេះឈ្មោះថាសហជាតធម៌ គឺថាជាធម៌តែងកើតព្រមគ្នា មិនមុនមិនក្រោយ ចុះបំណែកលោកម្ចាស់នឹងអាចបែកនូវធម៌ទាំងឡាយ ដែលមានកិរិយាកើតក្នុងទីជាមួយគ្នានេះ បញ្ញត្តឱ្យជាធម៌ផ្សេង ៗ គ្នាថា សភាវនេះជាផស្ស, ធម្មជាតិនេះជាវេទនា, ធម្មជាតិនេះជាសញ្ញា, ធម្មជាតិនេះជាចេតនា, ធម្មជាតិនេះជាវិញ្ញាណ, សភាវនេះជាវិតក្ក, សភាវនេះជាវិចារ ដូច្នេះទៅបានឬមិនបានទេលោកម្ចាស់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រសម្តេចមហា-រាជ ឯសភាវធម៌ទាំងឡាយនេះ អាត្មាភាពមិនអាចនឹងញែកបែកហើយធ្វើកំណត់ឱ្យផ្សេងៗគ្នាថា សភាវនេះជាផស្ស, ធម្មជាតិនេះជាវេទនា, ធម្មជាតិនេះជាសញ្ញា, ធម្មជាតិនេះជាចេតនា, ធម្មជាតិនេះជាវិញ្ញាណ, សភាវនេះជាវិតក្ក, សភាវៈនេះជាវិចារ ដូច្នេះនោះបានឡើយ ។

**ម. ឧបមំ ករោហិ** សូមលោកម្ចាស់ធ្វើនូវសេចក្តីឧបមាបន្តិចមក នឹងស្តាប់មើលលោកម្ចាស់ ។

**ឥ. យថា មហារាជ** បពិត្រសម្តេចមហារាជសេចក្តីនេះប្រៀបដូចអ្នកគ្រួឬពួកវិសេសរបស់មហាក្សត្រាធិរាជ ដែលជាអ្នកធ្វើនូវក្រយាព្រះស្ងោយថ្វាយ កាលដែលនឹងស្លឬ ញាំ, ធានោះ គេតែងបង់នូវគ្រឿងផ្សេងៗ ប្រទ្បាំគ្នា មានដាក់ទឹកដោះជូរ អំបិល, ខ្ញី, ជីរ និងម្ទេសជាដើម ហើយនិងវត្ថុដទៃ ៗ ដែលជារបស់វិសេសនោះ ទៅក្នុងឆ្នាំងសម្លឬធានោះ លុះរួបស្រេចហើយទើបលើកចូលទៅថ្វាយ ព្រះមហាក្សត្រ ចំណែកមហា-

ក្សត្រសោត ស្តេចនឹងបង្គាប់ទៅពួកវិសេសនោះថា អ្នកទាំងឡាយ ចូរអ្នកនាំមកនូវរសនៃទឹកដោះជូរក្នុងទឹកសម្លនោះមកឱ្យយើង ហើយនាំនូវរសនៃទឹកអំបិល, និងរសនៃខ្ទិ, និងរសនៃជីរ, និងរសនៃម្ទេស ដែលជារបស់ឆ្ងាញ់ ៗ ដែលអ្នកទាំងឡាយបង់ចុះហើយ ក្នុងឆ្នាំងសម្លនោះមកឱ្យយើង បពិត្រមហារាជ បើមហាក្សត្រស្តេចបង្គាប់យ៉ាងហ្នឹងហើយ ចុះបំណែកខាងពួកវិសេស នឹងអាចបាត់បែងបែកនូវរសនៃវត្ថុទាំងឡាយដែលប្រឡូកប្រឡំគ្នាក្នុងឆ្នាំងសម្លនោះ ហើយនឹងនាំយកនូវរសជូរ, ឬរសប្រៃ, រសល្វីង, រសហិរ, រសចត់និងរសផ្អែមជាដើម មកថ្វាយមហាក្សត្របានឬទេ មហាបពិត្រ ។

**ម. ន ហិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន ពួកវិសេសទាំងនោះ មិនអាចនឹងបែកញែកនូវរសជូរ និងរសប្រៃជាដើមដែលខ្ញុំនបង់ចុះជាមួយគ្នាក្នុងទឹកសម្ល នឹងនាំយកមកថ្វាយមហាក្សត្រនោះបានឡើយ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រសម្តេចមហារាជ ក៏ពួកអ្នក

គ្រូ ឬពួកវិសេសដែលមិនអាចនឹងញែកបែក នូវរសនៃទឹកសម្ល ដែលជ្រាបចេញពីវត្ថុទាំងឡាយ មានអំបិល និងអម្ពិលជាដើម ដែលខ្លួនបង់ចុះក្នុងឆ្នាំងសម្លនោះយ៉ាងណា, អាត្មាភាពនេះក៏មិនអាចនឹងញែកបែក នូវធម៌ទាំងឡាយមានផស្សជាដើម ដែលកើតព្រមគ្នា ហើយធ្វើឱ្យផ្សេងគ្នាថា នេះផស្ស, នេះវេទនា, នេះសញ្ញា, នេះចេតនា, នេះវិញ្ញាណ, នេះវិតក្ក, នេះវិចារ នោះបានឡើយ យ៉ាងនោះឯងសូមថ្វាយព្រះពរ ។ លំដាប់ពីនោះទៅទើបព្រះថេរថ្វាយព្រះពរសួរទៀមហាក្សត្រថា បពិត្រព្រះរាជសម្ភារ បុះអំបិលដែលគេត្រូវដឹងនោះ តើត្រូវដឹងដោយចក្ខុឬអ្វីមហាបពិត្រ ។

**ម.** ករុណាលោកម្ចាស់ អំបិលនោះគេត្រូវដឹងដោយចក្ខុយ៉ាងហ្នឹងហើយ ។

**ន. សុដ្ឋុ ខោ មហារាជ** បពិត្រសម្តេចមហារាជ ព្រះរាជឱង្ការដែលទ្រង់ត្រាស់ថា កិច្ចដែលគេដឹងរសអំបិលនោះ គឺដឹងដោយចក្ខុវិញ្ញាណ ព្រះតម្រាស់នេះ សូមទ្រង់ត្រាស់ឱ្យប្រាកដដោយល្អ កុំប្រែប្រួល ។

**ម. កឹ ភន្តេ** បពិត្រព្រះថេរដ៏ចំរើន ចុះលោកម្ចាស់សម្គាល់ថាគេដឹងដោយអ្វី ថាគេដឹងដោយជិវ្ហាឬអ្វី ។

**ន. អាម មហារាជ** បពិត្រមហារាជ អាត្មាភាពចូលចិត្តថាគេដឹងនូវអំបិលនោះ គឺដឹងដោយជិវ្ហាវិញ្ញាណជាប្រាកដ សូមមហាបពិត្រជ្រាប ។

**ម. កឹ បន ភន្តេ** បពិត្រព្រះនាគសេនថេរដ៏បម្រើន ចុះលោកម្ចាស់សម្គាល់ថា បុគ្គលដែលដឹងនូវអំបិលទាំងអស់នោះ គឺដឹងដោយជិវ្ហាឬអ្វី ។

**ន. អាម មហារាជ** បពិត្រមហារាជ អាត្មាភាពសម្គាល់ថាបុគ្គលដែលដឹងនូវអំបិលទាំងអស់នោះ គឺដឹងដោយជិវ្ហា តែម្យ៉ាងប៉ុណ្ណោះសូមទ្រង់ជ្រាប ។

**ម.** បើលោកម្ចាស់ថា គេដឹងដោយជិវ្ហា ចុះប្រសិនបើគេយករទេះទៅផ្ទុកអំបិលពេញក្នុងរទេះហើយ គេដឹកនាំមកកាន់ទីចំពោះមុខ បើត្រូវការបង់ដឹងនូវអំបិលនោះ តើយើងត្រូវធ្វើដូចម្ដេច គឺគ្រាន់តែមើលដោយភ្នែកទៅដឹង ឬ ៗ បាំយកជិវ្ហា

ទៅលិទ្ធភ្លក់មើល ទើបដឹងលោកម្ចាស់ ។ ម្យ៉ាងទៀតអំបិលក្នុងរទេះដែលគេតែងនាំមកដោយគោមានកម្លាំង ចុះបំណែកជិវ្ហានឹងអាចនាំមកនូវអំបិលទាំងរទេះបាន ឬពុំបានទេលោកម្ចាស់ ។

**ន.** បពិត្រមហារាជ ឯជិវ្ហានេះមិនអាចដឹកនាំមកនូវអំបិលទាំងរទេះនោះបានឡើយ ព្រោះអំបិលនោះធ្ងន់ហួសកម្លាំងនៃអណ្តាត សេចក្តីនេះដូចគ្នានឹងសហជាតធម៌ទាំងឡាយ មានផស្សជាដើម ដែលជាធម៌តែងកើតឡើងព្រមគ្នា ឬតែងកើតក្នុងទីជាមួយគ្នា តែងមានអារម្មណ៍ផ្សេង ៗ គ្នា ដែលអាត្មាភាពបានថ្វាយព្រះពរហើយថា បញ្ញាអាត្មាភាព មិនអាចនឹងញែកបែកនូវធម៌ទាំងនោះ ឱ្យប្លែកគ្នាបានទេ ម្យ៉ាងទៀត អាត្មាភាពសូមថ្វាយព្រះពរសួរមហាបពិត្រវិញថា ចុះអំបិលទាំងរទេះនោះ បុគ្គលនឹងអាចថ្លឹងដោយជញ្ជីង បានឬពុំបានទេ មហាបពិត្រ ។

**ម.** អំបិលក្នុងរទេះនោះ បុគ្គលនឹងអាចថ្លឹងដោយជញ្ជីងបាន លោកម្ចាស់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ត.** បុះមហារាជស្ដេចជ្រាបថា ប្រាកដជាថ្លឹងដោយជញ្ជីងបានយ៉ាងហ្នឹងឬអ្វី ។

**ម.** បុះលោកម្ចាស់យល់ដូចម្ដេច ថាមិនអាចថ្លឹងបានឬអ្វី។

**ត.** ថ្វាយព្រះពរ អាត្មាភាពថាមិនអាចនឹងថ្លឹងដោយជញ្ជីងបាន ព្រោះអំបិលទាំងរទេះនោះមានការធ្ងន់ដោយច្រើនឯការ ដែលនឹងថ្លឹងនូវរបស់ទាំងពួងនោះ គួរដល់កម្លាំងជញ្ជីងទើបនឹងថ្លឹងបាន បើវត្ថុនោះធ្ងន់ពេកហួសកម្លាំង ក៏មិនអាចនឹងថ្លឹងបានឡើយ មិនមែនជាកិច្ចការត្រូវប្រកបទេ ប្រៀបដូចជាជិវ្ហាដែលមិនអាចនឹងដឹកនាំមក នូវអំបិលទាំងរទេះនោះឯងសេចក្ដីនេះគួរនាយ៉ាងណាមិញ ថាព្រះរាជឱង្ការដែលត្រាស់ឱ្យអាត្មាភាពញែកបែកនូវសហជាតធម៌ទាំងឡាយ មានផស្សជាដើម ដែលជាធម៌តែងកើតឡើងព្រមគ្នានោះ ឱ្យផ្សេងចេញពីគ្នា ឬប្លែកចេញពីគ្នានោះពុំបានទេ ដូចគ្នានឹងអំបិលដែលបុគ្គលផ្ទុកបុះក្នុងរទេះ ហើយឱ្យអណ្ដាតទៅដឹកនាំមកទាំងរទេះពុំបាននោះ សូមថ្វាយព្រះពរ ។

**ម. កល្លោសិ ព្រះថេរនេះ** លោកឆ្លាសពេកណាស់ បេះដោះសាគួរឱ្យចូលចិត្តបាន ។

## បញ្ហាយតនកម្មនិព្វត្តបញ្ហា ។ ទី ៣

ព្រះមហាក្សត្រស្ដេចទ្រង់បុច្ឆាចំពោះទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៣ ក្នុងវគ្គទី ៤ នេះថា បពិត្រព្រះថេរដ៏ចំរើន ខ្ញុំមានសេចក្ដីសង្ស័យត្រង់អាយតនៈទាំង ៥ ប្រការ គឺកន្លែងដែលជាទីកើតនៃវិញ្ញាណទាំង៥នោះ អាយតនៈទាំង៥ ប្រការនេះ វេលាដែលនឹងកើតឡើងនោះជានឹងកើតឡើងដោយកម្មផ្សេង ៗ គ្នាឬៗនឹងកើតឡើងដោយកម្មតែម្យ៉ាងជាមួយគ្នាទេ លោកម្ចាស់។

ព្រះនាគសេនថេរ ថ្វាយព្រះពរទៅវិញថា បពិត្រសម្ដេចមហារាជ ឯអាយតនៈទាំង ៥ ប្រការ នឹងបានកើតដោយកម្មផ្សេងៗ គ្នាក៏ទេ គឺកើតឡើងដោយកម្មតែម្យ៉ាងជាមួយគ្នា សូមទ្រង់ជ្រាប។

**ម. ឧបមំ ករោហិ** សូមលោកម្ចាស់ឧបមាបន្តិចមកនឹងស្ដាប់មើល ។

**ន. ឯកស្មឹ ខេត្ត** បពិត្រព្រះរាជសម្ភារ សេចក្ដីនេះប្រៀបដូចពូជស្រូវទាំង ៥ យ៉ាងដែលបុគ្គលព្រាបព្រួសបណ្ដុះទៅក្នុងស្រែតែ ១ ហើយពូជទាំងនោះក៏ដុះដាលឡើង អំពីស្រែជាមួយគ្នា វេលាដល់បេញជាផ្លែ ក៏ផ្លែផ្សេង ៗ គ្នា សេចក្ដីនេះគួរនាយ៉ាងណាមិញ បពិត្រមហារាជ ឋាគួរនាដូបអាយ-តនៈ ទាំងឡាយ ៥ ប្រការ ក៏អាយតនៈទាំង ៥ នេះនឹងបានកើតដោយកម្មផ្សេង ៗ គ្នានោះក៏ទេ គឺកើតដោយកម្មតែម្យ៉ាង ជាមួយគ្នាដូចពូជស្រូវទាំង៥ ដែលកើតក្នុងស្រែតែ១ នោះឯង សូមទ្រង់ជ្រាប ។

**ម.** ខ្ញុំចូលបិត្តស្ដាប់បានហើយលោកម្ចាស់ អស់សង្ស័យក្នុងបិត្តហើយ ។

## កម្មនានាករណបញ្ហា ។ ទី ៤

ព្រះបរមក្សត្រាធិរាជ ស្ដេចទ្រង់ព្រះរាជបុច្ឆាចំពោះទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៤ ក្នុងវគ្គទី ៤ នេះតទៅទៀតថា បពិត្រព្រះថេរដ៏ចំរើន ខ្ញុំមានសេចក្ដីងឿងឆ្ងល់គិតមិនយល់មិន

ចូលចិត្តសោះ អំពីមនុស្សយើងសព្វថ្ងៃនេះ មិនដឹងជាហេតុអ្វី ធម្មជាតិដូចម្តេចធ្វើមនុស្សសត្វទាំងពួង ដែលកើតមកក្នុងលោកនេះ មិនឱ្យដូចគ្នា ស្មើគ្នាបាន ក៏បេះតែឱ្យផ្សេង ៗ គ្នា, ប្លែកគ្នាទីទៃ ៗ ទៅដូចសេចក្តីខាងក្រោមនេះ

"មានមនុស្សប្រុសស្រីបំពូកខ្លះ មានអាយុតិច ឬអាយុខ្លី មនុស្សប្រុសស្រីបំពូកខ្លះ មានអាយុច្រើនឬអាយុវែង មនុស្សប៉ែកខ្លះ មានជម្ងឺដំកាត់ច្រើនក្នុងខ្លួន ឬមានជម្ងឺជានិច្ចក្នុងរាងកាយមនុស្សប៉ែកខ្លះមានរោគាពាធតិច ឬមិនសូវមានជម្ងឺដំកាត់ មនុស្សពួកខ្លះមានពណ៌សម្បុរអាប់អន់ ឬពណ៌អាក្រក់មិនជាទីចង់មើលចង់ឃើញដល់អ្នកដទៃ, មនុស្សពួកខ្លះមានពណ៌សម្បុរភ្លឺថ្លា ឬមានពណ៌សម្បុរស្រស់ស្អាតបាត គួរជាទីចង់មើលចង់ឃើញដល់ភ្នែកគេរាល់គ្នា មនុស្សបំណែកខ្លះអាប់ឥតបុណ្យស័ក្តិ ឬជាមនុស្សមានអានុភាពតិច មិនសូវមានគេកោតខ្លាច មនុស្សបំណែកខ្លះមានបុណ្យស័ក្តិធំប្តុំថ្កើង នឹងមានសក្តានុភាពច្រើនប្រកបដោយយសបរិវារ មនុស្ស ១ ផ្នែកទៀត ជាមនុស្ស

មានទ្រព្យសម្បត្តិតិចតួចស្តួចស្តើង ឬមិនសូវមានទ្រព្យ មនុស្ស ១ ផ្នែកទៀត ជាអ្នកមានភោគសម្បត្តិច្រើនបរិបូណ៌ឥតមានខ្វះខាតឡើយ មនុស្ស ១ ក្រុមទៀត ជាមនុស្សមានត្រកូលថោកទាបដុនដាប មនុស្ស ១ ក្រុមទៀត ជាមនុស្សមានត្រកូលខ្ពង់ខ្ពស់ឧត្តុង្គឧត្តមរុងរឿង មនុស្ស ១ ប៉ែកទៀត ជាមនុស្សអាប់ឥតប្រាជ្ញា ទាំងបំណេះវិជ្ជាក៏ពុំសូវមាន មនុស្ស ១ ប៉ែកទៀត ជាមនុស្សមានប្រាជ្ញាឆ្លៀវឆ្លាសវាងវៃ ព្រមទាំងមានបំណេះវិជ្ជាផង" ឯមនុស្សទាំងអស់នេះ បើរាប់ជាគូពួកនោះត្រូវ ៧ គូ បើរាប់រាយពួកត្រូវជា ១៤ ពួក ក៏មនុស្សទាំងនេះធម្មជាតិអ្វីតាក់តែងផ្តុងផ្តើមឱ្យកើតឡើង បានជាមិនដូចគ្នាមិនស្មើគ្នានោះលោកម្ចាស់ សូមនិមន្តលោកម្ចាស់អត្ថាធិប្បាយបញ្ហានេះឱ្យច្បាស់លាស់មកមើល ។

គ្រានោះព្រះនាគសេនថេរ ថ្វាយព្រះពរទៅមហាក្សត្រវិញថា បពិត្រមហារាជ ប្រស្នាដែលទ្រង់ព្រះរាជបុច្ឆាមកនេះពីរោះពេកណាស់ ជាប្រស្នាដ៏ឧត្តមជាងប្រស្នាឯទៀត អាត្មា-

Websites: WatKhemaraRatanaram.org or WatKhmers.org

ភាពបំរុងនឹងវិសជ្ជនា ថ្វាយព្រះរាជសម្ភារមិនខាន តែមុនដែល នឹងវិសជ្ជនានោះ អាត្មាភាពសូមថ្វាយព្រះពរ សួរមហាបពិត្រ សិនថា រុក្ខាលតាជាតិព្រៃព្រឹក្សាទាំងឡាយ ដែលដុះឡើង បំរើនឡើង អំពីផែនដីតែម្យ៉ាង ចុះហេតុអ្វីមិនដូចគ្នា ឈើខ្លះ មានរសជូរ ខ្លះមានរសល្វីង ខ្លះមានរសហិរ ខ្លះមានរស បត់ ខ្លះមានរសផ្អែម ផ្សេងគ្នាមិនដូចគ្នាមិនស្មើគ្នានោះ តើធម្ម-ជាតិអ្វី តាក់តែងឱ្យផ្សេងគ្នាមហារាជ សូមព្រះអង្គវិសជ្ជនា សេចក្ដីនេះ បន្តិចមកសិនមើល ។

**ម. មញ្ញាមិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំសំគាល់ ថា ឈើទាំងឡាយបានជាមានរសផ្សេង ៗ គ្នានេះ មិនមែន ពីហេតុអ្វីទេ គឺមកពីពូជដើមវាផ្សេង ៗ គ្នា ពូជឈើណា ដែល ជូរ វេលាដល់ដុះត ៗ ទៅ ក៏នៅតែជាឈើជូរដូចមុន ពូជឈើ ណាដែលផ្អែម គ្រាដល់ដុះត ៗ ទៅ ក៏នៅជាផ្អែមដូចពូជ ដើមនោះវិញ សូមលោកម្ចាស់ជ្រាបដោយប្រការយ៉ាងនេះ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រសម្ដេចមហារាជ ឯរុក្ខជាតិ

ទាំងពួងបានជាមានរសផ្សេងគ្នា មិនដូចគ្នា ព្រោះពូជដើមវាផ្សេងគ្នាយ៉ាងណាមិញ ក៏មនុស្សប្រុសស្រីទាំងឡាយ ដែលមានអាយុខ្លីអាយុវែងមិនស្មើគ្នាជាដើមនោះ ក៏មិនគឺព្រោះហេតុអ្វី គឺមនុស្សទាំងនោះ បានសន្សំពូជគឺកុសលនិងអកុសល ទុកមកផ្សេង ៗ គ្នានោះឯង ទើបបានជាមនុស្សទាំងនោះមិនដូចគ្នា បពិត្រមហារាជ សេចក្ដីនេះត្រូវគ្នានឹងពុទ្ធភាសិត ដែលព្រះ-សម្មាសម្ពុទ្ធ ទ្រង់ត្រាស់ទេសនា ប្រារព្ធនឹងមាណពម្នាក់ថា: **កម្មស្សកា មាណវ សត្តា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មបដិសរណា កម្មំសត្តេ វិភជ្ជតិ យទិទំ ហីនប្បណីតតាយាតិ** ដូច្នេះជាប្រធានឥឡូវនេះអាត្មាភាពនឹងប្រែសេចក្ដីក្នុងកម្មទាំង៥យ៉ាងនេះ ហើយនឹងអធិប្បាយថ្វាយមហាបពិត្រ តាមខ្សែពុទ្ធភាសិតនោះថា **មាណវ** ម្នាលមាណព **សត្តា** សត្វទាំងឡាយ **កម្មស្សកា** មានកម្មជារបស់ខ្លួន **កម្មទាយាទា** នឹងត្រូវទទួលនូវផលនៃកម្ម **កម្មយោនី** មានកម្មជាកំណើត **កម្មពន្ធូ** មានកម្មជាផៅពង្ស **កម្មបដិសរណា** មានកម្មជាទី

រលឹកតប បពិត្រមហារាជ កុសលកម្មនិងអកុសលកម្មនេះជាមេបំណែកបែកសត្វឱ្យអាក្រក់ឱ្យល្អផ្សេងគ្នា ឥតមានអ្នកឯណាមានអំណាច អាចនឹងបែកសត្វទាំងនោះបានឡើយ ក្រៅពីកុសលនិងអកុសលនេះ ។

ដែលថាកម្មស្សកានោះ សេចក្តីថា សត្វទាំងឡាយឯណាបានធ្វើកុសលកម្ម ឬអកុសលកម្ម ដោយកាយ វាចា ចិត្ត របស់ខ្លួនហើយផលនៃកុសលកម្មឬអកុសលកម្មនោះ មិនដែលលះបង់បោលម្ចាស់ដែលធ្វើនោះឡើយ នឹងត្រឡប់មកតាក់តែងឱ្យកើតជានាមនិងរូប គឺជាខ្លួនប្រាណរបស់សត្វនោះវិញមិនខាន ហេតុនេះហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាថា កម្មស្សកា សត្វមានកម្មជារបស់ខ្លួន ។ ធ្វើការងារល្អជាកុសល ក៏មានកេរ្តិ៍ឈ្មោះពីរោះផ្សាយទៅជាកល្យាណកិត្តិសព្ទ បើខ្លួនធ្វើការងារអាក្រក់ជាអកុសល ក៏មានកេរ្តិ៍ឈ្មោះមិនពីរោះផ្សាយទៅជាបាបកិត្តិសព្ទ ឯសេចក្តីល្អនិងសេចក្តីអាក្រក់នេះ ឥតមានអ្នកឯណា ១ នឹងនាំមកឱ្យខ្លួនឡើយ គឺខ្លួនឯងឱ្យឯងនោះឯង ។

**កម្មទាយាទា** ជាសត្វទាំងឡាយ ត្រូវទទួលយកនូវផល នៃកុសលកម្ម ឬអកុសលកម្ម គឺផ្លែបុណ្យឬផ្លែបាប ដែល ខ្លួនបានបណ្តុះដាំទុកមករួចហើយជាពូជដើម គឺជាដែលខ្លួន បានធ្វើល្អឬអាក្រក់មកហើយនោះឯង កាលដើមខ្លួនធ្វើល្អ វេ-លាបានផល ៗ នោះនាំឱ្យបំរើនល្អ, កាលដើមខ្លួនធ្វើអាក្រក់ វេលាបានផល ៗ នោះនាំឱ្យបំរើនអាក្រក់ ។

**កម្មយោនី** ជាសត្វទាំងឡាយមានកុសលកម្ម និងអកុ-សលកម្មដែលខ្លួនបានសាងសន្សំទុកមកពីជាន់មុននោះ នាំឱ្យ កើតក្នុងទុគ្គតិភពឬ សុគតិភពមិនខាន កុសលកម្មឬអកុសល-កម្មនេះហើយដែលជាអ្នកតាក់តែងជាតិ, តាក់តែងភព, តាក់ តែងសម្បត្តិ, ទុកសម្រាប់ឱ្យសត្វបានធ្វើនោះមិនដែលខាន ឥតមានធម្មជាតិឯណា ១ ក្រៅពីកុសលឬអកុសលនេះទៅតាក់ តែងទុកឱ្យឡើយ ។

**កម្មពន្ធុ** ជាសត្វទាំងឡាយមានកម្ម គឺបុណ្យឬបាបដែល ខ្លួនបានធ្វើហើយនោះ នឹងមកជាផៅពង្ស ជាញាតិ ជាមិត្រ

Websites: WatKhemaraRatanaram.org or WatKhmers.org

ជាបងប្អូនមិនខានឡើយ គឺថាបើខ្លួនធ្វើអំពើល្អ អ្នកដែលល្អនឹងត្រូវការជាមួយនឹងខ្លួនផង បើខ្លួនធ្វើអាក្រក់ អ្នកដែលអាក្រក់នឹងត្រូវការជាមួយនឹងខ្លួនផង ធម្មតាសត្វទាំងឡាយតែប្រព្រឹត្តធ្វើការនីមួយ ៗ ត្រូវគ្នាជួបគ្នាហើយ អ្នកទាំងនោះតែងតែចូលចិត្តរាប់អានគ្នាមិនខានព្រោះថាការងារត្រូវគ្នាជួបគ្នា ។

**កម្មបដិសរណា** ថាសត្វទាំងឡាយ មានការងារល្អឬអាក្រក់ជាទីរឭកតគ្នា ឬថាមានការងារល្អនឹងអាក្រក់ជាទីសំណាក់អាស្រ័យ ឬថាជាគ្រូអាចារ្យជាធំជាងខ្លួន ព្រោះថាតែសត្វធ្វើការល្អហើយ ការនោះឯងតែងបង្គាប់សត្វ ឬនាំចិត្តសត្វឱ្យនឹកល្អឱ្យគិតល្អ បើសត្វធ្វើការអាក្រក់ហើយ, ការអាក្រក់នោះឯងតែងហៅ តែងប្រើសត្វឱ្យនឹករក ឬរឭកទៅរកសេចក្ដីអាក្រក់នោះមិនខាន ព្រោះហេតុយ៉ាងហ្នឹងហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាថា កម្មបដិសរណា សត្វទាំងឡាយមានការងារជាទីរឭកគ្រប់ប្រាណ។

**មហារាជ** បពិត្រសម្ដេចមហារាជ សេចក្ដីដែលអាត្មា-

ភាពអធិប្បាយថ្វាយព្រះពរមកនេះតាមខ្សែព្រះពុទ្ធភាសិត ដែលទ្រង់ទេសនាទុកមកថា "សត្វដែលផ្សេងគ្នាមិនស្មើគ្នានោះ មិនមែនពីព្រោះហេតុអ្វីឡើយ គឺពីព្រោះតែសត្វទាំងនោះប្រព្រឹត្តធ្វើអំពើខុសគ្នា សត្វពួកខ្លះបួលចិត្តបង់ធ្វើកុសល, ធ្វើបុណ្យ, ធ្វើល្អ, សត្វពួកខ្លះពេញចិត្តបង់ធ្វើអកុសលធ្វើបាបធ្វើអាក្រក់ (អំពើល្អ អាក្រក់) នេះហើយដែលជាអ្នកបែកបំណែកឱ្យសត្វមិនស្មើគ្នា សត្វណាធ្វើល្អ បានចំណែកល្អគឺមានអាយុវែងមិនសូវមានរោគាពាធជាដើម សត្វណាធ្វើអាក្រក់ បានចំណែកអាក្រក់គឺបានអាយុខ្លី មានរោគច្រើនជាដើម ប្រៀបដូចដើមឈើទាំងឡាយដែលមានរសជាតិជូរចត់ផ្សេង ៗ គ្នា ព្រោះតែពូជដើមផ្សេងគ្នានោះឯង សូមមហារាជ ជ្រាប ។

**ម. កល្លោសិ ភន្តេ** បពិត្រព្រះថេរដ៏ចំរើន លោកម្ចាស់ប៉ិនប្រសប់ណាស់ បេះទាញយកពុទ្ធភាសិតមកសំដែងដោះប្រស្នាគួរឱ្យជាទីអស្ចារ្យពេកណាស់ ខ្ញុំបួលចិត្តអស់សង្ស័យហើយ ។

## បដិកច្ចេរវាយាមករណបញ្ហា ។ ទី ៥

ព្រះបាទមិលិន្ទនរិន្ទរាជ ស្ដេចទ្រង់បុច្ឆាចំពោះទៅព្រះនាគ-

សេនបេរក្នុងប្រស្នាទី ៥ នេះតទៅថា បពិត្រព្រះថេរដ៏បម្រើន ខ្ញុំមានសេចក្ដីសង្ស័យនឹងពុទ្ធដីការបស់លោកម្ចាស់ ដែលពោលនឹងខ្ញុំពីកាលមុនថា អ្នកបួលក្នុងពុទ្ធសាសនា តែងនឹងធ្វើឱ្យរលត់នូវសេចក្ដីទុក្ខក្នុងបច្ចុប្បន្ននេះ ដើម្បីនឹងមិនឱ្យទុក្ខដទៃកើតឡើងបាន ម្យ៉ាងទៀតថា អ្នកបួសនោះលោកតែងព្យាយាមបំបាត់ទុក្ខទាំងពួងជាមុន មិនឱ្យទុក្ខនោះកើតឡើងទាន់ បុះហេតុអ្វីក៏បាំធ្វើដូច្នោះ បើប្រសិនណាបណ្ដោយឱ្យទុក្ខទាំងនោះមកដល់ហើយ សឹមព្យាយាមរំលត់ទៅមិនបានឬដូចម្ដេច លោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រព្រះរាជសម្ភារ ឯអ្នកបួសក្នុងព្រះពុទ្ធសាសនានេះ កាលបើបណ្ដោយឱ្យសេចក្ដីទុក្ខមកដល់ហើយទើបធ្វើព្យាយាមរំលត់នោះ ការព្យាយាមនោះមិនមែនជាកិច្ចត្រូវធ្វើឡើយ ឯការដែលនឹងរំលត់ទុក្ខនោះត្រូវធ្វើព្យាយាមទុកជាមុនទើបគួរជាកិច្ចត្រូវធ្វើ ។

**ម. ឱបមំ ករោហិ** សូមលោកម្ចាស់ប្រៀបប្រាយសេចក្ដីនោះយ៉ាងឱ្លបន្តិចមកនឹងស្ដាប់មើល ។

**ឥ. តំ កឹ មញ្ញសិ មហារាជ** បពិត្រសម្តេចមហារាជ ចុះព្រះរាជសម្ភារស្តេចទ្រង់ព្រះរាជដំរិះសំគាល់នូវហេតុនោះថាដូចម្តេច រឿងនេះអាត្មាភាពសូមប្រៀបជាសេចក្តីថ្វាយថាដូចជាអង្គរបស់មហាបពិត្រ ប្រសិនណាបើជាព្រះអង្គមានសេចក្តីស្រេកនូវព្រះឧទករស ក្នុងវេលាណា១ ហើយទើបនឹងទ្រង់បាត់បែងឱ្យមនុស្សទាំងឡាយកកាយជីកនូវអណ្តូងឬស្រះបោក្ខរណីដើម្បីតម្កល់ទុកនូវទឹកសម្រាប់សោយ រួចហើយទើបនឹងតាំងព្រះរាជបហប្ញទ័យថា អាត្មាអញនឹងរកទឹកផឹកដូច្នេះ ក្នុងវេលានោះឬអ្វីមហារាជ ។

**ម. ន ហិ ភន្តេ** បពិត្រព្រះបេរដ៏ចំរើន មិនមែនដូច្នោះទេឯទឹកនោះយើងត្រូវធ្វើទឹកស្លែងសម្រាប់តម្កល់ទុកជាមុន ឱ្យមាននៅជានិច្ចសម្រាប់ផឹក តែនឹកបង់ផឹកវេលាណាក៏ផឹកក្នុងវេលានោះភ្លាមទៅ មិនមែនធ្វេសប្រហែសបណ្តែតបណ្តោយឱ្យដល់ពេលស្រេកឃ្លាន ហើយទើបនឹងបាត់បែងឱ្យគេជីកអណ្តូងឬស្រះដូច្នោះទេលោកម្ចាស់ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រព្រះបរមរាជាធិរាជជាចំ-ណែកអស់លោកអ្នកបួសក្នុងព្រះពុទ្ធសាសនា ដែលខំព្យាយាមរំលត់នូវសេចក្ដីទុក្ខជាមុននោះក៏ដូច្នោះដែរ ឯសេចក្ដីទុក្ខនេះលុះតែខំព្យាយាមប្រឹងប្រែងគេចវេះចេញ អំពីចម្ងាយជាមុនទើបបានរួចខ្លះហើយគួរជាកិច្ចត្រូវធ្វើផង បើបង្អង់ទុកឱ្យសេចក្ដីទុក្ខចូលមកជិតឬមកដល់ហើយ ទើបព្យាយាមតទល់នឹងសេចក្ដីទុក្ខនេះ មុខជាមិនអាចនឹងតទល់បានឡើយ អំពើដែលខំធ្វើនោះ ក៏នឹងនាំឱ្យគ្រាន់តែហត់នឿយឥតប្រយោជន៍ ហើយមិនមែនជាកិច្ចត្រូវធ្វើផង ។

**ម.** សូមលោកម្ចាស់ ឧបមាឱ្យផ្សេងពីនេះតទៅទៀតមើលព្រះថេរ ។

**ន. តំ កឹ មញ្ញសិ មហារាជ** បពិត្រព្រះរាជសម្ភារបុះមហាប-ពិត្រស្ដេចជ្រាបនូវរឿងនេះដូចម្ដេចទៅ ឯអាត្មាភាពសូមប្រៀបសេចក្ដីនេះថ្វាយថា ដូចជាអង្គមហារាជ ប្រសិនណាបើស្ដេចមានសេចក្ដីស្រេកឃ្លាននូវក្រយាស្ងោយយ៉ាងខ្លាំងឡើងក្នុងព្រះ

កាយក្នុងគ្រាណា ១ ហើយព្រះអង្គទើបនឹងត្រាស់បង្គាប់ឱ្យមនុស្សទាំងពួងភ្នួរស្រែ ឱ្យព្រួសស្រូវខ្សាយឬស្រូវដំណើប ហើយទើបដឹកនាំនូវស្រូវនោះមក រួចទើបទ្រង់តាំងព្រះរាជ-ហឫទ័យថា អាត្មាអញនឹងបរិភោគនូវបាយដូច្នេះ ក្នុងគ្រានោះឬអ្វីមហាបពិត្រ ។

**ម. ន ហិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចំរើន មិនមែនដូច្នោះទេ ឯភោជនាហារនោះ យើងត្រូវបង្គាប់ឱ្យពួកវិសេសគេបាត់បែងទុកប្រចាំពេលរាល់ពេល តែឃ្លានវេលាណានឹងបរិភោគក្នុងវេលានោះ មិនបាច់ចាំបង្គាប់ឱ្យភ្នួរស្រែនោះឡើយ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រមហារាជ សេចក្តីនេះប្រៀបដូចការព្យាយាម រំលត់ទុក្ខរបស់លោកអ្នកបួសក្នុងពេលដែលទុក្ខមកដល់ហើយ ទើបខំព្យាយាមនោះមិនអាចរំលត់បានឡើយ ហើយមិនមែនជាកិច្ចការត្រូវប្រកបផង គួរតែព្យាយាមបំរុងទុកជាមុនទើបគួរជាកិច្ចត្រូវធ្វើ ប្រៀបដូចជាអ្នកដែលត្រូវបរិភោគនូវភោជនាហារ គួរតែបាត់បែងអាហារនោះបំរុងទុក

ជាមុន តែឃ្លានវេលាណា ក៏នឹងទទួលទានក្នុងវេលានោះទើប មិនលំបាក ។

**ម. ភិយ្យោ ឱបម្មំ ករោហិ** សូមលោកម្ចាស់ឧបមាឱ្យច្រើនទៅមើល ។

**ន. តំ កឹ មញ្ញសិ មហារាជ** បពិត្រមហារាជ ចុះមហាបពិត្រស្តេចជ្រាបនូវហេតុនោះថាយ៉ាងណា អាត្មាភាពសូមថ្វាយព្រះពរថា ប្រៀបដូចអង្គមហារាជប្រសិនណាបើមានសឹកសង្គ្រាមគេលើកមកដល់ជិតព្រះអង្គហើយក្នុងវេលាណា បំណែកព្រះអង្គទើបនឹងបាត់បែង ឱ្យជីកគូស្នាមភ្លោះព័ទ្ធជុំព្រះរាជវាំង ឱ្យធ្វើកំពែងបិទបាំងអំពីខាងក្នុង ឱ្យរាំងបាំងទ្វារ ស្រុកឱ្យធ្វើបន្ទាយ ហើយដឹកនាំមកនូវស្រូវទុកបំរុងបរិភោគ ហើយទើបនឹងបាត់ការឱ្យបង្ហាត់ពលដំរី, ពលសេះ, ពលរទេះ, ពលធ្នូពលដាវលំពែង ក្នុងពេលដែលសង្គ្រាមគេមកដល់នោះ ឬអ្វីព្រះអង្គ។

**ម. នហិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចំរើន មិនមែនដូច្នោះទេ

ឯកិច្ចការដែលត្រូវរក្សានូវព្រះនគរនោះ យើងត្រូវប្រុងប្រយ័ត្ន ចាត់ការទុកជាមុនពីចម្ងាយជាស្រេច តែបង្អង់ទុកឱ្យសត្រូវមក ដល់ហើយទើបចាត់ការ ៗ នោះមិនអាចសំរេចទៅបានឡើយ ។

**៩. ឯវមេវ ខោ មហារាជ** បពិត្រព្រះរាជសម្ភារ ឯអ្នកបួសក្នុង ពុទ្ធសាសនា ថាបើបណ្ដែតបណ្ដោយឱ្យសេចក្ដីទុក្ខនោះ ចូល មកដល់ហើយទើបព្យាយាមរំលត់ទុក្ខនោះ សេចក្ដីព្យាយាម នោះមិនមានប្រយោជន៍ឡើយ លុះតែព្យាយាមបំរុងទុកជាមុន ទើបជាកិច្ចគួរគប្បីប្រកប បពិត្រព្រះរាជសម្ភារ សេចក្ដីនេះដូចគ្នា នឹងភាសិតរបស់ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាទុកមកថា:

**បដិកច្ចេវ តំ កយិរា យំ ជញ្ញា ហិតមត្តនោ**
**ន សាកដិកចិន្តាយ មន្តាធីរោ បរក្កមេ**
**យថាបិ [1] សាកដិកោ នាម បសត្ថំ សមំ ហិត្វា មហាបថំ**
**វិសមំ មគ្គមារុយ្ហ អក្ខច្ឆិន្នោវ ឈាយតិ**
**ឯវំ ធម្មា អបក្កម្ម អធម្មមនុវត្តិយ**

---

១ ក្នុងសៀវភៅមិលិន្ទបញ្ហាប្រែរយថា “ន ច សាកដិចិត្តេន” មិលិន្ទបញ្ហាបាលីថា “ន សាកដិកចិន្តាយ” ដូចក្នុងទីនេះ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

## មន្ទោ មច្ចុមុខំ បត្តោ អក្ខច្ឆិន្នោវ ឈាយតីតិ

(ប្រែជាសេចក្ដីថា) ធម្មតាអ្នកប្រាជ្ញដែលមានប្រាជ្ញា មានចំណេះចេះដឹងច្រើន ជាអ្នកមានព្យាយាម លោកតែងដឹងនូវកិច្ចឯណាដែលជាប្រយោជន៍របស់ខ្លួនហើយ ក៏តែងធ្វើនូវកិច្ចជាប្រយោជន៍នោះ ឱ្យស្រេចជាមុនមិនខាន មិនបានធ្វើតាមគំនិតនៃអ្នកឈ្នួលរទេះនោះឡើយ ឯអ្នកឈ្នួលរទេះខ្លះដែលល្ងង់តែងលះបង់បោលនូវផ្លូវធំដែលរាបស្មើល្អនោះចេញ ហើយបររទេះរបស់ខ្លួនទៅតាមផ្លូវតូចដែលមានជង្ហុកថ្លុកច្រើនមិនបានរាបស្មើ ឯរទេះនោះក៏បាក់ភ្លៅវិនាសទៅ ចំណែកម្ចាស់រទេះក៏កើតទោមនស្សតូចចិត្តនៅក្នុងទីនោះយ៉ាងណាមិញ ក៏ធម្មតាបុគ្គលដែលជាអ្នកល្ងង់ខ្លៅអប្បឥតប្រាជ្ញា តែងគេចចៀសវាងចាកធម៌ដែលត្រូវដែលល្អនោះចេញ ខំប្រព្រឹត្តធ្វើតាមធម៌ដែលខុសដែលលាមកនោះវិញ វេលាសេចក្ដីស្លាប់មកដល់ហើយក៏តក់ស្លុតវង្វេងស្មារតីទៅក្នុងគ្រានោះ ប្រៀបដូចជាអ្នកម្ចាស់រទេះដែលមានរទេះបាក់ភ្លៅដេកនៅក្នុងផ្លូវនោះឯង ។

**ម. កល្លោសិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ឆ្លៀសឆ្លាសពេកណាស់ បេះវិសជ្ជនាពីរោះក្បោះក្បាយគួរឱ្យចូលចិត្តណាស់ខ្ញុំអស់សង្ស័យហើយ ។

## បកតិអគ្គិតោនេរយគ្គីនំឧណ្ហាការបញ្ហា ។ ទី ៦

ព្រះបាទមិលិន្ទ្រាធិរាជ ស្ដេចទ្រង់ព្រះរាជបុច្ឆាសួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៦ នេះថា បពិត្រព្រះថេរដ៏ចម្រើន ខ្ញុំមានសេចក្ដីសង្ស័យនឹងពាក្យលោកម្ចាស់ ដែលលោកម្ចាស់បានពោលនឹងខ្ញុំថា "ភ្លើងនរកមានកម្ដៅជាទីបំផុតជាងភ្លើងយើងជាប្រក្រតីសព្វថ្ងៃនេះ ឯភ្លើងយើងជាប្រក្រតីនេះ ថាបើបុគ្គលនឹងយកដុំថ្មយ៉ាងតូចប្រមាណប៉ុនកំភួនដៃ ឬកំភួនជើងទៅដាក់ដុតក្នុងគំនរភ្លើងយ៉ាងធំៗ អស់ពេលប្រហែល ១ ថ្ងៃក៏ដោយ ឯដុំថ្មនោះមិនអាចនឹងរលួយទៅបានឡើយ បំណែកភ្លើងក្នុងស្ថាននរកនោះ ថាបើមានដុំថ្មយ៉ាងធំប្រមាណប៉ុន ។ ផ្ទះហើយធ្លាក់ចុះទៅក្នុងគំនរភ្លើងនរកនោះ ដុំថ្មធំនោះឯងក៏នឹងក្ដៅរលាយសាបសូន្យទៅ ១ រំពេចមិនខានឡើយ ពាក្យពោល

យ៉ាងនេះខ្ញុំមិនជឿសោះឡើយ ម្យ៉ាងទៀតជាសត្វដែលកើតក្នុងស្ថាននរកនោះ មានអាយុវែងដល់ទៅ ១០០០ ឆ្នាំ ចុះហេតុអ្វីបើភ្លើងនរកនោះ មានកម្តៅក្តៅណាស់ក៏មិនឆេះនូវសត្វនរកទាំងនោះឱ្យសុះរលាយ ១ រំពេចទៅ ក៏ឱ្យស្ថិតនៅយូរដល់ម្លេះ សេចក្តីយ៉ាងហ្នឹងខ្ញុំរកជឿមិនបាន លោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរទៅវិញថា បពិត្រមហារាជ ចុះមហាបពិត្រសម្គាល់នូវសេចក្តីនោះជាដូចម្តេចទៅ រឿងនេះអាត្មាភាពសូមថ្វាយព្រះពរមហាបពិត្រវិញថា ចុះមហាបពិត្រស្តេចជ្រាបដែរឬ ជាមេក្ងោក, មេមាន់, មេមង្ករ, មេក្រពើ និងមេអណ្តើកទាំងឡាយនោះ វាតែងទំពាស៊ីឬតែងលេបនូវដុំថ្ម ឬដុំក្រួសទាំងឡាយទៅក្នុងពោះវានោះ ជាមែនឬមិនមែនទេ មហារាជ ។

**ម. អាម ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ពាក្យនោះមែនយ៉ាងហ្នឹងហើយ ឯមេសត្វទាំងឡាយមានមេក្ងោកជាដើមនោះ វាតែងស៊ីនូវដុំថ្មនិងក្រួសទាំងនោះ ជាអាហារមែនពិតហើយ លោកម្ចាស់ ។

**ន. កឹ បន តានិ មហារាជ** បពិត្រមហារាជ ចុះដុំថ្មឬដុំក្រួសទាំងឡាយដែលចូលទៅក្នុងផ្ទៃនៃសត្វទាំងនោះ ប្រហែលជារលួយដែរឬអ្វី មហារាជ ។

**ម. អាម ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ឯដុំទាំងនោះតែងក្តៅរលួយអស់ទៅមិនមានសល់ទេ ។

**ន.** បពិត្រមហារាជ ចុះគភ៌គឺពងឬកូនដែលនៅក្នុងផ្ទៃនៃមេសត្វទាំងនោះ ប្រហែលជារលួយរលាយអស់ដូចជាដុំថ្មនិងដុំក្រួសនោះដែរឬដូចម្តេច ។

**ម. ន ហិ ភន្តេ** គភ៌របស់សត្វទាំងនោះមិនមែនរលួយដូច្នោះទេ លោកម្ចាស់ វារលួយតែត្រង់ដុំថ្មនិងដុំក្រួសដែលជាអាហារដែលសត្វទាំងឡាយលេបចូលពីក្រៅមកនោះ ឯត្រង់គភ៌សត្វដែលកើតខាងក្នុងពោះនោះមិនបានរលួយទេ ។

**ន. កេន ការណេន** ព្រោះហេតុដូចម្តេចមហាបពិត្រត្រង់ដុំក្រួសដុំថ្មបេះធេះរលួយទៅបាន ឯគភ៌ដែលស្ថិតនៅក្នុងពោះសត្វនោះដូចគ្នាដែរទៅជាមិនរលួយ សេចក្តីនេះគួរឱ្យសង្ស័យដែរ មហារាជស្តេចនឹងទ្រង់ជ្រាបថាយ៉ាងណា ។

**ម. មញ្ញាមិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន សេចក្តីនេះ ខ្ញុំយល់ថាឯគតិរបស់សត្វដែលមិនរលួយ ដូចអាហារទាំងពួងនោះ ព្រោះគតិនោះអាស្រ័យនៅដោយកម្លាំង នៃផលជាកុសលឬអកុសល ដែលសត្វនោះបានធ្វើហើយនោះឯង សូមលោកម្ចាស់ជ្រាប ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រសម្តេចមហារាជ សេចក្តីនេះប្រៀបដូចសត្វនរកដែលកើតក្នុងភ្លើងនរក ៗ ឆេះនៅក្នុងស្ថាននរកនោះអស់ ១ ពាន់ឆ្នាំឬច្រើនជាង ១ ពាន់ឆ្នាំ ហើយសត្វទាំងនោះមិនអាចនឹងរលាយទៅបាន ក៏មិនមែនដោយហេតុអ្វីឡើយ គឺដោយកម្លាំងផលនៃអកុសលកម្មរបស់សត្វនោះឯងហើយ បានជាសត្វបានកើត បានចម្រើននៅក្នុងនរកនោះ វេលាដល់ស្លាប់ក៏ស្លាប់ក្នុងទីនោះផង បពិត្រមហារាជពាក្យនេះត្រូវគ្នានឹងភាសិតរបស់ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទេសនាទុកថា សោ ន ច តាវ កាលំ ករេយ្យ យាវ ន តំ បាបកម្មំ ព្យន្តី ហោតិ សេចក្តីថា បើបាបកម្មមិនទាន់អស់ ឬមិនទាន់

វិនាសទៅដរាបណា សត្វក៏មិនទាន់ធ្វើកាលកិរិយាទៅដរាប នោះដែរ សូមស្តេចជ្រាប ។

**ម.** សូមលោកម្ចាស់ ឧបមាឱ្យច្រើនជាងនេះទៅមើល ។

**ន. តំ កឹ មញ្ញសិ មហារាជ** បពិត្រមហារាជ ចុះសេចក្តីនេះមហាបពិត្រស្តេចនឹងទ្រង់យល់ជាដូចម្តេច អាត្មាភាពសូមថ្វាយព្រះពរសួរមហាបពិត្រវិញថា ចុះមេសីហទាំងឡាយក្តី មេខ្លាធំក្តី មេខ្លាដំបងក្តី អាត្មាភាពតែងឮមកថា សត្វទាំងឡាយនោះវាតែងទំពាស៊ី នូវសាច់និងឆ្អឹងដ៏រឹងទាំងឡាយជាអាហារមែនឬអ្វី មហាបពិត្រ ។

**ម. អាម ភន្តេ** សត្វទាំងឡាយនោះ វាតែងបរិភោគនូវឆ្អឹងនិងសាច់នោះមែន លោកម្ចាស់ ។

**ន. កឹ បន មហារាជ** បពិត្រមហារាជ ចុះឆ្អឹងដែលជារបស់រឹងនោះ វេលាដល់ចូលទៅនៅក្នុងក្រពះពោះវៀនសត្វទាំងនោះ ឆ្អឹងនោះជានឹងរលួយដែរឬដូចម្តេច ។

**ម. អាម ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ឆ្អឹងទាំងនោះតែងរលួយទៅជាធម្មតា ឥតមានសល់នៅទេ ។

**ន. កុច្ឆិគតោ គព្ភោ** បុះគភ៌ដែលតម្កល់នៅក្នុងផ្ទៃនៃមេសត្វទាំងនោះ ៗ មិនរលួយទៅដែរឬ ។

**ម. ន ហិ ភន្តេ** គភ៌នោះមិនរលួយទេ លោកម្ចាស់ ។

**ន. កេន ការណេន** ហេតុដូចម្តេចក៏មិនរលួយ ។

**ម. កម្មាធិកតេន** បានជាមិនរលួយព្រោះមានកម្ម ថែរក្សាមិនឱ្យវិនាសទៅ លោកម្ចាស់ ។

ឯព្រះមហាក្សត្រស្តេចបានឆ្លើយដូច្នោះហើយ ទើបទ្រង់និមន្តព្រះនាគសេនថេរឱ្យឧបមាតទៅទៀត ។

ព្រះនាគសេនថេរ លោកក៏ថ្វាយព្រះពរថា មហារាជបពិត្រមហារាជ ដ៏ជាមហិស្សរាធិបតី សេចក្តីនេះប្រៀបដូចសកុណជាតិទាំងឡាយ មានមេសសេះជាដើម ជាសត្វតែងទំពាស៊ីនូវឈើរឹងទាំងឡាយ ហើយមិនដល់នូវសេចក្តីវិនាសឡើយ ម្យ៉ាងទៀតអាត្មាភាពសូមថ្វាយព្រះពរមហាបពិត្រថាស្ត្រីក្នុងស្រុកយោនកដែលជាសុខុមាលជាតិក្តី ស្តេចស្រីដែលជាសុខុមាលជាតិក្តី ព្រាហ្មណីដែលជាសុខុមាលជាតិក្តី ស្រី

គហបតីដែលជាសុខុមាលជាតិក្តី តែងឮថាស្រីទាំងនោះតែងបរិភោគនូវដុំសាច់នឹងបង្អែមទាំងឡាយដ៏រឹង ៗ ជាមែន ឬអ្វី មហាបពិត្រ ។

**ម. អាម ភន្តេ** មែនលោកម្ចាស់ ។

**ន. កឹ បន តានិ** បពិត្រមហារាជ ចុះភោជនាហារទាំងឡាយនោះ លុះវេលាដល់ទៅក្នុងផ្ទៃនៃស្រីទាំងនោះហើយ មុខជានឹងរលួយ ឬដូចម្តេច មហាបពិត្រ ។

**ម. អាម ភន្តេ** មុខជានឹងរលួយមិនខានទេ លោកម្ចាស់ ។

**ន. យោ បន តាសំ** ចុះទារកឯណាដែលអាស្រ័យនៅក្នុងផ្ទៃនៃស្ត្រីទាំងឡាយនោះ ទារកនោះនឹងត្រូវរលួយដែរឬដូចម្តេច ។

**ម. ន ហិ ភន្តេ** ទារកដែលនៅក្នុងផ្ទៃនោះ មិនរលួយទេ លោកម្ចាស់ ។

**ន. កេន ការណេន** ចុះហេតុអ្វី មហាបពិត្រ បំណែកអាហារដែលនៅក្នុងផ្ទៃក៏អាចរលួយទៅបាន តែត្រង់ទារកជាវត្ថុស្ថិតនៅបន្ទាន់គ្នាដែរដូចម្តេចក៏មិនរលួយ ។

**ម. មញ្ញាមិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន សេចក្តីនេះខ្ញុំយល់ថា ឯទារកដែលនៅក្នុងផ្ទៃ ហើយមិនវិនាសទៅនោះ គឺមិនមែនហេតុអ្វីទេគឺផលកម្មនោះឯង ជាអ្នកទំនុកបំរុងថែរក្សាលោកម្ចាស់ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រសម្តេចព្រះមហារាជ សេចក្តីនេះប្រៀបដូចសត្វនរកទាំងឡាយដែលឆេះនៅក្នុងស្ថាននរកទល់ទុក្ខវេទនាអស់ពាន់នៃឆ្នាំជាប្រមាណ តែមិនអាចនឹងសុះនឹងរលួយទៅបាន ព្រោះសត្វទាំងនោះ កាលដែលកើតក៏កើតក្នុងទីនោះ វេលាដល់ចំរើនដល់ស្លាប់ក៏ចំរើននិងស្លាប់នៅក្នុងទីនោះ ព្រោះតែផលនៃអកុសលកម្មនោះឯងជួយថែរក្សា បពិត្រមហារាជ សេចក្តីនេះសមដូចពុទ្ធភាសិតដែលទ្រង់ប្រោស ប្រទានទុកមកថា សោ ន ច តាវ កាលំ ករោតិ យាវ ន កតំ បាបកម្មំ ព្យន្តី ហោតិ សេចក្តីថា បាបកម្មរបស់សត្វដែលបានធ្វើទុកមកហើយមិនទាន់អស់មិនទាន់វិនាសទៅដរាបណា សត្វទាំងនោះក៏មិនអាចនឹងធ្វើនូវកាលកិរិយាទៅដរាបនោះឯង សូមមហាបពិត្រជ្រាប ។

**ម. កល្លោសិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ឆ្លាសវាងវៃណាស់ បេះវិសជ្ជនាពីរោះក្បោះក្បាយគួរឱ្យរីករាយបាន ។

## បឋវីសណ្ឋារកបញ្ហា ។ ទី ៧

ព្រះបាទមិលិន្ទ្រាធិរាជ ស្ដេចទ្រង់សួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៧ នេះថា បពិត្រព្រះថេរដ៏ចំរើន លោកម្ចាស់បានពោលនឹងខ្ញុំថា មហាប្រថពីសព្វថ្ងៃនេះតម្កល់នៅលើទឹក ៗ តម្កល់នៅលើខ្យល់ ៗ តម្កល់នៅលើអាកាស ពាក្យនេះខ្ញុំនឹងរកចូលចិត្តជឿមិនកើតទេ លោកម្ចាស់ ។

គ្រានោះព្រះនាគសេនថេរ លោកក៏ចាប់យកនូវធម្មក្រកដែលពេញទៅដោយទឹក ហើយលើកឡើង ទើបថ្វាយព្រះពរទៅមហាក្សត្រថា បពិត្រព្រះរាជសម្ភារ ទឹកដែលស្ថិតនៅក្នុងធម្មក្រកដោយអំណាចនៃខ្យល់ទ្រទ្រង់ ឬថែរក្សាទុកនៅបានយ៉ាងណា ទឹកដែលតម្កល់នៅលើខ្យល់ក៏យ៉ាងនោះ មហារាជ។

**ម.** លោកម្ចាស់ ប៉ុនប្រសប់ខាងឯប្រៀបឱបមាស្រួលស្ដាប់ល្អណាស់ ខ្ញុំព្រះករុណាចូលចិត្តអស់សង្ស័យហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# និរោធនិព្វានបញ្ហា ។ ទី ៨

ព្រះមហាក្សត្រស្ដេចទ្រង់បុច្ឆាសួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៨ នេះថា បពិត្រព្រះនាគសេន ពាក្យដែលហៅថា និរោធ ៗ គឺសេចក្ដីរលត់ទុក្ខ ៗ នោះហៅថាព្រះនិព្វានឬអ្វី លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រមហារាជ និរោធសព្វហ្នឹងហើយ ដែលជាឈ្មោះនៃព្រះនិព្វានសូមមហាបពិត្រជ្រាប ។

**ម. កថំ ភន្តេ** បពិត្រព្រះថេរដ៏បម្រើន ហេតុដូចម្ដេចក៏យកត្រង់ពាក្យថានិរោធ ៗ នោះមកសន្មតឱ្យឈ្មោះថាជាព្រះនិព្វានវិញ លោកម្ចាស់ ខ្ញុំមានសេចក្ដីសង្ស័យពេកណាស់ សូមលោកម្ចាស់អធិប្បាយពាក្យនេះជាសេចក្ដី ឱ្យងាយស្ដាប់បន្តិចមកមើល ។

**ន. សព្វេ ពាលបុថុជ្ជនា ខោ មហារាជ** បពិត្រសម្ដេចមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់សេចក្ដីនេះបុះ អាត្មា-

ភាពនឹងអធិប្បាយថ្វាយថា ធម្មតាពាលបុថុជ្ជនទាំងឡាយ តែងលើកតែងសរសើរនូវអាយតនៈខាងក្នុង គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត របស់ខ្លួន និងអាយតនៈខាងក្រៅ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វ និងធម្មារម្មណ៍របស់ខាងក្រៅ ថាជាវត្ថុឧត្តមប្រពៃ ហើយស្ថិតនៅក្នុងអំណាចនៃអាយតនៈនោះ ៗ ហេតុនោះហើយបានជាពួកសត្វពាលទាំងនោះ តែងវិលវល់រសាត់ទៅតាមខ្សែនៃតណ្ហា លិចលង់ទៅក្នុងអំណាចនៃជាតិទុក្ខ ជរាទុក្ខ មរណទុក្ខ ឥតមានស្រាកស្រាន្តមិនបានរួចមិនបានផុត អំពីសេចក្តីសោក សេចក្តីខ្សឹកខ្សួលអួលអត់ សេចក្តីទុក្ខព្រួយ សេចក្តីអាក់អន់ និងការចង្អៀតចិត្តនោះឡើយ បពិត្រព្រះរាជសម្ភារ ចំណែកខាងព្រះអរិយសាវកទាំងពួង លោកមិនបានត្រេកអរ មិនលើកមិនសរសើរនូវអាយតនៈខាងក្នុងខាងក្រៅនោះឡើយ ហើយលោកមិនតាំងនៅក្នុងអំណាចនៃអាយតនៈនោះទេ ព្រោះលោកបានរំលត់នូវតណ្ហាដែលជាខ្សែតែងដឹកនាំសត្វ ឱ្យកើតឱ្យស្លាប់បានស្រេច

ហើយ កាលបើលោករំលត់តណ្ហារលត់ហើយ ឧបាទានក៏រលត់ទៅផង លុះឧបាទានរលត់ហើយ ភពក៏រលត់រលាយទៅផង លុះភពរលាយរលត់ហើយ ជាតិ ជរា ព្យាធិ មរណា សោកក៏សោះសូន្យទៅផង ទាំងសេចក្តីក្រៀមក្រំខ្សឹកខ្សួលអន់អាក់បង្អៀតបិត្តក៏សឹងរលត់ស្ងប់ស្ងាត់បាត់បង់ទៅទាំងអស់ឥតមានសល់ឡើយ ហេតុយ៉ាងហ្នឹងហើយ មហារាជ បានជាព្រះសម្មាសម្ពុទ្ធទ្រង់ប្រោសប្រទាននូវនិរោធធម៌នេះថា ជាព្រះនិព្វានសូមស្តេចជ្រាប ។

**ម.** បួលបិត្តស្តាប់បានហើយលោកម្ចាស់ ។

## និព្វានលភនបញ្ហា ។ ទី៩

ព្រះបរមក្សត្រាធិរាជ ស្តេចទ្រង់សន្ទនាការទៅនឹងព្រះនាគសេនថេរក្នុងប្រស្នាទី ៩ នេះថា បពិត្រព្រះថេរដ៏ចម្រើន ចុះជនទាំងឡាយទាំងពួងឬអ្វីដែលត្រូវបាននូវព្រះនិព្វានគ្រប់គ្នានោះ។

ព្រះនាគសេនថេរថ្វាយព្រះពរថា ន ខោ មហារាជ បពិត្រមហារាជ ឯជនទាំងឡាយទាំងពួងនោះ មិនត្រូវបាននូវព្រះនិ-

ព្វានគ្រប់គ្នាទេ ដែលត្រូវបាននោះ ចំពោះតែជនឯណានីមួយជាអ្នកប្រតិបត្តិត្រូវទៅលើធម៌ត្រូវនិងដឹងចំពោះនូវធម៌ដែ បណ្ឌិតគប្បីដឹងចំពោះ ដឹងប្រាកដនូវធម៌ដែលបណ្ឌិតគប្បីដឹងប្រាកដលះបង់បោលនូវធម៌ដែលអ្នកប្រាជ្ញត្រូវលះបង់បោល បម្រើននូវធម៌ដែលអ្នកប្រាជ្ញត្រូវបម្រើន ធ្វើឱ្យជាក់ច្បាស់នូវធម៌ដែលអ្នកប្រាជ្ញត្រូវធ្វើឱ្យជាក់ច្បាស់ ជនបំព្វកនោះហើយដែលត្រូវបាននូវព្រះនិព្វាននោះឯង សូមទ្រង់ជ្រាប ។

**ម.** ប្ញលបិត្តហើយ លោកម្ចាស់ ។

## និព្វានសុខភាវជាននបញ្ហា ។ ទី១០

ព្រះបាទមិលិន្ទរាជ ទ្រង់សន្ទនានឹងព្រះនាគសេនបេរតទៅ ក្នុងប្រស្នាទី ១០ នេះថា បពិត្រព្រះបេរដ៏បម្រើន អ្នកឯណាដែលមិនទាន់បាននូវព្រះនិព្វាននៅឡើយ អ្នកនោះនឹងអាចដឹងថាព្រះនិព្វាននោះជាទីសុខក្សេមក្សាន្តដែរឬ ។

ព្រះនាគសេនបេរថ្វាយព្រះពរថា បពិត្រមហារាជ អ្នកឯណាដែលមិនបានដល់នូវព្រះនិព្វាននៅឡើយ អ្នកនោះក៏គង់ដឹងថាស្ថានព្រះនិព្វាននោះប្រាកដជាមានសេចក្តីសុខដោយពិត ។

**ម. កថំ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ចំណែកមនុស្ស ដែលមិនទាន់បាននូវស្ថាននិព្វាននោះទេ ចុះហេតុអ្វីក៏ដឹងថា ស្ថានព្រះនិព្វាននោះសុខសប្បាយ ។

**ន. តំ កិំ មញ្ញសិ** ចុះមហារាជ ស្តេចជ្រាបដូចម្តេចទៅរឿងនេះ អាត្មាភាពសូមថ្វាយព្រះពរថា ដូចជាជនទាំងឡាយឯណា ១ ដែលជាអ្នកមិនធ្លាប់ដាច់ដៃដាច់ជើងសោះ តើជនទាំងឡាយនោះនឹងដឹងថា ធម្មតាមនុស្សដែលកំបុតដៃកំបុតជើងនោះតែងនឹងបាននូវសេចក្តីទុក្ខដែរឬដូចម្តេច មហារាជ ។

**ម. អាម ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន មនុស្សទាំងឡាយដែលជាមនុស្សមិនកំបុតដៃជើងនោះក៏គង់ដឹងថា អ្នកដែលកំបុតដៃជើងនោះ ប្រាកដជាបាននូវសេចក្តីទុក្ខព្រួយមិនខាន ។

**ន. កថំ ជានេយ្យុំ** បពិត្រមហារាជ ចុះមនុស្សទាំងនោះជាអ្នកមិនដែលដាច់ដៃដាច់ជើងទេ ម្តេចឡើយក៏ដឹងថា កិរិយាដាច់ដៃជើងនោះជាទីនាំមកនូវសេចក្តីទុក្ខដោយពិត្រ។

**ម. អញ្ញេសំ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន មនុស្សទាំង

នោះបានជាដឹងនោះ ព្រោះបានឮបានស្តាប់នូវសំដីឬសំឡេងនៃមនុស្សទាំងឡាយដទៃដែលកំបុតដៃកំបុតជើងនោះវាស្រែកវាថ្ងូរថា កិរិយាដែលដាច់ដៃជើងនោះលំបាកពេកណាស់ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រមហារាជ សេចក្តីនេះក៏ដូចគ្នាដែរ ឯជនទាំងឡាយឯណាមួយ ដែលមិនទាន់បានព្រះនិព្វាននៅឡើយ ជនទាំងនោះឯងក៏គង់ដឹង គង់ឮនូវសំឡេង ឬសម្តីនៃលោកអ្នកដែលបានឃើញបានដល់ព្រះនិព្វាននោះ លោកសម្តែងប្រាប់មិនខាន សូមមហាបពិត្រជ្រាប ។

**ម.**ព្រះថេរម្ចាស់ស្ទាត់ជំនាញណាស់តើ ក្នុងផ្លូវប្រៀបប្រាយឧបមានុបមេយ្យគួរឱ្យចូលចិត្តស្តាប់បានអស់សង្ស័យហើយ ។

បញ្ហា ១០ ក្នុងវគ្គជាគម្រប់ ៤ ចប់ ។

## បញ្ចមវគ្គ មានប្រស្នា ១០ ប្រការ

## ពុទ្ធអត្ថិនត្ថិភាវបញ្ហា ។ ទី ១

ព្រះបាទមិលិន្ទនរិន្ទរាជស្តេចទ្រង់បុច្ឆាចំពោះទៅនឹងព្រះ-

នាគសេនថេរក្នុងប្រស្នាទី ១ ក្នុងវគ្គទី ៥ នេះតទៅទៀតថា បពិត្រព្រះថេរដ៏ចម្រើនពុទ្ធោ តយា ទិដ្ឋោ ចុះអង្គព្រះសម្មាសម្ពុទ្ធនោះ លោកម្ចាស់ដែលបានឃើញដែរឬអ៊ី ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា ន ិ មហារាជ បពិត្រព្រះរាជសម្ភារ ឯព្រះសម្មាសម្ពុទ្ធនោះ អាត្មាភាពមិនដែលឃើញទេ ព្រោះព្រះអង្គបរិនិព្វានទៅមុនអាត្មាភាពកើត ។

**ម. អថ ភន្តេ** បើលោកម្ចាស់មិនបានឃើញដោយខ្លួនឯង ព្រោះព្រះអង្គបរិនិព្វានទៅមុន ចុះក្រែងឧបជ្ឈាយ៍អាចារ្យរបស់លោកម្ចាស់ លោកដែលបានឃើញដែរឬ ។

**ន. ន ិ មហារាជ** បពិត្រព្រះរាជសម្ភារ ឯព្រះឧបជ្ឈាយ៍អាចារ្យរបស់អាត្មាភាព ក៏លោកពុំដែលបានឃើញដែរ សូមទ្រង់ជ្រាប ។

**ម. តេន ិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន បើដូច្នោះ នត្ថិ ពុទ្ធោ ព្រះពុទ្ធនោះមិនមានទេ លោកម្ចាស់ ។

**ន. កឹ បន មហារាជ** បពិត្រមហារាជ ឱហានទី គឺស្ទឹង

ឈ្មោះឱហានទីនោះ  តើព្រះអង្គដែលបានទតឃើញដោយព្រះ
នេត្រឬអ្វី ។

**ម. ន ិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ឯឱហានទីនោះខ្ញុំមិនដែលបានឃើញទេ លោកម្ចាស់ ។

**ន. អបិ តេ បិតុនា** បើអង្គមហារាជ ពុំដែលបានទស្សនាការទេ ក្រែងព្រះវររាជបិតារបស់ព្រះអង្គស្តេចធ្លាប់បានទតឬអ្វី ។

**ម. ន ិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ទាំងព្រះរាជបិតារបស់ខ្ញុំទៀត ក៏ទ្រង់មិនដែលឃើញដែរ ។

**ន. តេន ិ មហារាជ** បពិត្រព្រះរាជសម្ភារ បើដូច្នោះស្ទឹងឱហានទីនោះ មិនមែនមានទេ មហារាជ ។

**ម. អត្ថិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន ឯស្ទឹងឱហានទីនោះគឺខ្ញុំមិនដែលឃើញមែន  ទាំងព្រះបិតារបស់ខ្ញុំសោតលោកក៏មិនដែលបានឃើញដែរ  តែស្ទឹងនោះប្រាកដជាមានមិនមុសាវាទទេ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រព្រះមហារាជ ឯអង្គព្រះ-ដ៏មានព្រះភាគនោះ ពិតមែនតែខ្លួនអាត្មាភាព កើតមិនទាន់មិនបានឃើញ ទាំងគ្រូអាចារ្យរបស់អាត្មាភាពទៀត ក៏លោកមិនដែលបានឃើញដែរ តែព្រះដ៏មានព្រះភាគនោះប្រាកដជាមានមែនមិនមុសាវាទទេ ។

**ម. សេចក្ដីវិសជ្ជនា** របស់លោកម្ចាស់ច្បាស់លាស់ពេកណាស់ គួរឱ្យជឿចូលចិត្តស្ដាប់បាន ខ្ញុំក៏អស់សង្ស័យហើយ ។

## ពុទ្ធានុត្តរភាវបញ្ហា ។ ទី ២

ព្រះបរមក្សត្រាធិរាជ ស្ដេចទ្រង់ព្រះរាជបុច្ឆាចំពោះនឹងព្រះនាគសេនថេរក្នុងប្រស្នាទី ២ ថា បពិត្រព្រះថេរដ៏ចម្រើន ពុទ្ធោ អនុត្តរោ ជាព្រះសម្មាសម្ពុទ្ធនោះ ព្រអង្គប្រសើរដោយវិសេសរកបុគ្គលប្រៀបផ្ទឹមឱ្យត្រឹមស្មើជាគូមិនមាន មែនឬអ្វី ។

ព្រះនាគសេនថេរថ្វាយព្រះពរថា ភគវា អនុត្តរោ បពិត្រព្រះរាជសម្ភារ ឯសម្ដេចព្រះភគវន្ដមុនី ព្រះអង្គប្រសើរដោយវិសេសជាងមនុស្សនិងទេវតា ឥតមានអ្នកឯណា ១ នឹងប្រដូចបានឡើយ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ម. កថំ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ឯព្រះសម្មា-សម្ពុទ្ធនោះ លោកម្ចាស់មិនដែលបានឃើញទេ ចុះហេតុអ្វីក៏លោកម្ចាស់ដឹងថា ព្រះសម្មាសម្ពុទ្ធព្រះអង្គប្រសើរដោយវិសេសជាងគេទាំងពួង ។

**ន. តំ កឹ មញ្ញសិ** ចុះមហារាជស្តេចទ្រង់ព្រះយោបល់ដូចម្តេចទៅក្នុងរឿងនោះ អាត្មាភាពសូមថ្វាយព្រះពរមហាបពិត្រវិញថា ចុះមហាសមុទ្រដ៏ធំ ដែលជនទាំងឡាយឯណានីមួយមិនដែលបានឃើញសោះ តើជាជនទាំងឡាយនោះនឹងអាចដឹងថា មហាសមុទ្រនោះមានទំហំធំ មានជម្រៅជ្រៅ នឹងរាប់គណនាមិនបាន មិនដែលមានបុគ្គលណា ១ នឹងហែលឆ្លងបានឡើយ បំណែកមហានទីទាំង ៥ គឺ គង្គា ១ យមុនា ១ អចិរវតី ១ សរភូ ១ មហីនទី ១ ទាំង ៥ នេះមិនដឹងជាហូរចុះទៅកាន់ទីណា បានជាមហាសមុទ្រធំទាំងនោះ មិនដែលពេញប្រៀបឬស្រកស្រុតចុះមកជាងប្រក្រតីសោះ បពិត្រមហារាជ ប្រហែលជាស្ទឹងធំ ៗ ទាំង ៥ នោះគង់ហូរចុះទៅកាន់មហាសមុទ្រនោះឬអ្វី មហារាជ។

**ម. អាម ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ជនទាំងឡាយគេធ្លាប់ដឹងថាមហានទី ទាំង ៥ នោះតែងហូរចុះទៅកាន់មហាសមុទ្រនោះឯង លោកម្ចាស់ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រសម្តេចមហារាជ អាត្មាភាពក៏តែងបានឃើញនូវព្រះអរិយសាវកទាំងឡាយ ដែលជាព្រះអរហន្តហើយបានដឹងថា ព្រះដ៏មានព្រះភាគ ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលប្រៀបផ្ទឹមមិនបាន ដូចជាជនដែលដឹងថាមហាសមុទ្រធំមានស្ទឹងទាំង ៥ តែងហូរចុះចូលទៅមិនចេះពេញមិនចេះល្មមនោះឯង សូមទ្រង់ជ្រាប ។

**ម.** ចូលចិត្តស្តាប់បានអស់សង្ស័យហើយ លោកម្ចាស់ ។

## ពុទ្ធានុត្តរភាវជានបញ្ហា ៗ ទី ៣

ព្រះមហាក្សត្រាធិរាជ ព្រះអង្គទ្រង់បុច្ឆាសន្ធនាទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៣ នេះថា បពិត្រព្រះថេរដ៏ចម្រើនលោកម្ចាស់អាចដឹងថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គប្រសើរចម្លែកជាងបុគ្គលដទៃឬអ្វី ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះនាគសេនថេរថ្វាយព្រះពរថា អាម មហារាជ បពិត្រមហារាជ អាត្មាភាពដឹងថាព្រះដ៏មានព្រះភាគព្រះអង្គប្រសើរប្លែកលើសជនទាំងពួង ។

**ម. កថំ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ហេតុដូចម្តេចក៏លោកម្ចាស់ដឹងបានថា ព្រះសម្មាសម្ពុទ្ធនោះព្រះអង្គប្រសើរលើសជនទាំងពួង ។

**ន.** ចុះមហាបពិត្រស្តេចបានជ្រាបដែរឬ ថាមានព្រះថេរអង្គ ១ មាននាមថា តិស្សថេរ ជាអ្នកចេះដឹងនូវលេខ ហើយបានធ្វើជាអាចារ្យបង្ហាត់បង្រៀនលេខនោះ ដល់កូនសិស្សទាំងឡាយផង លោកក៏ធ្វើកាលកិរិយាកន្លងទៅយូរយារឆ្នាំណាស់ហើយ ៗ ព្រះថេរអង្គនោះគេតែងដឹងប្រាកដថាមានមែនព្រោះហេតុអ្វី មហារាជ ។

**ម. លេខេន ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ដែលគេបានដឹងប្រាកដថា មានព្រះថេរជាអាចារ្យចេះលេខមែននោះ ព្រោះអាចារ្យនោះលោកបានតែងបែបវិធីលេខនោះទុកមកដោយត្រឹមត្រូវ គួរគេជឿបាន ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រមហារាជ អ្នកឯណា ១ ដែលបានឃើញ បានដឹងនូវធម៌របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ហើយ អ្នកនោះឯងឈ្មោះថាបានដឹង បានស្គាល់នូវព្រះដ៏មានព្រះភាគប្រាកដដោយពិត ព្រោះថាព្រះបរិយត្តិធម៌នឹងព្រះនព្វលោកុត្តរធម៌នោះ គឺព្រះអង្គសម្ដែងទុកមកហើយដោយប្រពៃពិត ។

**ម.** លោកម្ចាស់វិសជ្ជនាមកនេះ ខ្ញុំបូលបិត្តអស់សង្ស័យហើយ ។

## ធម្មទិដ្ឋបញ្ហា ។ ទី ៤

ព្រះមហាក្សត្រស្ដេចទ្រង់បុច្ឆាចំពោះទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៤ នេះថា បពិត្រព្រះមហាថេរដ៏ចម្រើន ធម៌ដែលព្រះសម្មាសម្ពុទ្ធសម្ដែងទុកនោះ លោកម្ចាស់បានឃើញដូចម្ដេចទៅ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រមហារាជ ឯធម៌ដែលព្រះទសពលញាណ បានត្រាស់បញ្ញត្តទុកហើយ ។ អ្នក

ឯណាបានស្តាប់ ៗ បានហើយបានទីជាសាវក អ្នកនោះឯង ក៏អាចនឹងប្រតិបត្តិតាមធម៌នោះ ដរាបដល់អស់ជីវិតទៅ សូមទ្រង់ជ្រាប ។

**ម.** ព្រះថេរម្ចាស់ឆ្លៀវឆ្លាសពេកណាស់ បេះវិសជ្ជនាយ៉ាងខ្លីហើយងាយស្តាប់ គួរឱ្យអស់សង្ស័យ ។

## នបសង្កមតិបដិសន្ធិគបាណបញ្ហា ៗ ទី ៥

ព្រះមហាក្សត្រាធិរាជ ស្តេចទ្រង់ចោទសួរចំពោះទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៥ នេះថា បពិត្រព្រះនាគសេនថេរដ៏ចម្រើន សត្វទាំងពួងដែលស្លាប់អំពីនេះទៅហើយកើតទៀតនោះ ចំណែកវិញ្ញាណរបស់សត្វនោះមិនបានឈានចេញចាកខន្ធនេះ ទៅបដិសន្ធិកើតទៀតទេឬ លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា អាម មហារាជ បពិត្រសម្តេចមហារាជ ឯសត្វទាំងពួងដែលនឹងកើតទៀតនោះ ចំ-ណែកវិញ្ញាណរបស់សត្វនោះ មិនបានចេញចាកខន្ធនេះ ហើយឈានទៅបដិសន្ធិទៀតទេ មហាបពិត្រសូមទ្រង់ជ្រាប ។

**ម. កថំ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន បើវិញ្ញាណរបស់សត្វទាំងនោះ មិនបានឈានចេញពីខន្ធនេះទៅបដិសន្ធិទៀតទេ ចុះហេតុអ្វីក៏ពុទ្ធភាសិតទ្រង់សម្តែងថា សត្វស្លាប់ទៅតែងកើតជាធម្មតាតាមយថាកម្ម សេចក្តីនេះ ខ្ញុំមានកង្ខាក្រៃពេកណាស់ សូមលោកម្ចាស់ធ្វើនូវសេចក្តីឧបមាបន្តិចមកនឹងស្តាប់មើល ។

**ន. យថា មហារាជ** បពិត្រមហារាជ ឯវិញ្ញាណរបស់សត្វដែលនឹងបដិសន្ធិទៀតនោះ មិនបាច់ចាំចេញអំពីខន្ធនេះទៅស្វែងរកទីកើតទៀតទេ គឺគ្រាន់តែញោចឬឃាកបន្តិចទៅ ក៏អាចនឹងចាប់បដិសន្ធិកើតបានមួយរំពេចមិនយូរឡើយ ប្រៀបដូចជាអណ្តាតប្រទីប ដែលគេអុជចម្លងពីប្រទីបដើម ដែលមានប្រេងតិចជិតអស់នោះឯង មហារាជ បពិត្រសម្តេចមហារាជ អណ្តាតភ្លើងដែលគេអុជចម្លងពីប្រទីបដើមនោះ អណ្តាតភ្លើងដើមនោះ ជានឹងឆ្លងមកទាំងអស់បាកទីរបស់ខ្លួននោះមកឆេះឯប្រទីបថ្មីឯណោះទាំងអស់ឬអ្វី មហាបពិត្រ ។

**ម. ន ហិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន មិនមែនឆ្លងមកទាំងអស់ទេ គឺគ្រាន់តែប៉ះប្រធេះ និងអណ្តាតហើយក៏ឆេះឡើងបាន ឯអណ្តាតភ្លើងដើមដែលនឹងអស់ឬរលត់ទៅនោះ មិនមែនអស់ព្រោះតែគេអុជបម្លងនោះទេ គឺរលត់ពីព្រោះតែអស់ប្រេងម្យ៉ាងនោះឯង លោកម្ចាស់ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រសម្តេចមហារាជ សេចក្តីនេះប្រៀបដូចវិញ្ញាណរបស់សត្វដែលត្រូវកើតទៀតនោះ មិនបាច់ចាំបេញបាកខន្ធនេះឈានទៅកាន់ភពដទៃទេ តែគង់អាចនឹងចាប់យកបដិសន្ធិថ្មីទៀតបាន ដូចជាអណ្តាតភ្លើងដែលគេបន្តពីប្រទីបដើមនោះឯង ។

**ម. ភិយ្យោ ឧបមំ ករោហិ** សូមលោកម្ចាស់ឧបមាឱ្យច្រើនជាងនេះតទៅទៀតមើល ។

**ន. អភិជានាសិ មហារាជ** បពិត្រមហារាជ ព្រះអង្គកាលនៅជាព្រះរាជកុមារនៅឡើយនោះ ទ្រង់បានរៀនលេខឬអក្សរនិងស្លោកគាថាអ្វីខ្លះ ក្នុងសំណាក់អាចារ្យរបស់មហាបពិត្រដែរឬ ។

**ម. អាម ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំបានរៀន
សូត្របំណោះវិជ្ជាទាំងនោះដែរ ។

**ន. កិន្នុ ខោ មហារាជ** បពិត្រមហារាជ ចុះបំណោះទាំង
អស់មានលេខ និងស្លោកគាថាជាដើម ដែលមហាបពិត្របាន
រៀននោះ បំណោះទាំងនោះ នឹងឃានចេញហូរចេញអំពីមាត់
អាចារ្យ មកចូលក្នុងព្រះឱស្ឋរបស់មហាបពិត្រឬអ្វី ។

**ម. ន ហិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន ឯបំណោះវិជ្ជាទាំង
នោះមិនបានឃានចេញចាកមាត់លោកអាចារ្យ មកកាន់មាត់
ខ្ញុំទេ ប៉ុន្តែស្នូរសព្ទសម្លេងរបស់លោកអាចារ្យដែលប្រាប់បំ-
ណោះនោះ លាន់ឮប្រាកដមកដល់ត្រចៀកខ្ញុំ ហើយខ្ញុំក៏កត់
សម្គាល់នូវសព្ទសម្លេងនោះទុក ជាលេខជាស្លោកជាគាថាក្នុង
ចិត្តបាន សូមលោកម្ចាស់ជ្រាប ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រព្រះរាជសម្ភារ សេចក្តីនេះ
ប្រៀបដូចជាតួវិញ្ញាណដើមរបស់សត្វទាំងពួង មិនបានចេញ
ចាកខន្ធនេះទៅទេ តែវិញ្ញាណដែលជាផលឈ្មោះថា វិបាក

វិញ្ញាណនោះឯង តែងកាន់យកបដិសន្ធិក្នុងភពថ្មីទៀត សូមទ្រង់ជ្រាប ។

**ម. កល្លោសិ ភន្តេ** បពិត្រព្រះនាគសេនថេរដ៏ចម្រើន លោកម្ចាស់ពេញហៅឆ្លាសវាងវៃពេកណាស់ បេះវិសជ្ជនាប្រៀបឧ-បមាសេចក្ដីទូលាយងាយស្ដាប់ល្អណាស់ ខ្ញុំចូលចិត្តហើយ ។

## វេទគូបញ្ហា ។ ទី ៦

ព្រះមហាក្សត្រ ស្ដេចទ្រង់បុច្ឆាទៅព្រះថេរក្នុងប្រស្នាទី ៦ នេះថា បពិត្រព្រះនាគសេនថេរដ៏ចម្រើន សភាវៈដូចម្ដេចដែលហៅថា វេទគូ គឺកិរិយាធ្វើនូវសង្ខតធម៌និងអសង្ខតធម៌ទាំងពួងឲ្យប្រាកដហើយនោះឬអ្វី លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្ដេចមហារាជ ឯពាក្យថាវេទគូនោះ លោកមិនបានពោលដោយបរមត្ថវោហារទេ សូមមហាបពិត្រជ្រាប ។

**ម. កល្លោសិ** លោកម្ចាស់ឆ្លៀវឆ្លាសពេកណាស់ ។

## នមម្ហាកាយាអញ្ញំកាយំសំកមនបញ្ហា ។ ទី ៧

ព្រះបរមក្សត្រាធិរាជ ស្ដេចទ្រង់បុច្ឆាសួរទៅ ព្រះនាគ-

Websites: WatKhemaraRatanaram.org or WatKhmers.org

សេនបេរក្នុងប្រស្នាទី ៧ នេះថា បពិត្រព្រះនាគសេនដ៏ចម្រើន សត្វទាំងពួង វេលាដែលនឹងទំលាយខន្ធស្លាប់ទៅ នឹងមាន សភាពអ្វីនីមួយចេញពីកាយនេះ ទៅកាន់កាយដទៃទៀតដែរឬ ។ មិនមានទេ លោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ ឯសត្វទាំងពួងវេលាដែលធ្វើកាលកិរិយាទៅនោះ មិនមាន សភាពអ្វីនីមួយ ចេញចាកកាយនេះហើយទៅកាន់កាយដទៃ ទៀតទេ សូមមហាបពិត្រជ្រាប ។

**ម. យទិ ភន្តេ នត្ថិ** បពិត្រលោកម្ចាស់ដ៏ចម្រើន ថាបើសត្វ ទាំងពួងនោះវេលាដែលទំលាយខន្ធនេះហើយ មិនមានសភាព អ្វីនីមួយចេញពីកាយនេះ ទៅកាន់កាយឯទៀតទេនោះក៏ជាការ ស្រួលពេកណាស់ ព្រោះថាសត្វទាំងនោះនឹងបានរួចចាកបាប កម្មដែលខ្លួនធ្វើហើយក្នុងជាតិនេះ លោកម្ចាស់ ។

**ន. អាម មហារាជ** បពិត្រមហារាជ បើសត្វទាំងនោះ មិនបានកាន់យកបដិសន្ធិកើតទៀតទេ ក៏មុខជានឹងរួចចាក

បាបកម្មបាន ជាបើសត្វទាំងនោះនៅកាន់យកបដិសន្ធិកើតត ទៅទៀត មុខជាមិនរួចចាកបាបកម្មដ៏លាមកនោះឡើយ ។

**ម.** សូមលោកម្ចាស់ឧបមាបន្តិចមកមើល ។

**ន.** បពិត្រមហារាជ សេចក្តីនេះប្រៀបដូចបុរសណាមួយ បានទៅលួចបេះផ្លែស្វាយ របស់បុរសឯទៀតដែលជាម្ចាស់ស្វាយ បុរសដែលទៅលួចនោះនឹងត្រូវមានទោសទណ្ឌកម្មដែរ ឬមហារាជ ។

**ម.** បុរសដែលទៅលួចនោះត្រូវមានទោស លោកម្ចាស់ ។

**ន.** ហេតុដូចម្តេចក៏ត្រូវមានទោស បើបុរសដែលទៅលួចបេះផ្លែស្វាយនោះ គឺបេះតែផ្លែដែលនៅខាងចុងឯណោះទេ ត្រង់គ្រាប់ស្វាយដែលបុរសជាម្ចាស់ដាំនោះមិនបានយកទេ ចុះហេតុអ្វីក៏ត្រូវមានទោស ។

**ម.** បពិត្រលោកម្ចាស់ដ៏ចម្រើន ផ្លែស្វាយដែលផ្លែជាប់នឹងចុងនោះមិនមែនមកពីទីណាមកជាប់ទេ គឺផ្លែដែលចេញពីដើម ៗ ដែលដុះពីគ្រាប់ ៗ ដែលបុរសជាម្ចាស់ស្វាយគេដាំនោះ

ឯង លោកម្ចាស់ ហេតុនោះហើយបានជាបុរសដែលទៅលួច បេះយកផ្លែស្វាយនោះត្រូវមានទោស សូមលោកម្ចាស់ជ្រាប ។

ន. បពិត្រមហារាជ សេចក្តីនេះប្រៀបដូចបុគ្គលដែលធ្វើនូវកម្មជាកុសលក្តីជាអកុសលក្តីដោយនាមរូបនេះ គឺធ្វើបុណ្យក្តីធ្វើបាបក្តីក្នុងជាតិនេះ វេលាដល់ស្លាប់ទៅ មាននាមរូបដទៃដែលអាស្រ័យនូវផលបុណ្យឬផលបាបដែលខ្លួនសត្វបានសាងទុកក្នុងជាតិមុននោះ មកកាន់យកបដិសន្ធិកើតឡើងទៀតទៅដូច្នេះហើយបានជាសត្វដែលធ្វើបាបឬធ្វើបុណ្យក្នុងជាតិនេះ វេ-លាដល់ស្លាប់ទៅត្រូវទទួល សោយនូវផលបាបឬផលបុណ្យនោះមិនខានឡើយ សូមមហាបពិត្រស្តេចជ្រាប ។

ម. ខ្ញុំព្រះករុណាចូលចិត្តអស់សង្ស័យហើយ លោកម្ចាស់ ។

## កម្មផលអត្ថិភាវបញ្ហា ៗ ទី ៨

ព្រះមហាក្សត្រស្តេចទ្រង់មានព្រះរាជឱង្ការសួរទៅព្រះនាគ-សេនថេរក្នុងប្រស្នាទី ៨ នេះថា បពិត្រព្រះនាគសេនដ៏ចម្រើន កុសលកម្មក្តីអកុសលកម្មក្តី ដែលបុគ្គលបានធ្វើហើយដោយ

នាមរូបនេះ ចុះអំពើកុសលនិងអកុសលទាំងនោះ តើនឹងទៅស្ថិតទៅតម្កល់ក្នុងទីដូចម្តេច លោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រព្រះរាជសម្ភារ ឯអំពើកម្មជាកុសលឬអកុសលទាំងនោះ មិនមែននឹងឃ្លាតចេញពីខ្លួនសត្វហើយទៅស្ថិតនៅក្នុងទីដទៃទេ គឺកម្មទាំងនោះតែងជាប់ចំពោះតាមខ្លួនសត្វ មិនដែលលះបង់គ្នា ប្រៀបដូចស្រមោលដែលតែងប្រព្រឹត្តប្រកិតទៅតាមរូបនោះឯង សូមជ្រាប ។

**ម. សក្កា បន ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន ចុះអំពើកុសលអកុសលទាំងឡាយ ដែលជាប់ទៅជាមួយនឹងខ្លួនសត្វនោះ បុគ្គលនឹងអាចចង្អុលបង្ហាញគ្នា ជាកុសលកម្មនោះនៅត្រង់នេះ អកុសលកម្មនោះស្ថិតនៅត្រង់ទីនោះដូច្នេះ ជាបានឬពុំបានទេ លោកម្ចាស់ ។

**ន. ន សក្កា មហារាជ** បពិត្រមហារាជ ឯអំពើកម្មទាំងនោះនឹងរកបុគ្គលឯណាអាចចង្អុលបង្ហាញគ្នាថា នៅត្រង់ទីនោះឬនៅត្រង់ទីនេះ ពុំបានទេ មហាបពិត្រ ។

**ម.** សូមលោកម្ចាស់ឱបមាបន្តិចមកមើល ។

**ន. តំ កឹ មញ្ញសិ មហារាជ** បពិត្រមហារាជ សេចក្ដីនេះ ព្រះអង្គនឹងទ្រង់ជ្រាបដូចម្ដេចទៅ អាត្មាភាពសូមថ្វាយព្រះពរ ថា រុក្ខជាតិទាំងពួងដែលមិនទាន់មានផ្លែក្ដិបចេញមកខាងក្រៅ នៅឡើយ ចុះបំណែកបុគ្គលទាំងឡាយ នឹងអាចចង្អុលបង្ហាញ ប្រាប់គ្នាថា ផ្លែឈើទាំងអស់នោះស្ថិតនៅត្រង់ទីនេះ ឬត្រង់ទី នោះ យ៉ាងនេះជាបានឬពុំបាន មហារាជ ។

**ម.** មិនបានទេ លោកម្ចាស់ ។

**ន.** បពិត្រព្រះរាជសម្ភារ ឯផ្លែបុណ្យនឹងផ្លែឈើនោះមាន កិរិយាប្រព្រឹត្តទៅប្រហែល ៗ គ្នា ម្យ៉ាងទៀតឯខ្សែបុណ្យឬខ្សែ បាបនោះ មិនបានស្ថិតនៅនឹងជដែល ៗ តែមួយកន្លែងនោះទេ គឺតែងប្រព្រឹត្តទៅហូរទៅរឿយ ៗ ជានិច្ចតាមពេលតាមសម័យ របស់សត្វដែលបានធ្វើ អ្នកឯណាមួយនឹងអាចកំណត់ថា ផលបុណ្យឬផលបាបនោះតែងស្ថិតនៅ តែត្រង់ទីនេះកន្លែងនេះ ម្យ៉ាង ដូច្នោះនោះពុំបានទេ ។

**ម.** លោកម្ចាស់ឆ្លាសពេកណាស់ បេះប្រៀបឧបមាគួរឱ្យចូលចិត្តស្តាប់បាន អស់សេចក្តីសង្ស័យ ។

## ឧប្បជ្ជនជាននបញ្ហា ១ ទី ៩

ព្រះបាទមិលិន្ទភូមិន្ទ្រាធិបតី ស្តេចទ្រង់បុច្ឆាចំពោះទៅព្រះនាគសេនថេរ ក្នុងប្រស្នាទី ៩ នេះថា បពិត្រព្រះថេរដ៏ចម្រើន សត្វឯណាដែលត្រូវការកើតទៀត សត្វនោះនឹងអាចដឹងថា អាត្មាអញត្រូវកើតទៀតដូច្នេះឬអ្វី លោកម្ចាស់ ។

ព្រះថេរថ្វាយព្រះពរថា យ៉ាងហ្នឹងហើយមហារាជ សត្វឯណាដែលត្រូវកើតឡើងទៀត សត្វនោះតែងដឹងថា អាត្មាអញគង់នឹងកើតទៀតមិនខាន ។

**ម.** សូមលោកម្ចាស់ប្រៀបជាសេចក្តីបន្តិចមកមើល ។

**ន.** បពិត្រមហារាជ អាត្មាភាពសូមថ្វាយព្រះពរថា គហបតីអ្នកស្រែ ដែលបានព្រោះដាំពូជទៅលើផែនដីហើយ ៗ ក្នុងវេលាឆ្នាំនោះ ក៏ទទួលមានភ្លៀងធ្លាក់ចុះមកស្រួលផង បំណែកអ្នកស្រែនោះនឹងអាចដឹងថា ស្រូវរបស់អញមុខជានឹងកើតបម្រើនឡើងមិនខានដូច្នេះឬ មហាបពិត្រ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ម.** យ៉ាងហ្នឹងហើយលោកម្ចាស់ អ្នកស្រែនោះនឹងបួលបិត្តថា ស្រូវរបស់ខ្លួននោះមុខជានឹងដុះឡើងបម្រើនឡើងតាមលំដាប់មិនខាន ។

**ន.** បពិត្រព្រះបរមក្សត្រាធិរាជ សេចក្តីនេះប្រៀបដូចជាបុគ្គលឯណា ១ ដែលមុខជានឹងកើតទៀតនោះ បុគ្គលនោះឯងគង់នឹងដឹងថាខ្លួនអាត្មាអញមុខជានឹងកើតទៀតមិនខាន ដូច្នេះឯង ។

**ម.** បួលបិត្តហើយលោកម្ចាស់ ៗ ឆ្លៀវឆ្លាសពេកណាស់ ។

## ពុទ្ធនិទស្សនបញ្ហា ។ ទី ១០

ព្រះបាទមិលិន្ទ្រាធិរាជ ទ្រង់បុច្ឆាសួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ១០ នេះថា បពិត្រព្រះនាគសេនដ៏បម្រើន ព្រះសម្មា-សម្ពុទ្ធនោះមានមែនឬអ្វី លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រព្រះរាជសម្ភារសម្តេចព្រះភគវន្តមុនីនោះប្រាកដជាមានមែន មបារាជ ។

**ម.** បើព្រះសម្ពុទ្ធមានមែន ចុះលោកម្ចាស់នឹងអាចបង្ហាញ

Websites: WatKhemaraRatanaram.org or WatKhmers.org

ខ្ញុំថា ព្រះសម្ពុទ្ធព្រះអង្គគង់នៅត្រង់ទីនេះ កន្លែងនេះដូច្នេះបានឬទេ ។

**ឥ. បរិនិព្វុតោ មហារាជ** បពិត្រមហារាជ ព្រះដ៏មានព្រះភាគនោះ ឥឡូវនេះព្រះអង្គចូលបរិនិព្វាន ដោយអនុបាទិ-សេសនិព្វានធាតុទៅហើយ អាត្មាភាពមិនអាចនឹងបង្ហាញមហាបពិត្រថា ព្រះបរមសាស្តាស្តេចគង់នៅត្រង់នេះ ទីឯនេះបានឡើយ ។

**ម.** បើលោកម្ចាស់បង្អុលបង្ហាញមិនបាន សូមលោកម្ចាស់ធ្វើនូវសេចក្តីឧបមានុបមេយ្យបន្តិចមកមើល ។

**ឥ.** បុះហេតុនេះ មហាបពិត្រស្តេចទ្រង់ជ្រាបដូចម្តេចទៅអេះ អាត្មាភាពសូមថ្វាយព្រះពរថា អណ្តាតភ្លើងធំឯណាដែលរលំរលត់បាត់ទៅហើយ អណ្តាតភ្លើងនោះ បុគ្គលនឹងអាចបង្អុលបង្ហាញគ្នាថា អណ្តាតភ្លើងនោះស្ថិតនៅត្រង់ទីនេះ ទីឯនេះដូច្នេះបានឬអ្វី មហារាជ ។

**ម.** មិនបានទេលោកម្ចាស់ ព្រោះអណ្តាតភ្លើងដែលរលាយរលត់បាត់ទៅហើយនោះ នឹងរកបញ្ញត្តិពុំមានឡើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

ន. បពិត្រព្រះរាជសម្ភារ អណ្ដាតភ្លើងដែលរលត់បាត់រស្មីទៅហើយនោះយ៉ាងណាមិញ ឯព្រះដ៏មានព្រះភាគដែលព្រះអង្គចូលបរិនិព្វានទៅហើយនោះក៏ដូច្នោះដែរ មិនអាចនឹងរកបុគ្គលឯណា នឹងចង្អុលបង្ហាញគ្នាបានឡើយ តែឯត្រង់ព្រះធម៌ដែលជាភាសិត របស់ព្រះអង្គនោះ អាត្មាភាពនឹងអាចចង្អុលបង្ហាញថ្វាយមហាបពិត្របាន ។

ម. លោកម្ចាស់វិសជ្ជនាមកនេះ គួរឱ្យខ្ញុំមានសេចក្ដីសោមនស្សត្រេកអរពេកណាស់ ខ្ញុំអស់សង្ស័យហើយ ។

ចប់វគ្គជាគម្រប់ ៥ តែប៉ុណ្ណោះ

## ឆដ្ឋមវគ្គ មានប្រស្នា ១១

## កាយអប្បិយបញ្ហា ។ ទី ១

ព្រះបាទមិលិន្ទភូមិន្ទ្រាធិបតី ស្ដេចទ្រង់មានព្រះរាជឱង្ការត្រាស់សួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ១ ក្នុងវគ្គទី ៦ នេះថា បពិត្រព្រះនាគសេនដ៏ចម្រើន រូបកាយនេះជាទីស្រឡាញ់របស់អ្នកបួសទាំងឡាយឬដូចម្ដេច លោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ ឯរាងកាយនោះ មិនមែនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកបួសទាំងពួងទេ ។

**ម. កិស្ស នុ ខោ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន រាងកាយនេះបើមិនមែនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកបួសទាំងនោះទេ ចុះហេតុអ្វីក៏អ្នកបួសទាំងអស់នោះបេះតែថែរក្សា រាប់អានទំនុកបំរុងរូបកាយនោះមិនបោះបង់ចោល ។

**ន. អត្ថិ បន មហារាជ** បពិត្រមហារាជា អាត្មាភាពសូមថ្វាយព្រះពរសួរមហាបពិត្រវិញថា ចំណែកខាងយោធាទាហានដែលចូលទៅកាន់ទីសង្គ្រាមតទល់គ្នានឹងបច្ចាមិត្រ តើយោធាទាំងនោះនឹងដែលត្រូវមុតដោយចុងព្រួញ ឬដោយចុងលំពែងខ្លះដែរឬ មហារាជ ។

**ម. អាម ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន ឯយោធាទាហានដែលចូលទៅកាន់ទីគយុទ្ធគ្នានឹងសត្រូវហើយ មិនលែងនឹងមុតដោយចុងព្រួញឬចុងលំពែងនោះទេ លោកម្ចាស់ ។

**ន. កឹ នុ ខោ មហារាជ** បពិត្រមហារាជ ចុះយោធាដែលមានដំបៅរបួសដោយមុខព្រួញ ឬមុខលំពែងនោះតើនឹងត្រូវធ្វើដូចម្ដេច ជានឹងត្រូវបំពោកដោយថ្នាំសម្រាប់បំពោក ឬត្រូវលាបដោយថ្នាំសម្រាប់លាប និងរុំដោយសំពត់មានសាច់ដ៏ល្អិតសម្រាប់រុំនោះដែរឬ មហារាជ ។

**ម. អាម ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន ឯយោធាដែលមានរបួសនោះ មិនអាចនឹងសម្ងំនៅស្ងៀមបានឡើយ មុខជានឹងខំស្វះស្វែងរកថ្នាំមកបំពោក រកប្រេងមកលាប រកសំពត់មករុំរក្សានូវមុខដំបៅនោះមិនខានទេ លោកម្ចាស់ ។

**ន. កឹ នុ ខោ មហារាជ** បពិត្រមហារាជ ចុះយោធាទាហានដែលមានរបួសដំបៅហើយ ខំស្វែងរកថ្នាំមកបំពោករកប្រេងមកលាប រកសំពត់មករុំរក្សាទុកនូវដំបៅនោះ តើយោធា-ទាហានទាំងឡាយនោះ ជានឹងមានអាណិតស្រឡាញ់រាប់អានដំបៅនោះដែរឬអ្វី មហាបពិត្រ ។

**ម. ន ខោ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ឯដំបៅនោះ

មិនមែនជាទីស្រឡាញ់របស់យោធាទាំងនោះទេ តែឯកិច្ចដែលយោធាទាហានទាំងអម្បាលនោះ ខំស្វែងរកថ្នាំមកលាបលាងនូវដំបៅទាំងនោះព្រោះតែនឹងឱ្យដំបៅទាំងនោះឆាប់សះឆាប់ជាឱ្យបានជុះសាច់ឡើងជាថ្មីវិញ ដើម្បីឱ្យផុតសេចក្ដីវេទនាដែលកើតឡើងអំពីដំបៅនោះប៉ុណ្ណោះទេ នឹងមានត្រូវការអ្វីដោយដំបៅនោះមិនមានឡើយ លោកម្ចាស់ ។

**៩. ឯវមេវ ខោ មហារាជ** បពិត្រសម្ដេចមហារាជ ឯរបួសដំបៅមិនជាទីស្រឡាញ់របស់យោធាទាហាន យ៉ាងណាមិញរាងកាយក៏មិនជាទីស្រឡាញ់របស់អ្នកបួសយ៉ាងនោះដែរ ឯលោកអ្នកបួសទាំងឡាយ បានជាជាប់ដោយកិច្ចរក្សាថែទាំនូវរាងកាយនេះ ព្រោះតែនឹងសង្គ្រោះដល់ព្រហ្មចារិយសីលម្យ៉ាងប៉ុណ្ណោះ ។ ១ វិញទៀតឯរាងកាយនេះ ព្រះបរមសាស្ដាចារ្យជាគ្រូ ទ្រង់សម្ដែងឧបមារាងកាយនេះ ថាដូចជាមុខបួសមុខដំបៅទេ ហេតុដូច្នេះហើយបានជាអ្នកបួសទាំងឡាយ តាំងចិត្តថែរក្សានូវរាងកាយនេះ ដូចគ្នានឹងយោធាទាហាន ដែល

រក្សានូវដំបៅនោះ ។ បពិត្រមហារាជ សេចក្ដីនេះដូចគ្នាឬ ត្រូវគ្នានឹងភាសិតរបស់ព្រះទសពលញាណ ដែលទ្រង់ប្រោសប្រទានជាបទគាថានេះទុកមកថា

**អល្លចម្មបដិច្ឆន្នោ  នវទ្វារោ មហាវណោ**
**សមន្តតោ បគ្ឃរតិ  អសុចិ បូតិគន្ធិកោតិ ។**

សេចក្ដីថា សម្ដេចព្រះអនាវរណញ្ញាណទ្រង់ប្រោសប្រទានព្រះធម្មទេសនានេះថា នែភិក្ខុទាំងឡាយ ឯរាងកាយរបស់សត្វនេះ មានស្បែកស្រស់បិទបាំងជិតជុំវិញ, មានទ្វារទាំង ៩ ប្រការសម្រាប់ហូរហៀរចេញនូវវត្ថុមិនស្អាត មានក្លិនដ៏ស្អុយ ប្រៀបដូចជាមុខដំបៅដ៏ធំ ដែលជាទីហូរហៀរចេញនូវវត្ថុស្មោកគ្រោកគ្រប់ប្រការ គួរជាទីខ្ពើមរអើមពេក ពុំគួរស្នេហាឡើយ បពិត្រព្រះរាជសម្ភារ សេចក្ដីដែលអាត្មាភាពពោលមកនេះ ពិតជាពុទ្ធភាសិតហើយ សូមមហារាជជ្រាប ។

**ម. កល្លោសិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ឆ្លៀវឆ្លាសពេកណាស់ បេះវិសជ្ជនាពីរោះស្រួលស្ដាប់ អស់សង្ស័យហើយ ។

## សម្បត្តកាលបញ្ហា ។ ទី២

ព្រះបាទមិលិន្ទភូមិន្ទ្រភូមិបាល ស្តេចទ្រង់បុច្ឆាចំពោះទៅព្រះនាគសេនថេរថា បពិត្រព្រះនាគសេនដ៏បម្រើន ពុទ្ធោ រីព្រះ-សម្មាសម្ពុទ្ធជាម្ចាស់ សព្វញ្ញូ ជាអ្នកដឹងនូវហេតុទាំងពួងគ្រប់-យ៉ាង សព្វទស្សាវី មានប្រក្រតីឃើញនូវហេតុទាំងពួងគ្រប់យ៉ាងឬអ្វី លោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា បពិត្រមហារាជ ព្រះសព្វញ្ញុតញ្ញាណ ព្រះអង្គជាសព្វញ្ញូ ជាសព្វទស្សាវី តែងដឹងតែងឃើញនូវហេតុទាំងពួងគ្រប់យ៉ាងឥតមានបន្លោះឡើយ ។

**ម.** បពិត្រលោកម្ចាស់ដ៏បម្រើន បើព្រះសម្ពុទ្ធព្រះអង្គតែងដឹងហេតុគ្រប់យ៉ាងហើយ ហេតុអ្វីក៏ព្រះអង្គមិនទ្រង់បញ្ញត្តសិក្ខា-បទ ដល់ភិក្ខុទាំងឡាយដែលជាសាវ័កព្រះអង្គនោះ តាមលំ-ដាប់ជាមុនទៅ ក៏បង្អង់ចាំឱ្យភិក្ខុទាំងឡាយនោះ ធ្វើខុសជ្រុលទៅហើយ ទើបទ្រង់បញ្ញត្តហាមប្រាមជាខាងក្រោយវិញ ។

**ន. អត្ថិ បន មហារាជ** បពិត្រមហារាជ ចុះលើផែនដីនេះ

នឹងមានមនុស្សឯណា ជាអ្នកអាចដឹងនូវថ្នាំជាភេសជ្ជៈ សម្រាប់រំងាប់នូវរោគាព្យាធិរបស់មនុស្សក្នុងលោកនេះដែរឬព្រះអង្គ ។

**ម. អត្ថិ ភន្តេ** បពិត្រលោកម្ចាស់ដ៏បម្រើន ឯគ្រូពេទ្យនោះមានក្នុងលោកនេះច្រើន ។

**ន. កឹ នុ ខោ** មហារាជ បពិត្រមហារាជ ចុះគ្រូពេទ្យនោះនឹងផ្សំថ្នាំឱ្យមនុស្ស ដែលមិនទាន់មានរោគាព្យាធិមួយមកបៀតបៀននោះផឹកជាមុនឬ ។ ឋាលុះតែមានរោគមកពាល់ត្រូវហើយទើបឱ្យផឹក ។

**ម. សម្បត្តេ ភន្តេ** បពិត្រលោកម្ចាស់ដ៏បម្រើន ឯគ្រូពេទ្យនោះត្រូវឱ្យថ្នាំមនុស្សផឹក ក្នុងវេលាដែលមានរោគមកពាល់ត្រូវហើយទើបគួរនឹងឱ្យផឹក បើមិនទាន់មានជម្ងឺអ្វីទេនឹងមានកិច្ចអ្វីដោយផឹកថ្នាំ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រមហារាជ សេចក្ដីនេះមានឧបមាយ៉ាងណាមិញឋា ឧបមេយ្យដូចអង្គព្រះសព្វញ្ញុត-ញ្ញាណ ដែលព្រះអង្គជាសព្វញ្ញូជាអ្នកដឹងនូវហេតុគ្រប់យ៉ាង

ហើយទ្រង់មិនបញ្ញត្តនូវសិក្ខាបទ ដល់ភិក្ខុជាសាវ័កដែលមិនទាន់មានហេតុគួរនឹងបញ្ញត្ត លុះតែភិក្ខុជាសាវ័កឯណា ១ ប្រព្រឹត្តជ្រុលហួសគន្លងធម៌ទៅហើយ ទើបទ្រង់បញ្ញត្តសិក្ខាបទហាមប្រាមជាខាងក្រោយ ដូចគ្នានឹងគ្រូពេទ្យនោះឯង សូមមហារាជជ្រាប ។

**ម.** បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ឆ្លៀវឆ្លាសពេកណាស់ បេះវិសជ្ជនាស្រួលបួលគួរឱ្យចូលចិត្តស្ដាប់បាន ។

## ទូត្តិសមហាបុរិសលក្ខណបញ្ហា ។ ទី ៣

ព្រះបាទមិលិន្ទនរិន្ទរាជទ្រង់បុច្ឆាចំពោះទៅព្រះនាគសេនថេរថា បពិត្រព្រះនាគសេនថេរដ៏ចម្រើន ពុទ្ធោ រឺព្រះបរមសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ ប្រការ និងអនុព្យញ្ជនៈទាំង ៨០ ប្រការ ហើយទ្រង់មានព្រះឆវីវណ្ណដ៏បរិសុទ្ធិភ្លឺផ្លេកយ៉ាងស្និទ្ធដ៏វិចិត្រដូចមាសដែលបុគ្គលបិទយ៉ាងល្អ និងពណ៌សម្បុរដ៏ឆ្អិនឆ្អៅដូចជាពណ៌សម្បុរនៃសុវណ្ណ គួរជាទីតម្រេកត្រេកអរហើយទ្រង់មានពន្លឺរស្មីផ្សាយ

បេញពីព្រះអង្គជានិច្ចមានប្រមាណ ១ ព្យាម ដូច្នេះមែនឬមិនមែន លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា អាម មហារាជ បពិត្រសម្តេចមហារាជ វីសម្តេចព្រះភគវន្តមុនី ព្រះអង្គទ្រង់ប្រកបដោយលក្ខណៈគ្រប់យ៉ាង ដូចព្រះរាជឱង្ការដែលទ្រង់រៀបរាប់មកនេះឯងដោយពិត ។

**ម. កិស្ស បន ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន បើអង្គព្រះសម្មាសម្ពុទ្ធប្រាកដជាមានសេចក្តីលំអដូច្នោះហើយ ប្រ-ហែលជាព្រះវររាជមាតាបិតារបស់ព្រះអង្គសោត ក៏នឹងមានទ្វត្តិ-សមហាបុរិសលក្ខណៈនិងអសីត្យានុព្យញ្ជនៈ ព្រមទាំងពណ៌សម្បុរល្អនិងមានពន្លឺរស្មីផ្សាយចេញពីអង្គមាតាបិតានោះដូចជាព្រះអង្គដែរឬអ្វី ។

**ន. ន ហិ មហារាជ** បពិត្រសម្តេចមហារាជ ឯព្រះវររាជមាតានិងព្រះវររាជបិតារបស់ព្រះសម្មាសម្ពុទ្ធនោះមិនមែនមានលក្ខណៈគ្រប់យ៉ាងដូចព្រះអង្គទេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ម.** បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះហេតុអ្វីព្រះបរមសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់កើតឡើងអំពីមាតាបិតារបស់ព្រះអង្គ ត្រង់តួព្រះអង្គឯងទ្រង់បរិបូណ៌ដោយព្រះមហាបុរិសលក្ខណៈនិងអសីត្យានុព្យញ្ជនៈព្រមទាំងព្រះសុវណ្ណពណ៌ និងព្រះកាញ្ចនឆវីវណ្ណ និងរស្មីចេញពីព្រះអង្គផង ប្លែកឆ្ងាយពីព្រះមាតាបិតារបស់ព្រះអង្គ ឯព្រះមាតាបិតារបស់ព្រះអង្គក៏ជាមនុស្សដូចធម្មតាម្យ៉ាងទៀតធម្មតាកូនតែងកើតអំពីមាតានិងបិតា លុះកើតមកហើយបើមិនដូចមាតាក៏គង់ដូចបិតា បើមិនដូចបិតាក៏គង់ប្រហែលទៅមាតាវិញមិនខាន ក៏មកឃើញចំឡែកប្លែកតែត្រង់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នេះ ព្រះអង្គមិនដូចមាតាមិនដូចបិតាទាំងពីរខាង ។

**ន. អត្ថិ បន មហារាជ** បពិត្រព្រះរាជសម្ភារ សូមទ្រង់ព្រះរាជអភ័យទោស អាត្មាភាពសូមថ្វាយព្រះពរសួរមហាបពិត្រថា ចុះដូចជាផ្កាបទុមក្ដី ផ្កាសត្តបុស្សក្ដី ផ្កាឧប្បលក្ដី ផ្កាកុមុទក្ដី ផ្កាឈូកសក្ដី ជាតិផ្កាទាំងនោះតែងកើតមាន ឬមិនមានទេមហាបពិត្រ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ម. អត្ថិ ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន ឯបុប្ផជាតិទាំងនោះតែងកើតមានដោយពិត វេលាដែលនឹងកើតនោះ គឺអាស្រ័យនូវទឹកនិងដីហើយទើបកើតឡើងបានលោកម្ចាស់ ។

**ន. កឹ នុ ខោ មហារាជ** បពិត្រមហារាជ ចុះបុប្ផជាតិទាំងនោះវេលាដែលកើតឡើង ត្រូវអាស្រ័យនូវទឹកនិងដីហើយទើបកើតឡើងបាន បើដូច្នេះបុប្ផជាតិទាំងនោះគង់មានពណ៌សម្បុរមានក្លិនក្លែបមានរសជាតិដូចទឹកឬដូចដីមិនខាន ឬដូចម្តេច ។

**ម. ន ហិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន មិនមែនដូច្នោះទេ ឯបុប្ផជាតិទាំងនោះតែងប្រព្រឹត្តទៅតាមជាតិដើមរបស់ខ្លួនគ្រប់ជាតិ មិនបានមានពណ៌សម្បុរឬរសជាតិដូចទឹក ឬដូចដីនោះទេ ។

**ន.** បពិត្រមហារាជ បើបុប្ផជាតិទាំងនោះមិនមានពណ៌សម្បុរដូចទឹកដូចដី ប្រហែលជាមានពណ៌ មានក្លិន មានរសដូចដីភក់ឬអ្វីមហាបពិត្រ ។

**ម. ន ហិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ឯបុប្ផជាតិ

ទាំងនោះនឹងថាមានពណ៌មានក្លិន មានរសដូចដីភក់នោះក៏មិនមែនដែរ ។

**ឥ. ឯវមេវ ខោ មហារាជ** បពិត្រមហារាជ ឯសម្ដេចព្រះភគវន្តមុនីសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គតែងមានព្រះរូបព្រះឆោមប្រកបដោយទ្វត្តឹសមហាបុរិសលក្ខណៈ និងអសីត្យានុព្យញ្ជនៈព្រមទាំងសុវណ្ណពណ៌និងព្រះកាញ្ចនធវីវណ្ណ និងព្រះរស្មីប្រមាណ ១ ព្យាមចេញពីព្រះអង្គដោយពិត ព្រោះទ្រង់បានសាងសន្សំបន្សំព្រះបារមីមកជាច្រើនជាតិ បំណែកខាងព្រះវរៈរាជជននីនិងព្រះវររាជបិតាព្រះអង្គនោះ ទ្រង់មិនបានប្រកបដោយសេចក្ដីលំអទាំងឡាយ មានទ្វត្តឹសមហាបុរិសលក្ខណៈជាដើមនោះ ព្រោះព្រះមាតានិងព្រះបិតារបស់ព្រះអង្គ ទ្រង់សាងសន្សំព្រះបារមីនោះតិចជាងព្រះបរមគ្រូ សូមមហាបពិត្រស្ដេចជ្រាប ។

**ម. កល្លោសិ** លោកម្ចាស់ឆ្លៀវឆ្លាសពេកណាស់ ។

## ព្រហ្មចារីបញ្ហា ។ ទី ៤

ព្រះបរមក្សត្រាធិរាជ ព្រះអង្គទ្រង់ព្រះរាជបុច្ឆាសួរទៅព្រះ-

Websites: WatKhemaraRatanaram.org or WatKhmers.org

នាគសេនថេរក្នុងបញ្ហានេះថា   បពិត្រព្រះនាគសេនដ៏ចម្រើន ពុទ្ធោ  ព្រហ្មចារី  រឺព្រះសម្ពុទ្ធជាម្ចាស់ព្រះអង្គទ្រង់ប្រព្រឹត្តនូវធម៌ ដូចជាព្រហ្មឫអ្វី លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរទៅវិញថា  បពិត្រសម្តេច មហារាជ ភគវា ព្រហ្មចារី រឺព្រះបរមភគវន្ត ព្រះអង្គតែងប្រព្រឹត្ត នូវធម៌ដូចព្រហ្មមែន សូមមហាបពិត្រជ្រាប ។

**ម. ពុទ្ធោ ព្រហ្មុនោ សិស្សោ** បពិត្រព្រះនាគសេនដ៏ចម្រើន បើព្រះសម្មាសម្ពុទ្ធព្រះអង្គប្រព្រឹត្តនូវធម៌ដូចជាព្រហ្ម   មានតែ ព្រះអង្គត្រូវជាសិស្សគណនៃព្រហ្មឬអ្វី លោកម្ចាស់ ។

**ន. អត្ថិ តេ មហារាជ** បពិត្រសម្តេចមហារាជ ប្រហែលជា ព្រះអង្គស្តេចទ្រង់មានដំរីមង្គលជាប្រធាននៃដំរីធំទាំងពួងដែរឬ ដូចម្តេចព្រះអង្គ ។

**ម. អាម ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន ឯដំរីជាមង្គល នោះខ្ញុំម្ចាស់ធ្លាប់មានជាច្រើនហើយ សូមព្រះថេរជ្រាប ។

**ន.កិន្នុ ខោ មហារាជបពិត្រមហារាជ** បុះដំរីនោះដែលវានឹង ស្រែកបន្លឺឡើងនូវសំឡេងដូចជាសំឡេងនៃបក្សីក្រៀលដែរឬ ។

**ម. អាម ភន្តេ** បពិត្រព្រះនាគសេនដ៏បម្រើន ឯដំរីមង្គល នោះវាតែងបន្លឺឡើង នូវសំឡេងដូចជាសំឡេងនៃសត្វក្រៀលដែរ លោកម្ចាស់ ។

**ន. ហត្ថិ កោញ្ចស្ស សកុណស្ស សិស្សោ** បពិត្រមហារាជ បើដំរីនោះវាបន្លឺឡើងនូវសំឡេងដូចសំឡេងនៃសត្វក្រៀល ប្រ-ហែលជាដំរីនោះត្រូវជាសិស្សរៀនសូត្រអំពីសំណាក់នៃក្រៀល មកឬអ្វីព្រះអង្គ ។

**ម. ន ហិ ភន្តេ** បពិត្រព្រះនាគសេនដ៏បម្រើន ឯដំរីនោះមិនមែនជាសិស្សគណាអ្វីនៃក្រៀលនោះទេ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រសម្តេចមហារាជ ឯដំរីវេលាដែលនឹងស្រែកឡើងមានសម្រែកដូចជាសម្រែកនៃក្រៀល តែមិនមែនជាសិស្សគណាក្រៀលនោះទេ ដូចគ្នានឹងព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គតែងប្រព្រឹត្តនូវធមិដូចព្រហ្មក៏ពិតមែន តែព្រះអង្គមិនមែនជាសិស្សគណាអ្វីនៃព្រហ្មនោះទេ ម្យ៉ាងទៀត អាត្មាភាពសូមថ្វាយព្រះពរមហាបពិត្រថា សំពុទ្ធិកោ ចុះព្រហ្ម

នោះជាអ្នកត្រាស់ដឹងនូវធម៌ដោយខ្លួនឯងដែរឬ ។ មិនមែនត្រាស់ដឹងទេ ។

**ម. អសំពុទ្ធោ** បពិត្រព្រះនាគសេនដ៏បម្រើន ព្រហ្មនោះមិនមែនជាអ្នកត្រាស់ដឹងនូវធម៌អ្វីដោយខ្លួនឯងទេ លោកម្ចាស់ ។

**ន. ព្រហ្មា ភគវតោ សិស្សោ** បពិត្រមហារាជ បើព្រហ្មមិនបានត្រាស់ដឹងនូវធម៌ដោយខ្លួនឯងទេ ព្រហ្មនោះថាជាសិស្សនៃព្រះដ៏មានព្រះភាគវិញទើបសមមហារាជ ។

**ម. កល្លោសិ** លោកម្ចាស់ឆ្លៀវឆ្លាសពេកណាស់ ។

## ឧបសម្បន្នបញ្ហា ។ ទី ៨

ព្រះបាទមិលិន្ទ្រាធិបតី ស្តេចទ្រង់ព្រះរាជបុច្ឆាសួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៨ នេះថា បពិត្រព្រះនាគសេនដ៏បម្រើន បុគ្គលដែលមានឧបសម្បទនោះល្អឬ ។ បុគ្គលដែលមិនមានឧបសម្បទនោះល្អលោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ អ្នកដែលមានឧបសម្បទនោះទើបល្អព្រះអង្គ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ម.** បពិត្រព្រះនាគសេនដ៏បម្រើន បុះព្រះសម្មាសម្ពុទ្ធព្រះ-អង្គមានឧបសម្បទឬមិនមាន ។

**ន. ឧបសម្បន្នោ ខោ ភគវា** បពិត្រសម្តេចមហារាជ វីព្រះ-ដ៏មានព្រះភាគ ព្រះអង្គទ្រង់មានឧបសម្បទបរិបូណ៌ពេកណាស់ សូមទ្រង់ជ្រាប ។

**ម. សុណន្តុ ភោន្តោ** ម្នាលអ្នកយោនកាមាត្យទាំងឡាយ ចូរអ្នកទាំងឡាយចាំស្តាប់នូវពាក្យនៃខ្ញុំឱ្យច្បាស់លាស់ ខ្ញុំនឹងប្រាប់អ្នករាល់គ្នាឱ្យស្តាប់បាន ត្បិតព្រះនាគសេនអង្គនេះ លោកបានពោលពាក្យថាដូច្នេះ ថាសម្តេចព្រះដ៏ទ្រង់ព្រះភាគព្រះអង្គជាឧបសម្បន្នដ៏បរិបូណ៌ពេញលេញ ឥឡូវនេះខ្ញុំនឹងសួរលោកម្ចាស់ឱ្យជាក់ច្បាស់ក្នុងរឿងនេះថា បពិត្រព្រះនាគសេនដ៏បម្រើន បុះព្រះសមណគោតម ដែលលោកបានឧបសម្បទពេញលេញ ជាអ្នកបួសប្រាកដនោះ តើអ្នកណាជាអាចារ្យបំបួសលោក អ្នកណាជាព្រះឧបជ្ឈាយ៍ទទួលដឹងការខុសត្រូវឱ្យលោក ហើយមានគណៈសង្ឃប៉ុន្មានអង្គ ជាអ្នកឱ្យឧបសម្បទដល់សមណគោតមនោះ ។

**ត. នត្ថិ មហារាជ** បពិត្រសម្តេចមហារាជ រីអាចារ្យក្តី ព្រះឧបជ្ឈាយ៍ក្តី របស់ព្រះដ៏មានព្រះភាគនោះមិនមានទេ ទាំងការកសង្ឃជាអ្នកឱ្យនូវឧបសម្បទ ដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះទៀតក៏មិនមានដែរ តែឯព្រះដ៏មានព្រះភាគនោះ ព្រះអង្គកើតឡើងឯងត្រាស់ដឹងឯងមួយអន្លើដោយព្រះសព្វញ្ញុតញ្ញាណទៀបប្រទេសជាទីតម្កល់នៃពោធិព្រឹក្សនោះឯង ឯអាចារ្យឬឧបជ្ឈាយ៍របស់ព្រះអង្គនោះមិនមានទេ សូមស្តេចជ្រាប ។

**ម. យទិ ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន បើព្រះសមណគោតមម្ចាស់នោះ ព្រះអង្គមិនមានអាចារ្យមិនមានឧបជ្ឈាយ៍ហើយតាមសេចក្តីយល់របស់ខ្ញុំថា ព្រះអង្គនោះជាអនុបសម្បន្នដោយពិត មិនមែនជាឧបសម្បន្នឡើយ ព្រោះហេតុថាឧបសម្បន្នដែលនឹងកើតឡើងដល់បុគ្គលណា ១ នោះ ដោយមានអាចារ្យ ឧបជ្ឈាយ៍ និងការកសង្ឃព្រមឱ្យឧបសម្បទផងទើបបាន ។

**ត.** នាកាលព្រះមហាក្សត្រ ស្តេចមានព្រះរាជឱង្ការយ៉ាង

នេះហើយ ចំណែកព្រះនាគសេនថេរដ៏មានអាយុ ផ្ទុយពីន លោកជាអង្គព្រះអរហន្តដ៏វិសេស លោកជាអ្នកបានសម្រេច ព្រមនូវបដិភិសម្ភិទាញាណ ក៏មានថេរវាចាថ្វាយព្រះពរចំពោះ ទៅព្រះបាទមិលិន្ទរាជវិញថា មហារាជ បពិត្រសម្ដេចមហា-រាជ បុះមហាបពិត្រស្ដេចបេះសោយក្រយាស្ងោយដែរឬទ្រង់មិន បេះទេ ។

**ម. អាម ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ឯការបរិភោគ នូវភោជនាហារនោះ ខ្ញុំបេះណាស់ហើយលោកម្ចាស់មិនបាច់ សួរទេ ។

**ន. ត្វំ មហារាជ** បពិត្រមហារាជ ដែលព្រះអង្គទ្រង់បេះ សោយនូវក្រយាស្ងោយនោះតើ មានអ្នកឯណាជាអាចារ្យ អ្នក ឯណាជាព្រះឧបជ្ឈាយ៍របស់ព្រះអង្គ ។

**ម. នត្ថិ ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន ឯការបរិភោគ អាហារនោះ មិនចាំមានអាចារ្យឬឧបជ្ឈាយ៍បង្រៀនទៀតទេ លោកម្ចាស់ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ន. ត្វំ មហារាជ** បពិត្រមហារាជ ឯការបរិភោគនោះបើព្រះអង្គមិនមានអាចារ្យ ឧបជ្ឈាយ៍បង្ហាត់បង្រៀនហើយប្រហែលជាព្រះអង្គមិនបេះសោយទេឬអ្វី ។

**ម. ន ហិ ភន្តេ** បពិត្រព្រះនាគសេនដ៏បម្រើន សេចក្ដីនេះមិនមែនដូចលោកម្ចាស់ថានោះទេ ឯការបរិភោគជនាហារនោះមិនបាច់ចាំមានអាចារ្យ ឬឧបជ្ឈាយ៍ណាមកបង្ហាត់បង្រៀនទេ ព្រោះខ្ញុំធ្លាប់ទទួលទានភោជនាហារទាំងនោះយូរយារមកណាស់ហើយ គ្រប់ជាតិគ្រប់ជាន់ដែលកើតមកក្នុងសង្សារវដ្ដនេះ ។

**ន. សុដ្ឋុ ខោ មហារាជ** បពិត្រសម្ដេចមហារាជ មហាបពិត្រស្ដេចទ្រង់ជ្រាបថា តួព្រះអង្គដែលទ្រង់បេះសោយនូវក្រយាស្ងោយនោះមិនបាច់ចាំមានគ្រូអាចារ្យណាមកបង្ហាត់បង្រៀនទេ ព្រោះព្រះអង្គធ្លាប់លេបធ្លាប់សោយនូវក្រយាស្ងោយទាំងនោះមកយូរយារជាតិណាស់ហើយ នឹងរកទីបំផុតខាងដើមមិនឃើញ សេចក្ដីនេះក៏ប្រហែលគ្នានឹងរឿងរ៉ាវរបស់សម្ដេចព្រះភគវា ដែល

Websites: WatKhemaraRatanaram.org or WatKhmers.org

ព្រះអង្គមិនមានគ្រូអាចារ្យណា ១ នឹងឱ្យឧបសម្បទាព្រះអង្គនោះ គឺព្រះអង្គទ្រង់បានឧបសម្បទាឯង ទ្រង់បានត្រាស់ដឹងចំពោះព្រះអង្គឯង មួយអន្លើដោយព្រះសព្វញ្ញុតញ្ញាណនៅទៀបគល់នៃមហាពោធិព្រឹក្ស ព្រោះទ្រង់បានកសាងនូវបារមីទាំងឡាយ ១០ ប្រការ មានទានបារមីជាដើមមកយូរយារជាតិណាស់ហើយ ក៏ព្រះសព្វញ្ញុតញ្ញាណព្រមទាំងបារមី ១០ ប្រការនេះហើយមកជាព្រះឧបជ្ឈាយ៍អាចារ្យរបស់ព្រះអង្គនោះ បពិត្រសម្តេចមហារាជ ឯឧបសម្បទារបស់ព្រះភគវន្តមុនីសាស្តានេះក៏ជាទីអស្ចារ្យចំឡែកពេកណាស់ គឺជាគុណសម្បត្តិម្យ៉ាងដែលធ្លាប់កើតហើយកើតឡើងប្រាកដក្នុងលោកនេះ បណ្តាលសេចក្តីអស្ចារ្យនោះឯងឱ្យឃើញច្បាស់ថា មនុស្សឯណាដែលជាមនុស្សខ្វាក់អំពីកំណើត ក៏ត្រឡប់ទៅជាមនុស្សមានបក្ខុភ្លឺល្អឡើង មនុស្សដែលមានត្រចៀកថ្លង់ក៏ត្រឡប់ជាស្តាប់សំឡេងបាន មនុស្សដែលមានជើងខ្វិនក៏ត្រឡប់ទៅជាដើរឈរបាន មនុស្សដែលគក៏ត្រឡប់ជាមានជិវ្ហាស្រួលនិយាយបាន មនុស្សដែល

គមខ្នងក៏ត្រឡប់ទៅជាមានខ្នងត្រង់ស្រួលបួលឡើងបាន អ្នកដែលឃ្លានបាយក៏បានបាយបរិភោគស្កប់ស្កល់ទៅ អ្នកដែលស្រេកទឹកក៏បានទឹកផឹកដោយបរិបូណ៌ អ្នកដែលមានអាឃាតគំនំគំគួនទៅវិញទៅមក ក៏បែរទៅជាមានចិត្តអាណិតមេត្តារាប់អានគ្នាទៅមក សេចក្ដីលំបាកក្នុងកំណើតជាបេតវិស័យក៏វិនាសសាបសូន្យអស់ទៅ ថ្នាំដែលមានពិសពុលក៏ត្រឡប់ទៅជាមានជាតិផ្អែមដូចទឹកអម្រឹតវិញ ស្ត្រីដែលមានគភ៌ធំប្រឡើសលើសប្រមាណមិនដូចគេឯងក៏បានសំរាលកូនរួចបេញមកដោយស្រួលឥតមានគ្រោះថ្នាក់អ្វីឡើយ ទូកដែលប្រព្រឹត្តទៅកាន់ប្រទេសផ្សេង ៗ ក៏បានដល់ទៅបតទៀបកំពង់ដោយស្រួលឥតមានលង់លិចអ្វីឡើយ ក្លិនដែលស្អុយខារផ្សរបត់ក៏ត្រឡប់ទៅជាក្លិនក្រអូបឆ្ងាញ់ល្អទៅវិញ ភ្លើងក្នុងមហានរកឈ្មោះអវីចិក៏រលត់រលាយបាត់អស់ទៅ ទឹកប្រៃក្នុងមហាសមុទ្រក៏ត្រឡប់ទៅជាទឹកមានរសផ្អែមឆ្ងាញ់វិញ ភ្នំទាំងឡាយក៏ស្រែកបន្លឺនូវសព្ទសំឡេងទ្រហឹងអឺងកង ។ លំអិតខ្លឹមបន្ទន់ដ៏ជាទិព្វក្ដី ផ្កាមន្ទារ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដ៏ជាទិព្វក្តី ក៏ជ្រុលចុះមករោយរាយដេរដាសពាសពេញ ផ្កាឈើទាំងឡាយដែលរីក ៗ ក៏ជ្រុះមកសព្វទីកន្លែង មហាព្រហ្មទាំងឡាយ ក៏ទះដៃឱ្យសព្ទសាធុការទ្រហឹងអឹងកង ។

មហារាជ បពិត្រសម្តេចមហារាជ ឯសម្តេចព្រះភគវាជាសាស្តាចារ្យនេះ ព្រះអង្គទ្រង់មានព្រះពិម្ព គឺព្រះរូបព្រះឆោមរបស់ព្រះអង្គមានពណ៌ល្អដូចជាពណ៌នៃមាស មានព្រះឆវីវណ្ណស្អាតស្និទ្ធដូចកែវដ៏វិចិត្ររចនាផ្សេង ៗ ព្រះអង្គទ្រង់បានឧបសម្បទាឯង ឥតមានគ្រូអាចារ្យណាឱ្យព្រះអង្គឡើយ ទ្រង់ត្រាស់ដឹងឯងក្រោមម្លប់ពោធិព្រឹក្ស ព្រោះព្រះអង្គបានសាងសន្សំបន្សំព្រះបារមីធម៌ទាំងឡាយ ៣០ ប្រការ មានទានបារមីជាដើម មានឧបេក្ខាបារមីជាទីបំផុត មកយូរអង្វែងជាតិហើយ ទើបព្រះអង្គសម្រេចឧបសម្បទាយ៉ាងនេះ ឧបសម្បទាយ៉ាងនេះហើយដែលបានឈ្មោះអច្ឆរិយព្ភូតធម៌នេះ ៗ ប្រែថាធម៌ដែលមិនធ្លាប់កើតមិនធ្លាប់ឃើញ ហើយកើតឡើងមានឡើងជាគុណគួរអស្ចារ្យបំផ្លែក មានមកប្រាកដក្នុងលោកនេះ សេចក្តីអស្ចារ្យនេះហើយ

Websites: WatKhemaraRatanaram.org or WatKhmers.org

ដែលបណ្ដាលឱ្យស្ដេចនៃភ្នំឈ្មោះសិនេរុ បក់បង្វិលវិលខ្លួន ឯងដូចជាកង់នៃបក្រ ហើយស្រែកគ្រហឹមយ៉ាងខ្លាំងដោយអានុភាពអំណាចនៃឧបសម្បទាកម្ម នៃព្រះសម្មាសម្ពុទ្ធម្ចាស់ ។ ម្យ៉ាងទៀតទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងអាកាសវិមានក៏កើតមានសេចក្ដីសោមនស្សត្រេកអរ នៅក្នុងអាកាសមួយអន្លើដោយយសបរិវារទាំងពួង ហើយឱ្យនូវសាធុការដោយកិរិយាបង្អុរនូវផ្កាទិព្វទាំងឡាយ ចំណែកបន្ទទេវបុត្រក៏បញ្ឈប់នូវរថមណ្ឌលរបស់ខ្លួននៅក្នុងកណ្ដាលអាកាសវេហាស៍ ហើយរោយរាយនូវផ្កាទាំងឡាយធ្លាក់ចុះមក ប្រៀបដូចជាដំណក់ទឹកដោះដែលជ្រុះចុះមកអំពីអាកាសស្ថាន ហើយឱ្យនូវសព្ទសាធុការពរ ។ ពពួកទេវតាទាំងឡាយដែលស្ថិតនៅក្នុងឥភាកាស ក៏កើតមានសេចក្ដីសោមនស្សស្មោះសរ ឱ្យនូវសាធុការគ្រប់ ៗ គ្នា ឯវំ តថាគតស្ស ឧបសម្បទាភាវោ បាកដោ អហោសិ ឯឧបសម្បទានុភាពរបស់ព្រះតថាគត ជាម្ចាស់នោះក៏កើតមានគុណដ៏ទូទៅប្រាកដឡើងក្នុងលោកយ៉ាងនេះ សូមមហារាជស្ដេចជ្រាប ។

**ម. ឧបមំ ករោហិ** សូមលោកម្ចាស់ឧបមានូវឧបសម្បទាកម្មរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នេះជាសេចក្តីឱ្យខ្ញុំងាយស្តាប់បន្តិចទៅមើល ។

**ន. យថា ឯវំ មហារាជ** បពិត្រមហារាជ ឯព្រះសម្មាសម្ពុទ្ធដែលព្រះអង្គទ្រង់បាននូវឧបសម្បទាយ៉ាងនេះ គឺជាព្រះអង្គស្តេចដល់នូវទីជាទីបំផុតខាងលើទី ១ ហើយឥតអ្នកឯណានឹងអាចឡើងទៅខាងលើទីដែលព្រះអង្គបានដល់នោះឡើយ ប្រៀបដូចព្រះរាជសម្ភារដែលទ្រង់ឡើងគង់លើកនៃដំរីហើយ ៗ មានមនុស្សដទៃទៀត មកឡើងលើព្រះស្ធរងព្រះអង្គនោះតើជាទ្រង់ព្រមឱ្យជិះឬៗ ទ្រង់នឹងធ្វើដូចម្តេច ។

**ម. ន ហិ ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន បើខ្ញុំម្ចាស់បានឡើងជិះលើកដំរីរបស់ខ្ញុំហើយ មិនមានអ្នកឯណានឹងហ៊ានមកជិះលើកខ្ញុំទៀតទេ បើបែរទៅជាមានមនុស្សដទៃណាមួយហ៊ានឡើងមកជិះលើកខ្ញុំ ៗ នឹងមិនអត់ទេ មុខជានឹងកាត់ក្បាលមនុស្សនោះដោយព្រះខ័នរាជ ១ រំពេចមិនយូរឡើយ សូមលោកម្ចាស់ជ្រាប ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រសម្តេចមហារាជ មហាបពិត្រ ដែលទ្រង់មានតួវព្រះរាជតេជានុភាពយ៉ាងណា ក៏អង្គសម្តេចព្រះដ៏មានព្រះភាគព្រះអង្គទ្រង់បានឧបសម្បទាដោយព្រះអង្គឯងឥតមានអ្នកឯណា ១ ហើយនឹងអាចឱ្យឧបសម្បទានោះដល់ព្រះអង្គបានឡើយ បើបែរទៅជាមានអ្នកឯណា ១ ហើយអាចឱ្យនូវឧបសម្បទានោះដល់ព្រះអង្គ អ្នកនោះឯងនឹងបែកក្បាលទៅជា ៧ ភាគ ដោយអំណាចពុទ្ធានុភាពនោះមិនខានទេ មានឧបមានុបមេយ្យដូចជាព្រះរាជានុភាពនោះឯង ម្យ៉ាងទៀតបពិត្រសម្តេចមហារាជ កាលពីជាន់មុន ព្រះអង្គស្តេចបានមានព្រះរាជឱង្ការសួរអាត្មាភាពថា ក្រុមជំនុំសង្ឃប៉ុន្មានអង្គអាចឱ្យនូវឧបសម្បទាដល់ព្រះដ៏មានព្រះភាគមែនឬ ។

**ម. វទាមិ ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន ពាក្យនេះខ្ញុំបានពោលមែន ។

**ន. ន សង្ឃេន ខោ មហារាជ** បពិត្រសម្តេចមហារាជឯឧបសម្បទារបស់ព្រះដ៏មានព្រះភាគនោះ ឥតមានភិក្ខុសង្ឃ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឯណាដទៃនឹងអាចឱ្យបានឡើយ មានតែសង្ឃ ៣ ពួកទើបឱ្យបានគឺបារមីសង្ឃ ១ កុសលសង្ឃ ១ ផលសង្ឃ ១ សេចក្តីនេះត្រូវផ្ទួបពុទ្ធភាសិតដែលទ្រង់សម្តែងទុកមកថា

**បត្តាភោ ប បដិបន្នា បត្តាភោ ប ផលេដ្ឋិតា**

**ឯស សង្ឃោ ឧជុភូតោ បញ្ញាសីលសមាហិតោ**

សេចក្តីថា បុគ្គលឯណា ១ មានចិត្តត្រង់ ប្រកបដោយសីល សមាធិ បញ្ញា បានប្រតិបត្តិក្នុងមគ្គ ៤ ហើយតាំងនៅក្នុងផល ៤ បុគ្គលនោះឯងលោកហៅថាជាសង្ឃប្រាកដបាន ។ ម្យ៉ាងទៀតបពិត្រសម្តេចមហារាជ ឧបសម្បទាឯណា ១ គឺសង្ឃទាំង ៣ ពួក មានបារមីសង្ឃជាដើមនេះអាចឱ្យនូវឧបសម្បទាបានឥតមានទាស់ឡើយ ។

**ម. អច្ឆរិយំ ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន សេចក្តីនេះក៏ជាអស្ចារ្យពេកណាស់ អព្ភូតំ ភន្តេ បពិត្រព្រះនាគសេនដ៏ចម្រើន ហេតុនេះក៏ជាហេតុមិនធ្លាប់កើតហើយកើត ឯប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកនេះក៏ជាប្រស្នាយ៉ាងវិចិត្រ នឹងរកប្រស្នាឯណា ១ មកប្រៀបផ្ទឹមឱ្យប្រហែលនោះមិនមានឡើយ ។

**ឥ. អាម មហារាជ** បពិត្រមហារាជ ឯឧបសម្បទារបស់ព្រះដ៏មានព្រះភាគនេះល្អពេកណាស់ សូមមហាបពិត្រស្តេចជ្រាប ។

**ម. អត្ថិ បន ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន ចុះឧបសម្បទារបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះប្រាកដជាមាន ឬមិនមានទេ ។

**ឥ. ឧបសម្បន្នោ មហារាជ** បពិត្រសម្តេចមហារាជ ឯព្រះសម្មាសម្ពុទ្ធប្រាកដជាព្រះអង្គបានដល់នូវឧបសម្បទា ដោយពិតមួយអន្លើនឹងព្រះសព្វញ្ញុតញ្ញាណក្រោមម្លប់ពោធិព្រឹក្ស នឹងមានអ្នកឯណា ១ អាចឱ្យនូវឧបសម្បទានោះដល់ព្រះអង្គនោះគ្មានឡើយ ដូចជាព្រះអង្គបញ្ញត្តនូវសិក្ខាបទដល់សាវកទាំងឡាយមិនឱ្យប្រព្រឹត្តកន្លងជរាបដល់អស់ជីវិតនោះឯង ។

**ម. កល្លោសិភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់វាងវៃពេកណាស់ បេះវិសជ្ជនាគួរឱ្យចូលចិត្តដោយងាយ ។

## អស្សុបញ្ហា ៗ ទី ៦

ព្រះបរមក្សត្រាធិរាជស្តេច ទ្រង់ព្រះរាជបុច្ឆាចំពោះទៅព្រះ

នាគសេនថេរថា បពិត្រព្រះថេរដ៏ចម្រើន បុរសពីរពួកឬជនពីរពួក ជនពួក ១ មានសេចក្ដីខ្សឹកខ្សួលសម្រក់ទឹកភ្នែក ព្រោះមាតាបិតាធ្វើកាលកិរិយាស្លាប់បង់ទៅ ជនពួក ១ ទៀតសម្រក់ទឹកភ្នែកព្រោះបានស្ដាប់ធម៌ឬឃើញធម៌ដែលពីរោះត្រូវចិត្ត ហើយកើតសេចក្ដីខ្សឹកខ្សួលហូរហៀរទឹកភ្នែក ទឹកភ្នែករបស់ជនទាំងពីរពួកនេះ តើទឹកភ្នែករបស់ជនពួកណានឹងបានជាភេសជ្ជៈគឺថ្នាំសម្រាប់រំងាប់រោគ ទឹកភ្នែករបស់ជនពួកណាដែលមិនបានជាភេសជ្ជៈ លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរទៅវិញថា បពិត្រមហារាជ ទឹកភ្នែកនៃជនពួក ១ មានសម្ផស្សដ៏ក្ដៅ ព្រោះអំណាចនៃរាគ ទោស មោហ ដុតកំដៅឲ្យដ៏ខាងក្នុងហើយហូរហៀរស្រក់ស្រោចចេញមក ទឹកភ្នែកនៃជនពួក ១ ទៀតមានសម្ផស្សដ៏ត្រជាក់យ៉ាងឧត្ដម ព្រោះបានស្ដាប់ធម៌ទេសនា ដោយកំឡាំងនៃបីតិនឹងសោមនស្សក្លាហានហើយហូរហៀរចេញមក មហារាជ បពិត្រសម្ដេចមហារាជ អាត្មាភាពសូមថ្វាយព្រះពរសម្រេច

Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្តីនេះថា ទឹកភ្នែកឯណាដែលត្រជាក់ ទឹកភ្នែកនោះនឹងទៅជាថ្នាំភេសជ្ជៈយ៉ាងវិសេស ទឹកភ្នែកឯណាដែលក្តៅទឹកភ្នែកនោះឯងមិនមែនជាថ្នាំភេសជ្ជៈទេ សូមទ្រង់ជាប ។

**ម. កល្លោសិ ភន្តេ បពិត្រ**ព្រះនាគសេនដ៏ចម្រើន លោកម្ចាស់ប៉ិនប្រសប់ពេកណាស់ក្នុងការវិសជ្ជនានេះ ។

## វសបដិសំវេទីបញ្ហាៗ ទី ៧

ព្រះបាទមិលិន្ទនរិន្ទរាជ ស្តេចទ្រង់បុច្ឆាទៅព្រះនាគសេនថេរថា បពិត្រព្រះនាគសេនដ៏ចម្រើន ជនមានពីរបំពូក ជនបំពូក១ ជាវីតរាគបុគ្គល ជនបំពូក ១ ទៀតជាអវីតរាគបុគ្គល ជនទាំងពីរបំពូកនេះតើនឹងមានហេតុផ្សេង ៗ គ្នាដូចម្តេចទៅលោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថាបពិត្រមហារាជ ជនដែលជាវីតរាគគឺមានរាគទៅប្រាសហើយចាកសន្តាននោះ ជាអនជ្ឈោសិត ជនដែលជាអវីតរាគ គឺមានរាគមិនទាន់ទៅប្រាសចាកសន្តាននោះ ជាអជ្ឈោសិត សូមមហាបពិត្រស្តេចជ្រាប ។

**ម. កឹ ឯវំ ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន ចុះជនដែលជាអផ្លោសិតនោះមានសេចក្តីអធិប្បាយដូចម្តេច ជនដែលជាអនផ្លោសិតនោះ មានសេចក្តីអធិប្បាយដូចម្តេច សូមលោកម្ចាស់វិសជ្ជនាមកមើល ។

**ន. ឯកោ ខោ មហារាជ** បពិត្រមហារាជ ឯជនពួក ១ ដែលជាអផ្លោសិតនោះ គឺជននោះឯងនៅមានប្រយោជន៍ ឬនៅប្រកបកិច្ចការក្នុងលោកនេះនៅឡើយ ឯជនដែលជាអនផ្លោសិតនោះ គឺជននោះឯងមិនមានប្រយោជន៍ឬមិនត្រូវការក្នុងលោកនេះតទៅទៀត សូមមហារាជស្តេចជ្រាប ។

**ម. ឯវរូបំ ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន សេចក្តីដែលលោកម្ចាស់វិសជ្ជនាមកយ៉ាងនេះ ខ្ញុំក៏ចូលចិត្តបានហើយថា អ្នកដែលមានរាគរម្ងាប់ផុតបាកសន្តានិនោះ តែងមិនមានប្រយោជន៍ត្រេកអរឡើយ ឯអ្នកដែលនៅប្រកបដោយរាគនោះតែងមានប្រយោជន៍ត្រេកអរតទៅ ក៏បំណែកខាងខ្ញុំឃើញថា មនុស្សទាំងពីរបំពូកនេះ នៅមានសេចក្តីប្រាថ្នាបរិភោគនូវ

ភោជនាហារដែលជាទីគាប់ចិត្តនៅឡើយ មិនមានអ្នកឯណា ១ នឹងប្រាថ្នានូវភោជនដែលមិនពេញចិត្តនោះទេ បើយ៉ាងហ្នឹង ហើយចុះហេតុអ្វី ក៏បុគ្គលទាំងនោះមិនដូចគ្នាលោកម្ចាស់ សូមនិមន្តវិសជ្ជនាឱ្យច្បាស់លាស់មកមើល ។

**ន. វីតរាគោ ខោ មហារាជ** បពិត្រមហារាជបុគ្គលទាំង ២ បំពូកនោះ ក៏សុទ្ធតែជាអ្នកនៅបរិភោគអាហារដូចគ្នាមែន តែមានអារម្មណ៍ផ្សេងគ្នា អ្នកដែលជាវីតរាគនោះ មានអារម្មណ៍មិនបានជាប់ចំពាក់ក្នុងរសនៃអាហារអាក្រក់ល្អនោះឡើយ គឺឆាន់បង្ហាន់នោះ គ្រាន់តែនឹងតម្កល់ខ្លួនឱ្យបានតាំងនៅក្នុង ព្រហ្មចរិយធម៌ប៉ុណ្ណោះទេ ឯអ្នកដែលប្រកបដោយរាគនោះ នៅមានចិត្តត្រេកអរជាប់ចំពាក់ក្នុងរសនៃអាហារ ដែលឆ្ងាញ់និងមិនឆ្ងាញ់នៅឡើយ សូមមហាបពិត្រស្តេចជ្រាប ។

**ម. កល្លោសិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ឆ្លៀវឆ្លាសពេកណាស់ បេះវិសជ្ជនាស្រួលបួល ខ្ញុំអស់សង្ស័យហើយ ។

# បញ្ញាយបតិដ្ឋានបញ្ហា ៗ ទី ៨

ព្រះមហាក្សត្រ ស្ដេចទ្រង់បុច្ឆាសួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៨ នេះថា បពិត្រព្រះនាគសេនដ៏ចម្រើន បញ្ញា កុហិំ វសតិ បញ្ញានេះឯងតែងស្ថិតនៅត្រង់ទីណា លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រមហារាជ ឯបញ្ញានេះមិនមានទីកន្លែងនឹងស្ថិតនៅទេ សូមជ្រាប ។

**ម. នត្ថិ បញ្ញា** បពិត្រព្រះនាគសេនដ៏ចម្រើន បើលោកម្ចាស់មានថេរវាចាថាដូច្នោះនោះ ប្រហែលជាបញ្ញានោះមិនមានទេឬ ។

**ន. វាតោ មហារាជ** បពិត្រមហារាជ អាត្មាភាពសូមថ្វាយព្រះពរថា ចុះខ្យល់តែងស្ថិតនៅក្នុងទីណាមហាបពិត្រ ។

**ម. ន កិស្មិញ្ចិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន ខ្យល់មិនមានទីកន្លែងស្ថិតនៅទេ លោកម្ចាស់ ។

**ន. នត្ថិ វាតោ** បពិត្រមហារាជ បើខ្យល់នោះមិនមានទីស្ថិតនៅ មានតែខ្យល់នោះមិនមានដែរឬ ។

**ម. កល្លោសិ** ព្រះថេរលោកឆ្លើយឆ្លាសល្អ បេះវិសជ្ជនាតបប្រស្នាស្រួលពេកណាស់ ។

## សំសារបញ្ហា ។ ទី ៩

ព្រះមហាក្សត្រស្តេចទ្រង់បុច្ឆា ចំពោះទៅព្រះនាគសេនថេរថា បពិត្រព្រះនាគសេនដ៏ចម្រើន លោកម្ចាស់បានពោលថា សំសារោ ។ ដូច្នេះ សំសារសព្ទនេះ តើមានសេចក្តីអធិប្បាយដូចម្តេច សូមលោកម្ចាស់វិសជ្ជនាមកមើល ។

ព្រះនាគសេនថ្វាយព្រះពរថា បពិត្រមហារាជ ឯសំសារសព្ទនេះប្រែថា ប្រទេសជាទីអន្ទោលទៅនិងត្រឡប់មកនៃសត្តនិករ គឺសត្វដែលកើតក្នុងលោកនេះ វេលាដល់ស្លាប់ក៏ស្លាប់ក្នុងលោកនេះ សត្វដែលស្លាប់ក្នុងលោកនេះហើយទៅបដិសន្ធិកើតទៀតក្នុងលោកដទៃ សត្វដែលកើតក្នុងលោកនោះវេលាដល់ស្លាប់ក៏ស្លាប់ក្នុងលោកនោះ សត្វដែលស្លាប់ក្នុងលោកនោះទៅកើតក្នុងលោកឯទៀត ឯវំ ខោ មហារាជ សំសារោ បពិត្រសម្តេចមហារាជ ឯសង្សារនេះមានសេចក្តីដូចអាត្មាភាពវិសជ្ជនាមកនេះ សូមទ្រង់ជ្រាប ។

**ម. ឧបមំ ករោហិ** សូមលោកម្ចាស់ប្រៀបឧបមាជាសេចក្ដីបន្តិចមកមើល ។

**៩. យថា មហារាជ** បពិត្រសម្ដេចមហារាជ សេចក្ដីនេះប្រៀបឧបមាដូចបុរសណា ១ បានបរិភោគនូវផ្លែស្វាយទំរួចយកគ្រាប់ស្វាយនោះទៅដាក់ដាំចុះលើផែនដី ស្វាយនោះក៏ដុះបម្រើនធំឡើងដោយលំដាប់ មានផ្កាផ្លែបរិបូណ៌ បំណែកខាងបុរសជាម្ចាស់នោះក៏ទៅបេះយកផ្លែនោះមកបរិភោគ រួចយកគ្រាប់ស្វាយនោះទៅដាំម្ដងទៀត ស្វាយនោះក៏ដុះឡើងមានផ្លែផ្កាត ៗ ទៅ ឯផ្លែស្វាយជាដំបូងដែលបុរសយកទៅដាំមុនក៏ដុះបេញជាដើមជាមែកស្លឹកផ្កាផ្លែ ដើមចាស់ក៏រលំរលាយបាត់សូន្យទៅ នៅតែពូជគឺផ្លែ ៗ នោះក៏ដុះដាលជាដើមជាមែកស្លឹកផ្កាផ្លែទៀត ត ៗ គ្នាទៅឥតមានទីបំផុត ឯទីបំផុតខាងដើមនៃដើមស្វាយនោះនឹងរកប្រាកដមិនមានយ៉ាងណាមិញ បពិត្រមហារាជ ឯកំណើតសត្វក្នុងសង្សារ ដែលកើតហើយស្លាប់ ៗ ហើយកើតត ៗ ទៅនោះ ក៏រកទីបំផុតពុំមានដូចពូជឈើនោះឯង សូមទ្រង់ជ្រាប ។

**ម. កល្លោសិ** លោកម្ចាស់ប៉ិនណាស់ប្រសប់ប្រៀបគួរឱ្យចូលចិត្តបានហើយ ។

## បិរកតសរណបញ្ហា ។ ទី ១០

ព្រះបរមក្សត្រាធិរាជ ស្តេចទ្រង់បុច្ឆាចំពោះទៅព្រះនាគសេនថេរថា បពិត្រព្រះថេរដ៏ចម្រើន បុគ្គលរលឹកនូវអំពើការអ្វីនីមួយដែលខ្លួនធ្វើទុកយូរហើយ កន្លងទៅហើយនោះ តើរលឹកដោយធម្មជាតិអ្វី លោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា សតិយា មហារាជ បពិត្រសម្តេចមហារាជ ឯបុគ្គលដែលនឹងរលឹកនូវអំពើកម្មទាំងពួងនោះគឺរលឹកដោយស្មារតី សូមមហារាជជ្រាប ។

**ម. បិន្តេន សរិយតិ** បពិត្រព្រះនាគសេនដ៏ចម្រើន លោកម្ចាស់សំដែងថារលឹកដោយស្មារតី ឯខ្ញុំចូលចិត្តថាបុគ្គលនឹងរលឹកនូវអំពើការនោះគឺរលឹកដោយចិត្តជាប្រាកដ មិនមែនរលឹកដោយស្មារតីទេ ។

**ន. អភិជានាសិ មហារាជ** បពិត្រមហារាជ ចំណែក

មហាបពិត្រ ស្ដេចពេញព្រះហឫទ័យថា ឯការដែលនឹងនឹករលឹកនោះ គឺរលឹកដោយចិត្តបំពោះ បើដូច្នេះអាត្មាភាព សូមថ្វាយព្រះពរសួរថា ចុះមហាបពិត្រកាលដែលនឹងធ្វើការអ្វីនីមួយហើយភ្លេចភ្លាំងបាត់ទៅនឹករកពុំឃើញជាមានឬពុំមាន ។

**ម. អាម ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន ឯការដែលធ្វើហើយវង្វេងភ្លេចបាត់ទៅគង់មាន លោកម្ចាស់ ។

**ន. កិន្នុ ខោ មហារាជ** បពិត្រមហារាជ ចុះសម័យដែលព្រះអង្គធ្វើការនោះប្រហែលជាទ្រង់ធ្វើដោយគ្មានចិត្តឬដូចម្ដេចក៏បានជាភ្លេចបាន ។

**ម. ន ហិ ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន ឯសម័យដែលធ្វើការនោះមិនមែនធ្វើដោយគ្មានចិត្តទេ គឺចិត្តនោះនៅមានប្រាកដ តែវាគ្មានស្មារតីនឹងរលឹក បានជាវាភ្លេចបាត់ទៅវិញ លោកម្ចាស់ ។

**ន.** មហាបពិត្រស្ដេចទ្រង់ជ្រាបយ៉ាងនេះ ត្រូវពេកណាស់ ក៏ការដែលរលឹកនោះគឺរលឹកដោយស្មារតី ៗ នេះជាភ្នាក់ងារ

សម្រាប់ខាងនឹករលឹកតែម្យ៉ាង ឯចិត្តនោះមានកិច្ចត្រូវគិតត្រូវសន្សំ ចិត្តនេះជាភ្នាក់ងារខាងរិះគិតតែម្យ៉ាងប៉ុណ្ណោះ មិនមែនជាអ្នកនឹករលឹកទេ សូមមហាបពិត្រស្ដេចជ្រាប ។

**ម. កល្លោសិ** ព្រះថេរម្ចាស់លោកឆ្លាសពេកណាស់បេះវិសជ្ជនាដោះស្រាយប្រស្នាពីរោះល្អណាស់ ខ្ញុំអស់មានសេចក្ដីសង្ស័យហើយ ។

## សតិអភិជានបញ្ហា ។ ទី ១១

ព្រះបរមក្សត្រាធិរាជ ស្ដេចទ្រង់បុច្ឆាបំពោះទៅព្រះនាគ-សេនថេរក្នុងប្រស្នាទី ១១ នេះថា បពិត្រព្រះនាគសេនដ៏ចម្រើន សតិចេតសិកដែលជាធម្មជាតិ សម្រាប់រលឹកនូវវត្ថុទាំងពួងនោះតែងមានដល់តែអ្នកដែលចេះដឹងម្យ៉ាងទេឬ ។ នឹងមាននូវទៅដល់ជនជាកុដុម្ពិកដែរ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្ដេចមហារាជ ឯសតិនោះតែងមានដល់ជនដែលជាអ្នកចេះដឹងផង ដល់ជនជាកុដុម្ពិកផង មិនដែលខានទេ ។

**ម.ឯរំ ហិ ខោភន្តេ** បពិត្រព្រះនាគសេនដ៏បម្រើន ខ្ញុំមិនយល់ដូច្នោះទេ ខ្ញុំយល់ថាឯសតិបេតសិកនោះមានចំពោះតែមនុស្សដែលបេះដឹង ឯជនដែលជាកុដុម្ពិកនោះមិនមានសតិឡើយ ។

**ន. មហារាជ** បពិត្រសម្តេចមហារាជ ឯស្មារតីនេះបើមិនមានដល់ជនជាកុដុម្ពិកហើយ ចំណែកខាងកិច្ចដែលបុគ្គលត្រូវប្រកបក្នុងសិល្បសាស្ត្រក្តី ក្នុងព្រះកម្មដ្ឋានក្តី ក្នុងវិជ្ជាការផ្សេង ៗ ក្តី អំពីសំណាក់នៃគ្រូបាអាចារ្យទាំងឡាយ ក៏មិនមានប្រយោជន៍ឡើយ បពិត្រមហារាជ ឯស្មារតីនេះប្រាកដជាមានដល់ជនជាកុដុម្ពិកនោះឯង ទើបបានជាមានកិច្ចត្រូវប្រកបក្នុងការសិក្សាសិល្បសាស្ត្រ និងព្រះកម្មដ្ឋានហើយនិងវិជ្ជាការទាំងពួងអំពីសំណាក់នៃអាចារ្យទាំងឡាយ ដើម្បីនឹងបំពេញស្មារតីនោះឱ្យចម្រើនបរិបូណ៌ឡើងដោយគុណទាំងនោះ សូមមហារាជស្តេចជ្រាប ។

**ម. កល្លោសិ** លោកម្ចាស់ប៉ិនប្រសប់ណាស់ហើយ បេះដោះស្រាយសេចក្តីស្រួលស្តាប់ ខ្ញុំអស់សង្ស័យហើយ ។

ចប់វគ្គជាគម្រប់ ៦ តែប៉ុណ្ណោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

# សត្តមវគ្គមានប្រស្នា ១៩ ប្រការ

## សតិអាការបញ្ហា ៗ ទី ១

ព្រះបរមក្សត្រាធិរាជស្ដេចទ្រង់សួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ១ ក្នុងវគ្គទី ៧ នេះថា បពិត្រព្រះនាគសេនដ៏ចម្រើន ចុះសតិចេតសិកដែលនឹងកើតឡើងដល់បុគ្គលទាំងពួងនោះតើដោយអាការប៉ុន្មានយ៉ាងលោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្ដេចមហារាជ ឯសតិចេតសិកនោះវេលាដែលនឹងកើតឡើង គឺកើតដោយអាការ ១៧ ស្ថាន ។

ឯអាការ ១៧ ស្ថាននោះគឺ

១. អភិជានតោបិ សតិ

២. កដុម្ពិកាយបិ សតិ

៣. ឱឡារិកវិញ្ញាណតោបិ សតិ

៤. ហិតវិញ្ញាណតោបិ សតិ

៥. អហិតវិញ្ញាណតោបិ សតិ

៦. សភាគនិមិត្តតោបិ សតិ

៧. វិសភាគនិមិត្តតោបិ សតិ

៨. កឋាភិញ្ញាណតោបិ សតិ

៩. លក្ខណតោបិ សតិ

១០. សរណតោបិ សតិ

១១. មុទ្ទតោបិ សតិ

១២. គណនាតោបិ សតិ

១៣. ធារណតោបិ សតិ

១៤. ភាវនាតោបិ សតិ

១៥. បោត្ថកនិពន្ធនតោបិ សតិ

១៦. ឧបនិក្ខេបនតោបិ សតិ

១៧. អនុភូតតោបិ សតិ

ក៏អាការរបស់ស្មារតីទាំង ១៧ ស្ថាន ដូចឈ្មោះដែលរាប់មកនេះ សូមមហាបពិត្រស្ដេចជ្រាប ។

**ម. កថំ ភន្តេ** អភិជានតោសតិ បពិត្រព្រះនាគសេនដ៏ចម្រើន បុះអភិជានតោសតិ គឺសតិទី ១ នោះ តើមានសេចក្ដីប្រែនិងអធិប្បាយដូចម្ដេចទៅ ។

**ឥ. មហារាជ** បពិត្រមហារាជ ឯអភិជានតោសតិ នោះ ប្រែជាសេចក្ដីថា ស្មារតីឯណាដែលកើតឡើងដល់បុគ្គលដែលជាអ្នកបេះដឹងអាចរលឹកជាតិបាន និងស្មារតីរបស់ព្រះមហាអានន្ទដែលជាអ្នកស្ដាប់នូវព្រះសូត្រតែ ១ គ្រាក៏អាចចងចាំបាន និងស្មារតីនៃនាងខុជ្ជុត្តរាឧបាសិកា ដែលបានស្ដាប់នូវព្រះសទ្ធម្មទេសនាតែម្ដងក៏អាចចាំបាន នាំយកមកសំដែងប្រាប់ជនទាំងពួងឱ្យស្ដាប់បានផង ស្មារតីនោះបានឈ្មោះថា អភិជានតោ សតិ សូមមហាបពិត្រស្ដេចជ្រាប ។

**ម. កថំ ភន្តេ កុដុម្ពិកាយសតិ** បពិត្រព្រះនាគសេនដ៏ចំរើន ចុះកុដុម្ពិកាយសតិ ៗ ទី ២ នោះ តើមានសេចក្ដីអធិប្បាយយ៉ាងណាលោកម្ចាស់ ។

**ឥ. មហារាជ** បពិត្រព្រះរាជសម្ភារ ឯកុដុម្ពិកាយសតិ នោះ ប្រែជាសេចក្ដីថា ស្មារតីឯណា ១ ដែលកើតឡើងដល់ជនដែលមានទ្រព្យសម្បត្តិច្រើនហើយ លាក់ទុកឬកប់ទុកហើយភ្លេចនឹក ភ្លេចគិតអំពីរបស់ទាំងនោះ លុះមានជនដទៃគេមករកខ្ចីបងការ ទើបមានស្មារតីនឹករលឹកដល់ទ្រព្យដែលខ្លួន

Websites: WatKhemaraRatanaram.org or WatKhmers.org

កប់ទុកនោះ ស្មារតីយ៉ាងនេះបានឈ្មោះថា កុដុម្ពិកាយសតិ សូមមហារាជស្តេចជ្រាប ។

**ម. កថំ ឱឡារិកវិញ្ញាណគោសតិ** បពិត្រព្រះថេរដ៏ចម្រើន ចុះស្មារតីដែលឈ្មោះថាឱឡារិកវិញ្ញាណគោសតិ ៗ ទី៣ នោះ តើអធិប្បាយដូចម្តេច ។

**ន. មហារាជ** បពិត្រសម្តេចមហារាជ ឯឱឡារិកវិញ្ញាណគោសតិនោះ ប្រែសេចក្តីថា ស្មារតីឯណា ១ ដែលកើតឡើងដល់ជន ដែលមានវិញ្ញាណគ្រោតគ្រាតនៅឡើយ បានខាងស្មារតីរបស់ព្រះបរមក្សត្រាធិរាជដែលទើបនឹងបានរាជាភិសេកថ្មី ៗ និងស្មារតីរបស់ព្រះអរិយបុគ្គលដែលទើបនឹងបានដល់សោតាបត្តិផលថ្មី ៗ តែងមានព្រះហឫទ័យរីករាយសប្បាយនៅឡើយ ស្មារតីយ៉ាងនេះហៅថា ឱឡារិកវិញ្ញាណ-គោសតិ សូមទ្រង់ជ្រាប ។

**ម. កថំ ហិ ភន្តេ ហិតវិញ្ញាណគោសតិ** បពិត្រព្រះថេរដ៏ចម្រើន ហិតវិញ្ញាណគោសតិ ៗ ទី ៤ នោះ តើមានសេចក្តីអធិប្បាយដូចម្តេចលោកម្ចាស់ ។

**ឥ. មហារាជ** បពិត្រសម្តេចមហារាជ ឯហិតវិញ្ញាណ-តោសតិនោះ ប្រែចេញជាសេចក្តីថា ស្មារតីឯណា ១ ដែលកើតឡើងដល់បុគ្គល ដែលមានវិញ្ញាណប្រកបទៅដោយគុណបានខាងបុគ្គលដែលធ្លាប់សោយនូវសេចក្តីសុខអំពីកាលមុនៗមក ហើយនឹករលឹកដល់សេចក្តីសុខនោះថា អាត្មាអញបានភប់ប្រសប់ប្រទះនឹងសេចក្តីសុខសប្បាយយ៉ាងនោះ ៗ ក្នុងពេលមុនស្មារតីយ៉ាងនេះ បានឈ្មោះថាហិតវិញ្ញាណតោសតិ សូមមហាបពិត្រជ្រាប ។

**ម. កថំ អហិតវិញ្ញាណតោសតិ** បពិត្រព្រះថេរដ៏ចម្រើន ចុះអហិតវិញ្ញាណតោសតិ ៗ ទី ៨ នោះ តើដូចម្តេច ។

**ឥ. មហារាជ** បពិត្រមហារាជ ឯអហិតវិញ្ញាណតោ-សតិនោះមានសេចក្តីថា ស្មារតីឯណា ១ ដែលកើតឡើងដល់បុគ្គលដែលធ្លាប់បានទទួលរងទុក្ខវេទនាក្នុងកាលគ្រាមុន ៗ មក ហើយរលឹកនឹកដល់សេចក្តីទុក្ខទោស ដែលខ្លួនធ្លាប់សោយនោះ ៗ ស្មារតីយ៉ាងនេះបានឈ្មោះថា អហិតវិញ្ញាណតោសតិ សូមស្តេចជ្រាប ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ម. កថំ សភាគនិមិត្តគោសតិ** បពិត្រព្រះនាគសេនថេរដ៏ចម្រើន ចុះសភាគនិមិត្តគោសតិ ៗ ទី ៦ នោះតើមានសេចក្តីអធិប្បាយដូចម្តេចទៅ លោកម្ចាស់ ។

**ន. មហារាជ** បពិត្រសម្តេចមហារាជ ឯសភាគនិមិត្តគោសតិនោះ មានសេចក្តីថា ស្មារតីឯណាដែលកើតឡើងដល់ជនដែលមាននិមិត្តឬភេទ មានចំណែកស្មើ បានខាងឯជនដែលបានឃើញអ្នកដទៃមានរូបរាង សណ្ឋានទ្រង់ទ្រាយប្រហែលដូចមាតាបិតា បងប្រុស ប្អូនស្រី របស់ខ្លួនដែលបែកបាត់ទៅហើយមានស្មារតីរលឹកដល់ញាតិទាំងនោះ ឬបានឃើញនូវអូដ្ឋ, គោ, និងលារបស់អ្នកដទៃហើយ មានស្មារតីនឹករលឹកដល់ទ្រព្យរបស់ខ្លួនទាំងនោះមានអូដ្ឋជាដើម ស្មារតីយ៉ាងនេះបានឈ្មោះថា សភាគនិមិត្តគោសតិ សូមទ្រង់ជ្រាប ។

**ម. កថំ វិសភាគនិមិត្តគោសតិ** បពិត្រព្រះថេរដ៏ចម្រើន ចុះវិសភាគនិមិត្តគោសតិ ៗ ទី ៧ នោះតើមានសេចក្តីអធិប្បាយដូចម្តេច ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ឥ. មហារាជ** បពិត្រមហារាជ ឯវិសភាគនិមិត្តតោសតិ នោះ មានសេចក្ដីថា ស្មារតីឯណាដែលកើតឡើងដល់ជន ដែលមាននិមិត្តឬភេទមានចំណែកមិនស្មើ បានដល់ជនដែល បានរលឹកដល់ ពណ៌សម្បុរ ក្លិន, រស, និង ផោដ្ឋព្វារម្មណ៍ ដែលខ្លួនធ្លាប់ឃើញ ធ្លាប់ធុំ ធ្លាប់ភ្លក់ ធ្លាប់ពាល់ត្រូវហើយ ស្មារតីយ៉ាងនេះបានឈ្មោះថា វិសភាគនិមិត្តតោសតិ សូម ស្ដេចជ្រាប ។

**ម. កថំ កថាភិញ្ញាណតោសតិ** បពិត្រព្រះថេរដ៏ចម្រើនបុះ ស្មារតីទី ៨ ដែលហៅថា កថាភិញ្ញាណតោសតិ នោះតើ មានសេចក្ដីអធិប្បាយដូចម្ដេចលោកម្ចាស់ ។

**ឥ. មហារាជ** បពិត្រមហារាជ ឯកថាភិញ្ញាណតោសតិ នោះ មានសេចក្ដីថា ស្មារតីឯណា ១ ដែលកើតឡើងដល់ បុគ្គលដែលភ្លេចស្មារតីឬភ្លាត់ស្មារតី លុះបុគ្គលដទៃគេប្រាប់គេ រលឹកឡើង ក៏បានដឹងចំពោះវិញ ស្មារតីយ៉ាងនេះបានឈ្មោះ ថា កថាភិញ្ញាណតោសតិ សូមមហាបពិត្រស្ដេចជ្រាប ។

**ម.កថំ លក្ខណតោសតិ** បពិត្រព្រះថេរដ៏ចម្រើនចុះលក្ខណតោសតិ ៗ ទី ៩ នោះតើមានសេចក្ដីអធិប្បាយដូចម្ដេច ។

**ឥ. មហារាជ** បពិត្រសម្ដេចមហារាជ ឯលក្ខណតោសតិនោះ មានសេចក្ដីថា ស្មារតីឯណា ១ ដែលកើតឡើងដល់បុគ្គលជាអ្នកដឹងនូវលក្ខណៈនៃសត្វទាំងពួង បានដល់ជនជាម្ចាស់នៃគោ បានឃើញនូវអវយវៈជាគ្រឿងប្រដាប់របស់គោហើយអាចរលឹកដឹងស្គាល់បាន ស្មារតីយ៉ាងនោះបានឈ្មោះថា លក្ខណតោសតិ សូមស្ដេចជ្រាប ។

**ម. កថំ សរណតោសតិ** បពិត្រព្រះថេរដ៏ចម្រើន ចុះសរណតោសតិ ៗ ទី ១០ នោះ តើមានសេចក្ដីអធិប្បាយដូចម្ដេច ។

**ឥ. មហារាជ** បពិត្រមហារាជ ឯសរណតោសតិនោះ មានសេចក្ដីថា ស្មារតីឯណា ១ ដែលកើតឡើងដល់បុគ្គលដែលភ្លេចខ្លួន ហើយអ្នកដទៃគេមកនិយាយដាស់តឿនរំលឹកថា នែអ្នក ៗ ចូរនឹកនូវហេតុនេះមើល ទើបបុគ្គលនោះអាចរលឹកបាន ស្មារតីយ៉ាងនេះបានឈ្មោះថា សរណតោសតិ សូមស្ដេចជ្រាប ។

**ម. កបំ មុទ្ធគោសតិ** បពិត្រព្រះថេរដ៏បម្រើន ចុះមុទ្ធគោ-សតិ ៗ ទី ១១ នោះ តើមានសេចក្ដីសំដែងចេញដូចម្ដេចទៅ ។

**ន. មហារាជ** បពិត្រមហារាជ ឯមុទ្ធគោសតិនោះមានសេចក្ដីសម្ដែងថា សតិណា ១ ដែលកើតឡើងដល់បុគ្គលណាដែលបានសរសេរសំបុត្រកំណត់កត់ទុកហើយភ្លេចទៅ លុះគ្រាក្រោយបានឃើញសំបុត្រនោះហើយ ទើបមានស្មារតីរលឹកឃើញថា អក្សរសំបុត្រនេះអាត្មាបានសរសេរទុកជាលំដាប់នៃសំបុត្រនេះ ស្មារតីយ៉ាងនេះបានឈ្មោះថា មុទ្ធគោសតិ សូមមហាបពិត្រស្ដេចជ្រាប ។

**ម. កបំ គណនាគោសតិ** បពិត្រព្រះថេរដ៏បម្រើន ចុះគណនាគោសតិ ៗ ទី ១២ នោះ តើមានសេចក្ដីសំដែងដូចម្ដេចលោកម្ចាស់ ។

**ន. មហារាជ** បពិត្រមហារាជ ឯគណនាគោសតិនោះមានសេចក្ដីសម្ដែងថា សតិណា ១ ដែលតែងកើតឡើងដល់បុគ្គលដែលជាអ្នករាប់គណនានូវវត្ថុទាំងពួង មានប្រមាណ

ច្រើនដោយគំនូសកំណត់ទើបរាប់បាន សតិយ៉ាងនេះបាន ឈ្មោះថា គណនាគោសតិ សូមស្តេចជ្រាប ។

**ម. កថំ ធារណាគោសតិ** បពិត្រព្រះនាគសេនដ៏ចម្រើន ចុះសាធារណាគោសតិ ៗ ទី ១៣ នោះ តើមានប្រការដូចម្តេច ។

**ន. មហារាជ បពិត្រមហារាជ** ឯធារណាគោសតិនោះ មានអធិប្បាយជាសេចក្តីសង្ខេបថា សតិណា ១ ដែលតែង កើតឡើងដល់បុគ្គលដែលជាអ្នកទ្រទ្រង់ទុកនូវសេចក្តីទាំងពួង បានច្រើន សតិនេះឯងបានឈ្មោះថា ធារណាគោសតិ សូម ទ្រង់ជ្រាប ។

**ម. កថំ ភាវនាគោសតិ** បពិត្រព្រះថេរដ៏ចម្រើន ចុះ ភាវនា-គោសតិ ៗ ទី ១៤ នោះ តើមានប្រការដូចម្តេច ។

**ន. មហារាជ** បពិត្រមហារាជ ឯភាវនាគោសតិនោះ មានសេចក្តីថា សតិណា ១ ដែលកើតឡើងដល់ភិក្ខុណា ១ ដែលបានសម្រេចនូវបុព្វេនិវាសានុស្សតិញាណ គឺសេចក្តីដឹង និងរលឹកបាន នូវខន្ធសន្តានដែលកើតហើយក្នុងកាលមុន ៗ

គឺរលឹកជាតិបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ដរាបដល់ច្រើន ជាតិទៅ សតិនោះឯង បានឈ្មោះថា ភាវនាគោសតិ សូម មហាបពិត្រស្តេចជ្រាប ។

**ម. កថំ បោដ្ឋកនិពន្ធនតោ សតិ** បពិត្រព្រះថេរដ៏ចម្រើន ចុះសតិទី ១៥ នោះតើនឹងមានសេចក្ដីអធិប្បាយដូចម្ដេចលោក ម្ចាស់ ។

**ន. មហារាជ** បពិត្រមហារាជ ឯសតិទី ១៥ ដែលហៅ ថា បោដ្ឋកនិពន្ធនតោសតិនេះ មានសេចក្ដីថា សតិឯណា ១ ដែលតែងកើតឡើងដល់រាជបុរសជាខ្ញុំរាជការ ដែលរលឹកដល់ ព្រះរាជានុសាសនីកថាដែលបានកត់ត្រាព្រះរាជដីកាទុកក្នុងស្លឹក រឹតហើយជាស្រេច លុះដល់ត្រូវការវេលាណាហើយ ក៏នាំយក មកមើលនូវព្រះរាជដីកានោះទើបរលឹកចាំបានគ្រប់កន្លែងឡើង បពិត្រមហារាជ សតិយ៉ាងនេះបានឈ្មោះថា បោដ្ឋកនិពន្ធន- គោសតិ សូមស្ដេចជ្រាប ។

**ម. កថំ ឧបនិក្ខេបតោសតិ** បពិត្រព្រះថេរដ៏ចម្រើន ចុះ សតិទី ១៦ នោះតើដូចម្ដេច ។

**ន. មហារាជ** បពិត្រព្រះបរមរាជាធិរាជ ឯសតិទី ១៦ ដែលហៅថា ឧបនិក្ខេបគោសតិនោះ មានសេចក្ដីថា សតិណា ១ ដែលតែងកើតឡើងដល់ជនដែលបានឃើញនូវទ្រព្យដែលខ្លួនតាំងទុកហើយរលឹកនឹកឃើញសព្វគ្រប់ចំពូក សតិយ៉ាងនេះបានឈ្មោះថា ឧបនិក្ខេបនគោសតិ សូមស្ដេចជ្រាប ។

**ម. កបំ អនុភូតគោសតិ** បពិត្រព្រះថេរដ៏ចម្រើន ចុះសតិទី ១៧ នោះតើដូចម្ដេច លោកម្ចាស់ ។

**ន. មហារាជ** បពិត្រមហារាជ ឯសតិទី ១៧ ដែលហៅថាអនុភូតគោសតិនោះមានសេចក្ដីថាសតិណា១ដែលកើតឡើងដល់បុគ្គល ដែលជាអ្នករលឹកដល់រូបដែលខ្លួនធ្លាប់បានឃើញ រលឹកដល់សំឡេង រលឹកដល់ក្លិន រលឹកដល់រស រលឹកដល់ផោដ្ឋព្វារម្មណ៍ ដែលខ្លួនធ្លាប់បានស្ដាប់ បានធុំបានភ្លក់ និងធ្លាប់បានពាល់ត្រូវហើយក្នុងកាលមុន សតិយ៉ាងនេះបានឈ្មោះថា អនុភូតគោសតិ បពិត្រសម្ដេចមហារាជ ឯសតិដែលនឹងកើតឡើងដោយអាការ ១៧ ស្ថាននេះ សូមមហាបពិត្រស្ដេចទ្រង់ជ្រាបដោយបការដូច្នេះ ។

**ម. កល្លោសិ ភន្តេ** បពិត្រព្រះនាគសេនដ៏ចម្រើន លោកម្ចាស់ក៏ជាអ្នកប្រាជ្ញប្រាកដពិតហើយ ព្រោះមានប្រាជ្ញាវាងវៃណាស់ បេះដោះប្រស្នាស្រួលឥតមានទាស់ ខ្ញុំក៏អស់សង្ស័យហើយ ។

## វិសេសបញ្ហា ៗ ទី ២

ព្រះបរមក្សត្រាធិរាជ ស្តេចទ្រង់ត្រាស់សួរទៅ ព្រះនាគសេនថេរក្នុងប្រស្នាទី ២ ក្នុងវគ្គទី ៧ ថា បពិត្រព្រះនាគសេនថេរដ៏ចម្រើន លោកម្ចាស់បានពោលថា អ្នកឯណា ១ ប្រព្រឹត្តធ្វើអំពើបាបកម្មមកយូរយារណាស់ហើយដរាបដល់អាយុ ១០០ ឆ្នាំ វេលាដល់ជិតមរណាសន្នកាលជិតនឹងស្លាប់ ក៏បានតាំងតម្កល់ស្មារតីល្អ រលឹកខ្ជាប់ទៅក្នុងពុទ្ធគុណតែមួយពេលប៉ុណ្ណោះ ជាអ្នកនោះឯងគង់នឹងបានទៅកើត ឯស្ថានទេវលោកជាប្រាកដមិនខាន ពាក្យយ៉ាងនេះខ្ញុំម្ចាស់រកតាំងចិត្តជឿមិនកើត ១ ។ ម្យ៉ាងទៀតលោកម្ចាស់បានពោលថា អ្នកឯណា ១ តែជ្រុលខ្លួនបានប្រព្រឹត្តធ្វើអំពើបាណាតិបាតហើយកុំថាឡើយច្រើនដង

Websites: WatKhemaraRatanaram.org or WatKhmers.org

សូម្បីធ្មើតែម្តង អ្នកនោះឯងក៏គង់នឹងច្បុតទៅកើតក្នុងស្ថាននរកមិនខាន ពាក្យនេះខ្ញុំមិនជឿ ១ សូមលោកម្ចាស់ប្រែស្រាយអធិប្បាយសេចក្តីនេះ ឱ្យខ្ញុំស្តាប់បានចូលចិត្តផងមើល ។

ព្រះនាគសេនថេរ ថ្វាយព្រះពរទៅវិញថា តំ កឹ មញ្ញសិ មហារាជ បពិត្រសម្តេចមហារាជ ចុះសេចក្តីនេះព្រះអង្គទ្រង់ព្រះតម្រិះដូចម្តេចទៅ អាត្មាភាពសូមថ្វាយព្រះពរសួរថា ដុំថ្មនោះតូចតិចទេប្រមាណជាប៉ុនគ្រាប់ពោតឬគ្រាប់ម្រេច បុគ្គលយកទៅដាក់តម្កល់ផ្ទាល់លើខ្នងទឹកដោយឥតមានទូកឬវត្ថុអ្វី សម្រាប់ទ្រាប់ទ្រអំពីខាងក្រោមនៃដុំថ្មនោះទេ បំណែកថ្មនោះនឹងអាចអណ្តែតទៅលើខ្នងទឹកបានឬមិនបានទេ មហាបពិត្រ ។

**ម. ន ហិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ឯដុំថ្មនោះមិនអាចនឹងអណ្តែតលើខ្នងទឹកផ្ទាល់ ដោយឥតមានវត្ថុតម្កល់នោះបានឡើយលោកម្ចាស់ ។

**ន. កិន្នុ វាហសតំបិ បាសាណំ** បពិត្រមហារាជ ហេតុអ្វីក៏មិនអាចអណ្តែតបាន ប្រសិនបើថ្មមានប្រមាណច្រើន

Websites: WatKhemaraRatanaram.org or WatKhmers.org

ចំនួន ១០០ រទេះ តែគេបានលើកយកទៅដាក់តម្កល់លើទូកឬសំពៅហើយបណ្តែតបន្សាត់ទៅលើខ្នងទឹក តើថ្មនោះអាចនឹងអណ្តែតទៅបានឬទេមហាបពិត្រ ។

**ម. អាម ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ថ្មនោះអាចអណ្តែតទៅបាន ព្រោះមានទូកឬសំពៅទ្រទ្រង់ពីខាងក្រោមលោកម្ចាស់ ។

**ន. យថា មហារាជ** បពិត្រមហារាជ សូមព្រះអង្គទ្រង់សណ្តាប់អាត្មាភាពនឹងប្រៀបថ្វាយ ថាឯកុសលធម៌ទាំងពួងប្រៀបដូចជាទូក ឬសំពៅមានសភាពតែងអណ្តែតទៅលើគង្គាបាន ឯអកុសលកម្មនោះសោតប្រៀបដូចជាដុំថ្មទាំងពួង មានសភាពតែងលង់លិចបុះទៅក្នុងគង្គា ក៏ធម្មតាដុំថ្មទាំងពួងតែងមានភារធ្ងន់ជាបំផុតជាងសភាវៈឯទៀត កុំថាឡើយថ្មនោះធំឬច្រើន សូម្បីដុំថ្មទាំងនោះតូចតាចបន្តិចបន្តួចក្តីតែគ្មានគ្រឿងទ្រពីក្រោមហើយ ដុំថ្មទាំងនោះក៏មិនអាចនឹងអណ្តែតទឹកទៅបានប្រៀបដូចអំពើអកុសលទាំងពួងដែលបុគ្គលបានធ្វើហើយ កុំ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឋាឡើយបាំធ្វើច្រើនផង ទោះបីធ្វើតែបន្តិច ឬតែម្តងហើយ គ្មានបានធ្វើអំពើកុសលអ្វីដទៃ ជាឧបាយជាគ្រឿងគាំទ្រសោះ បុគ្គលនោះនឹងអាចដោះខ្លួន បេញឱ្យផុតពីអបាយភូមិនោះមិនរួចឡើយ ព្រោះអកុសលកម្មនេះមានភារៈជាគ្រឿងធ្ងន់តែងលង់តែងលិចបុះជាធម្មតា ។ ចំណែកខាងកុសលកម្មវិញ ប្រៀបដូចជាទូកឬសំពៅ ធម្មតាទូកទាំងពួងមានសភាពស្រាលតែងអណ្តែតទៅលើទឹកបាន កុំឋាទូកនោះតូចស្រាលទោះបីទូកនោះធំធ្ងន់យ៉ាងណាក្តី ក៏គង់នឹងអណ្តែតទៅលើខ្នងគង្គាបាន ហើយមិនអណ្តែតទៅតែសំបកទូកទទេឡើយ អាចទ្រទ្រង់ដឹកនាំនូវវត្ថុដែលគេផ្ទុកទៅជាមួយផងបាន ប្រៀបដូចកុសលទាំងពួងដែលបុគ្គលបានធ្វើហើយ កុំឋាឡើយខ្លួនសត្វនោះបានប្រព្រឹត្តធ្វើតែអំពើកុសលកម្មមួយមុខដ៏បរិសុទ្ធស្អាតល្អ ប្រសិនបើខ្លួនសត្វនោះ កាលជាន់មុនភាន់ច្រឡំទៅប្រព្រឹត្តធ្វើអំពើអកុសលឱ្យជ្រុលហួសទៅហើយ ៗ ទើបបែរត្រឡប់មកប្រព្រឹត្តធ្វើអំពើសុចរិតជាខាងក្រោយវិញ កុសលផលសុចរិតនោះឯង ក៏គង់

មិនលះបង់បោលសត្វនោះឡើយ អាចទ្រទ្រង់នូវម្ចាស់បុណ្យនោះឱ្យអណ្តែតឡើងទៅកើតក្នុងសុគតិភពបាន ព្រោះកុសលកម្មនោះមានសភាពជាគ្រឿងអណ្តែតទៅខាងលើនោះឯង ។ សេចក្តីនេះប្រហែលគ្នានឹងបទគាថា ដែលលោកបានពោលទុកមកថាដូច្នេះ

**ភតិកានំ យថា នាវា អប្បមាណគរុភារា**
**អតិភារំ សមាធាយ អណ្ណវេ អវសីទតិ ។**
**ឯវមេវ នរោ បាបំ ថោកំ ថោកម្បិ អាចិនំ**
**អតិភារំ សមាធាយ និរយេវ និមុជ្ជតិ ។**
**តស្មា កិញ្ចិ ឥមំ នាវំ សិត្តា តេ លហុមេស្សតិ**
**សុតិត្ថំ បរតោ បារំ និព្វានស្សានុបាទិកន្តិ ។**

សេចក្តីថា ទូកឬសំពៅតែងទ្រទ្រង់ឬផ្ទុកនូវភារៈជាទម្ងន់ហួសប្រមាណហើយ គង់នឹងលង់លិចចុះទៅកាន់បាតសមុទ្រមិនខាន ព្រោះតែផ្ទុកនូវទំនិញរបស់អ្នកឈ្មួលទាំងឡាយច្រើនសេចក្តីនេះមានឧបមាដូចម្តេចមិញ ថាមានឧបមេយ្យដូចនរជន

ទាំងពួង ដែលខំសន្សំធ្វើនូវអំពើបាបកម្មបន្តិច ៗ ក៏គង់នឹងលង់លិចបុះទៅកាន់ទីនរកមិនខាន ព្រោះតែផ្ទុកនូវបាបកម្មដ៏ធ្ងន់នោះឯង ហេតុដូច្នោះនរជាតិប្រុសស្រីគួរគប្បីស្តារនូវទូកពោលគឺអត្តភាពដែលមានបាបបន្តិចបន្តួចនោះ បេញឱ្យស្រាលនឹងបានដល់នូវត្រើយខាងឆាយ ដែលមានកំពង់បតដ៏ល្អប្រពៃពោលគឺអមតមហានិព្វាន ដែលមិនមានសេសសល់នៃកិលេសតិចតួចឡើយ បពិត្រសម្តេចមហារាជ អាត្មាភាពអធិប្បាយថ្វាយសេចក្តីមកប៉ុណ្ណោះ សូមមហាបពិត្រស្តេចជ្រាប ។

**ម. កល្លោសិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ពេញជាអ្នកឆ្លៀវឆ្លាសពេកណាស់ ខ្ញុំអស់សង្ស័យហើយ ។

## អនាគតបញ្ហា ។ ទី ៣

ព្រះបាទសម្តេចមិលិន្ទ្រាធិបតីស្តេចទ្រង់សួរទៅ ព្រះនាគសេនថេរក្នុងប្រស្នាទី ៣ ក្នុងវគ្គទី ៧ នេះថា បពិត្រព្រះនាគសេនម្ចាស់ដ៏ចម្រើន សព្វថ្ងៃនេះប្រហែលជាលោកម្ចាស់ខំព្យាយាមដើម្បីលះបង់នូវអតីតទុក្ខ គឺទុក្ខដែលកន្លងទៅហើយនោះឬ ។

**ន. ន ហិ មហារាជ** បពិត្រមហារាជ អាត្មាភាពមិនមែន ព្យាយាមដើម្បីលះបង់នូវទុក្ខក្នុងអតីតនោះទេ ។

**ម. កឹ បន ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន បើលោកម្ចាស់ មិនព្យាយាមដើម្បីរំលត់ទុក្ខក្នុងអតីតនោះទេ ប្រហែលជាលោក ម្ចាស់ព្យាយាមនឹងរំលត់នូវអនាគតទុក្ខ គឺទុក្ខដែលមិនទាន់មាន មកនោះឬ ។

**ន. ន ហិ មហារាជ** បពិត្រមហារាជ អាត្មាភាពមិនមែន ព្យាយាមដើម្បីលះបង់នូវទុក្ខក្នុងអនាគតនោះទេ ។

**ម. កឹ បន ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន បើលោកម្ចាស់ មិនព្យាយាមដើម្បីរំលត់ទុក្ខក្នុងអតីតនិងអនាគតនោះទេ ប្រ ហែលជាលោកម្ចាស់ព្យាយាមនឹងរំលត់នូវបច្ចុប្បន្នទុក្ខគឺទុក្ខក្នុង បច្ចុប្បន្ននេះឬអ្វី ។

**ន. ន ហិ មហារាជ** បពិត្រមហារាជ អាត្មាភាពមិនមែន ព្យាយាមបំរុងនឹងរំលត់ទុក្ខក្នុងបច្ចុប្បន្ននេះទេ ។

**ម. យទិ តុម្ហេ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ថាបើ

លោកម្ចាស់មិនព្យាយាមដើម្បីនឹងរំលត់នូវអតីតទុក្ខ អនាគតទុក្ខនិងបច្ចុប្បន្នទុក្ខទេ ចុះសព្វថ្ងៃនេះព្រះថេរធ្វើសេចក្ដីព្យាយាមដើម្បីហេតុអ្វី ។

**៦. កិត្តិ មហារាជ** បពិត្រព្រះរាជសម្ភារ ចុះហេតុដូចម្ដេចក៏មហាបពិត្រស្ដេចទ្រង់សួរដូច្នេះទៀត សេចក្ដីនេះអាត្មាភាពបានថ្វាយព្រះពររួចអំពីមុនមកហើយតើ ថាអាត្មាភាពបួសសព្វថ្ងៃនេះ ដើម្បីនឹងធ្វើសេចក្ដីព្យាយាមរំលត់នូវគំនរទុក្ខនេះ នឹងមិនឱ្យទុក្ខដទៃកើតឡើងបាននោះឯង សូមមហាបពិត្រជ្រាប ។

**ម. អត្ថិ បន ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន បើដូច្នោះលោកម្ចាស់ធ្វើព្យាយាមសព្វថ្ងៃនេះ ដើម្បីនឹងរំលត់នូវទុក្ខដែលមិនទាន់មានមកនោះឯងឬ ។

**៦. អាម មហារាជ** បពិត្រសម្ដេចមហារាជ អាត្មាភាពខំព្យាយាមនឹងបន្ទោបង់នូវអនាគតទុក្ខ ដូចព្រះរាជឱង្ការនេះឯង សូមទ្រង់ជ្រាប ។

**ម. តុម្ហេ ខោ ភន្តេ** បពិត្រព្រះនាគសេនថេរដ៏ចម្រើន លោកម្ចាស់ឆ្លៀវឆ្លាសពេកណាស់ ពេញជាបណ្ឌិតយ៉ាងឆើត យ៉ាងឆ្នើមក្នុងលោកនេះ តែខ្ញុំមានសេចក្ដីសង្ស័យពេកនឹងភាសិតរបស់លោកម្ចាស់សម្ដែងថា អង្គលោកម្ចាស់សព្វថ្ងៃនេះ ខំព្យាយាម ដើម្បីនឹងរំលត់ឬបន្ទោបង់នូវទុក្ខទាំងឡាយដែលមិនទាន់មានមក បុះបើទុក្ខទាំងនោះមិនទាន់កើតឡើងទេ លោកម្ចាស់ប្រឹងធ្វើព្យាយាមកំចាត់បង់នូវវត្ថុអ្វី សេចក្ដីនេះគួរឱ្យសង្ស័យពេក សូមលោកម្ចាស់អធិប្បាយឱ្យងាយស្ដាប់បន្តិចមកមើល ។

**ន. អត្ថិ បន វោ មហារាជ** បពិត្រសម្ដេចមហារាជ បុះក្នុងដែនគររបស់មហាបពិត្រ ប្រហែលជាមានមហាក្សត្រជាសត្រូវឬជាបច្ចាមិត្រឯណានីមួយ មានប្រាថ្នាចង់បានតែងលើកមកបៀតបៀនដណ្ដើមយកដែរឬ មហាបពិត្រ ។

**ម. អាម ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន ស្ដេចដែលជាសត្រូវនោះតែងមាន លោកម្ចាស់ ។

**ឥ. កឹ នុ ខោ មហារាជ** បពិត្រមហាក្សត្រាធិរាជ ចុះបើទ្រង់មានព្រះរាជឱង្ការត្រាស់ថា ស្រុកនគររបស់ព្រះអង្គតែងមានមហាបច្ចាមិត្រជាសត្រូវ មានបំណងចង់បានដោយពិត ចុះព្រះអង្គនឹងអត់ទ្រាំចាំឱ្យសត្រូវទាំងនោះ លើកពួកពលសេនាទាហានចូលមកដល់ផ្ទាល់តួព្រះអង្គហើយ ទើបបាត់បែងឱ្យជីកគូធ្វើកំពែង ធ្វើទ្វារស្រុក ធ្វើទ្វារនគរ លើកពួនភាគបន្ទាយនឹងនាំមកនូវស្រូវទាំងពួងបំរុងទុកធ្វើស្បៀងអាហារក្នុងវេលាជាមួយនឹងសត្រូវចូលមកនោះឬអ្វីព្រះអង្គ ។

**ម. ន ហិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន ខ្ញុំមិនបណ្តោយចាំឱ្យសត្រូវលុកលុយចូលមកដល់ហើយ ទើបបាត់បែងការពារស្រុកដូច្នោះទេ ត្រូវបាត់បែងរៀបចំបង្ការទុកជាមុនឱ្យស្រេចទើបបាន លោកម្ចាស់ ។

**ឥ. កឹ តុម្ហេ មហារាជ** បពិត្រមហារាជ បើមិនដូច្នោះព្រះអង្គនឹងបណ្តោយសត្រូវ ឱ្យចូលមកដល់ទីចំពោះព្រះភក្ត្រព្រះអង្គ ទើបទ្រង់ត្រាស់បង្គាប់ឱ្យបង្ហាត់ពលដំរី ពលសេះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ពលរទេះ ពលធ្នូ ពលសស្រ្តាវុធ មានដាវនិងលំពែងជាដើមឬអ្វី មហាបពិត្រ ។

**ម. ន ហិ ភន្តេ** មិនមែនដូច្នោះទេលោកម្ចាស់ យើងត្រូវបង្ហាត់បតុរង្គសេនានោះបំរុងទុកជាមុនឱ្យស្រេចទើបបាន ។

**ន. កិស្សត្ថាយ** ប្រយោជន៍ដើម្បីអ្វីក៏បង្ហាត់សេនាទាហានទុកជាមុន មហាបពិត្រ ។

**ម. អនាគតានំ ភយានំ** បដិឃាហនត្ថាយ បពិត្រព្រះបវរដ៏ចម្រើន បានជាប្រៀនប្រដៅពួកពលទាំងនោះទុកជាមុន ដើម្បីនឹងការពារនូវសេចក្ដីភ័យអន្តរាយដែលមិនទាន់មានមក នោះឯងលោកម្ចាស់ ។

**ន. អត្ថិ បន មហារាជ** បពិត្រមហារាជ បុះសេចក្ដីភ័យអន្តរាយនៅខាងមុខនោះមុខជានឹងមានមកឬអ្វីព្រះរាជសម្ភារ ។

**ម. អត្ថិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ឯភ័យអន្តរាយនោះតែងមានមករឿយ ៗ មិនខាន ។

**ន. តុម្ហេ ខោ មហារាជ** បពិត្រមហារាជ ព្រះអង្គជាបុគ្គល

ប្រកបដោយបញ្ញាញាណដ៏ប្រពៃក្រៃពេក ទ្រង់បេះបាត់ការបំរុងទុកដើម្បីឃាត់ភ័យអន្តរាយ ដែលមិនទាន់មានមកជាមុននោះត្រូវល្អណាស់ សេចក្ដីនេះមានឧបមាដូចម្ដេចមិញ ជាមានឧបមេយ្យដូចជា អាត្មាភាពដែលតាំងការព្យាយាមបន្ទោបង់នូវទុក្ខនេះ ដើម្បីមិនឱ្យទុក្ខដទៃកើតឡើងបាននោះឯង ។

**ម. ភិយ្យោ ឧបមំ** សូមលោកម្ចាស់ឧបមាឱ្យប្រើនតទៅទៀតមើល ។

**ន. តំ កឹ មញ្ញសិ មហារាជ** បពិត្រសម្ដេចមហារាជ សេចក្ដីនេះព្រះអង្គនឹងទ្រង់ព្រះតម្រិះដូចម្ដេចទៅ អាត្មាភាពនឹងថ្វាយព្រះពរសួរថា មហាបពិត្រស្ដេចតែងសោយនូវព្រះឧទករសជាធម្មតា បុះដែលព្រះអង្គនឹងសោយព្រះឧទកនោះទ្រង់បង្អង់ចាំស្រេកខ្លាំងហើយ ទើបបាត់ការឱ្យពួកពលជីកអណ្ដូងលើកស្រះបោក្ខរណីនិងស្រះធំ ៗ ទាំង ៤ ហើយដងយកទឹកនោះមកទើបទ្រង់តាំងព្រះហឫទ័យថា អញនឹងផឹកនូវទឹកដូច្នេះឬអ្វីមហាបពិត្រ ។

**ម. ន ហិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន មិនដែលដូច្នោះទេ ធម្មតាមនុស្សតែងផឹកទឹកតែរាល់ពេល គេត្រូវធ្វើនូវទីសម្រាប់តម្កល់នូវទឹកគឺគេជីកអណ្តូងលើកស្រះទុកជាមុន វេលាណាត្រូវការផឹក គេដងមកផឹកភ្លាម មិនអាចទៅជីកឱ្យទាន់ស្ពានដោះទេ លោកម្ចាស់ ។

**ន. កិស្សត្ថាយ** ហេតុដូចម្តេចក៏បាំធ្វើឱ្យទុកស្ពានដោះទុកជាមុន ។

**ម. អនាគតានំ ភន្តេ បិបាសានំ** បពិត្រព្រះថេរដ៏ចម្រើន បានជាធ្វើទីសម្រាប់តម្កល់ទឹកទុកជាមុនដោះ ដើម្បីនឹងការពារនូវសេចក្តីស្រេកទឹកដែលមិនទាន់មានមកដោះឯង ។

**ន. អត្ថិ មហារាជ** បពិត្រមហារាជ កិច្ចដែលស្រេកទឹកដោះត្រូវមានមកខាងមុខមិនខានឬអ្វី ។

**ម. អត្ថិ ភន្តេ** កិច្ចដែលស្រេកទឹក ដែលមិនទាន់មានមកដោះ នឹងមានមកដល់ប្រាកដ លោកម្ចាស់ ។

**ន. អតិបណ្ឌិតា** មហាបពិត្រស្តេចមានព្រះបញ្ញាបារមីក្រៃ

Websites: WatKhemaraRatanaram.org or WatKhmers.org

ពេកណាស់ ព្រោះទ្រង់បេះបាត់បែងនូវឱទកស្ពានទុកដើម្បីនឹងបន្ទោបង់នូវសេចក្តីស្រេកទឹក ដែលមិនទាន់មានមកនោះទុកជាមុន សេចក្តីនេះមានគួរនាដូចម្តេចមិញ ឋាមានគួរនាដូចរូបអាត្មាភាពដែលបួសហើយ ខំព្យាយាមប្រហារនូវទុក្ខនេះ ដើម្បីមិនឱ្យទុក្ខដទៃកើតឡើងបាននោះឯង សូមស្តេចជ្រាប ។

**ម. ភិយ្យោ ឧបមំ ករោហិ** បពិត្រព្រះថេរដ៏ចម្រើន សូមនិមន្តលោកម្ចាស់ធ្វើសេចក្តីឧបមាឱ្យច្រើនជាងនេះតទៅទៀតមើល។

**ន. តំ កឹ មញ្ញសិ មហារាជ** បពិត្រមហារាជ សេចក្តីនេះព្រះអង្គនឹងទ្រង់ព្រះដំរិះដូចម្តេចទៅ អាត្មាភាពសូមថ្វាយព្រះពរសួរ លុះតែមហាបពិត្រទ្រង់បង់សោយស្រូវសាលី កាលណាទើបបានត្រាស់បង្គាប់ ឱ្យភ្ជួរស្រែសាបព្រោះស្រូវសាលីកាលនោះឬដូចម្តេច ។

**ម. ន ហិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន មិនដូច្នោះទេ ខ្ញុំព្រះករុណាចាត់ការឱ្យធ្វើបម្រុងទុកជាមុនឱ្យហើយ ។

**ន. កិស្សត្ថាយ** បពិត្រមហារាជ ព្រះអង្គទ្រង់ចាត់ការឱ្យធ្វើបម្រុងទុកជាមុនដើម្បីប្រយោជន៍ដូចម្តេច ។

**ម. អនាគតានំ ពុទ្ធានំ បដិញាបាសាយ** បពិត្រព្រះបេរដ៏បម្រើន ខ្ញុំព្រះករុណាបាត់ការឱ្យធ្វើបម្រុងទុកជាមុន ដើម្បីនឹងទទួលទានឱ្យទាន់បំណាច់ដែលនឹងមានក្នុងខាងមុខ ។

**ឥ. អត្ថិ បន មហារាជ** បពិត្រមហារាជ ឯកិច្ចស្រែកឃ្លានត្រូវការបរិភោគដែលមិនទាន់មានមកនោះ នឹងមានមកជាខាងមុខមិនខានឬដូចម្តេច ។

**ម. អត្ថិ ភន្តេ** បពិត្រលោកម្ចាស់ដ៏បម្រើន ឯការបរិភោគភោជនាហារទៅខាងមុខនោះនឹងមានមកមិនខានលោកម្ចាស់ ។

**ឥ. អតិបណ្ឌិតា** បពិត្រសម្តេចមហារាជ ព្រះអង្គជាបុគ្គលដ៏ឆ្លៀវឆ្លាស ជាបណ្ឌិតដ៏ក្រៃលែង ទ្រង់បេះបាត់បែងការងារទុកដើម្បីលះបង់នូវសេចក្តីស្រែកឃ្លានដែលមិនទាន់មានមក សេចក្តីនេះប្រៀបដូចការព្យាយាមរបស់អាត្មាភាពនោះឯងសូមទ្រង់ជ្រាប ។

**ម. កល្លោសិ ភន្តេ** បពិត្រលោកម្ចាស់ដ៏បម្រើន លោកជាបុគ្គលឆ្លៀវឆ្លាសប្រពៃពេក បេះឧបមានុបមេយ្យគួរឱ្យចូលចិត្តស្តាប់បាន ខ្ញុំអស់សង្ស័យហើយក្នុងរឿងនេះ។

## ទូរព្រហ្មលោកបញ្ហា ។ ទី ៤

ព្រះមហាក្សត្រស្ដេចទ្រង់ត្រាស់បុច្ឆាទៅព្រះនាគសេនថេរ ក្នុងបញ្ហាទី ៤ ក្នុងវគ្គទី ៧ តទៅទៀតថា បពិត្រព្រះថេរដ៏ចម្រើន កីវ ទូរោ ឥតោ ព្រហ្មលោកោ ទីស្ថានព្រហ្មលោកនោះ តើមានចម្ងាយប៉ុន្មានអំពីមនុស្សលោកនេះទៅ លោកម្ចាស់ ។

**ឥ. ទូរោ ខោ មហារាជ** បពិត្រមហារាជ រីឯវិមានស្ថានព្រហ្មលោកនោះ ឆ្ងាយដាច់ស្រយាលក្រៃពេកណាស់ អំពីមនុស្សលោកនេះឡើងទៅ មានប្រមាណដល់ ៤៨,០០០ យោជន៍ ហើយមានពាក្យលោកប្រៀបទុកមកថា ដុំថ្មមួយដុំមានទំហំប្រមាណប៉ុនដំបូលផ្ទះ ដុំនោះធ្លាក់បុះមកពីស្ថានព្រហ្មលោកនោះ មកដល់ផែនដីនេះអស់ពេលបំនួន ៤ ខែគត់ ទើបដល់មក សូមមហារាជជ្រាប ។

**ម. ភន្តេ នាគសេន** បពិត្រព្រះនាគសេនដ៏ចម្រើន លោកម្ចាស់បានពោលពីជាន់មុនថា មានភិក្ខុដែលមានឫទ្ធានុភាពជាអ្នកមានចិត្តស្ទាត់ជំនាញដោយឈានសមាបត្តិ បានហោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

ឡើងអំពីមនុស្សលោកទៅកាន់ព្រហ្មលោកឆាយ តែមួយរំពេច បានដល់ទៅ ប្រហែលគ្នានឹងបុរសដែលមានកំឡាំងលាតដៃចេញទៅនិងបត់ដៃចូលមកវិញប៉ុណ្ណោះឯង ពាក្យលោកម្ចាស់នេះខ្ញុំមិនអាចជឿបានទេ ព្រោះថាទីឆ្ងាយដល់ទៅមួយរយយោជន៍ ហេតុអ្វីក៏ទៅឆាប់ម្លេះ ។

**ន. កុហិំ បន មហារាជ** បពិត្រមហារាជ ជាតិភូមិដែលព្រះអង្គប្រសូតនោះតើមាននៅក្នុងទីឯណា ។

**ម. អត្ថិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន ឯទីកន្លែងដែលខ្ញុំកើតនោះមាន ទីនោះជាកោះឈ្មោះថាអលសណ្ឌទ្វីប សូមលោកម្ចាស់ជ្រាប ។

**ន. កីវ ទូរោ មហារាជ** បពិត្រមហារាជ អលសណ្ឌទ្វីបនោះមានចម្ងាយប៉ុន្មានយោជន៍អំពីទីនេះទៅ មហាបពិត្រ ។

**ម. អត្ថិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន ឯអលសណ្ឌទ្វីបនោះមានចម្ងាយ ២០០ យោជន៍ អំពីទីនេះទៅ សូមលោកម្ចាស់ជ្រាប ។

**ន. អភិជានាសិ** បពិត្រព្រះរាជសម្ភារ ព្រះអង្គស្តេចទ្រង់ចាំបាកដហើយទីនោះ បុះព្រះអង្គនឹងអាចរលឹកដល់ការងារដែលព្រះអង្គបានធ្វើទុកនៅក្នុងទីនោះបានឬទេ ។

**ម. អាម ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំអាចរលឹកបានដោយងាយ ។

**ន. លហុំ ខោ មហារាជ** បពិត្រព្រះរាជសម្ភារព្រះអង្គស្តេចទ្រង់រលឹកទៅកាន់ទីឆ្ងាយបម្ងាយ ២០០ យោជន៍ បានក្នុងមួយរំពេចហ្ន៎ មហាបពិត្រ ។

**ម. កល្លោសិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន លោកម្ចាស់ជាអ្នកឆ្លៀវឆ្លាសប្រពៃពេក បេះប្រៀបពន្យល់ដោយស្រួលងាយស្តាប់ណាស់ ។

## ព្រហ្មលោកកស្មិរនគរបញ្ហា ។ ទី ៩

ព្រះបាទមិលិន្ទស្តេចទ្រង់សួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៩ នេះថា បពិត្រព្រះនាគសេនដ៏ចម្រើន មនុស្សម្នាក់ធ្វើកាលកិរិយាស្លាប់អំពីទីនេះ ហើយទៅកើតឯស្ថានព្រហ្មលោក

មនុស្សម្នាក់ទៀតធ្វើកាលកិរិយាអំពីទីនេះដែរ តែនៅកើតក្នុងស្ថានមនុស្ស ត្រឹមក្រុងកសិ្មរនេះ បណ្ដាមនុស្សទាំងពីរពួកនេះ មនុស្សពួកណាទៅកើតមុន ពួកណាទៅកើតក្រោយ លោកម្ចាស់ ។

ព្រះនាគសេនថ្វាយព្រះពរថា សមកំ មហារាជ បពិត្រមហារាជ ឯមនុស្សទាំងពីរក្រុមនេះទៅកើតស្មើគ្នាព្រមគ្នា សូមស្ដេចជ្រាប ។

**ម. ឧបមំ ករោហិ** ចុះហេតុអ្វីក៏បានជាទៅកើតស្មើគ្នា បើទីនោះមិនស្មើគ្នាទេ លោកម្ចាស់ សូមលោកម្ចាស់ឧបមាជាសេចក្ដីបន្តិចមកមើល ។

**ន. កុហឹ បន មហារាជ** បពិត្រសម្ដេចមហារាជ អាត្មាភាពសូមថ្វាយព្រះពរសួរមហាបពិត្រថា ចុះជាតិភូមិគឺភូមិដែលព្រះអង្គទ្រង់ប្រសូតនោះ តើនៅត្រង់ទីណាមានឈ្មោះថាអ្វី ។

**ម. អត្ថិ ភន្តេ** បពិត្រព្រះថេរដ៏បម្រើន ឯស្រុកដែលខ្ញុំកើតនោះមានឈ្មោះថា កាលសិរគ្រាមនៅក្នុងកោះឈ្មោះអលសណ្ឌទ្វីប លោកម្ចាស់ ។

**ន. កីវ ទូរោ មហារាជ** បពិត្រសម្តេចមហារាជ ចុះស្រុកកាលសិរនោះមានចម្ងាយប៉ុន្មានយោជន៍អំពីទីនេះទៅ ។

**ម. ទិមត្តានិ យោជនសតានិ** បពិត្រលោកម្ចាស់ដ៏ចម្រើន អំពីទីនេះទៅ ដល់កាលសិរគ្រាមនោះ មានចម្ងាយ ២០០ យោជន៍លោកម្ចាស់ ។

**ន. កីវទូរំ មហារាជ** បពិត្រសម្តេចមហារាជ ចុះអំពីទីនេះទៅក្រុងកស្មិរនោះ តើមានចម្ងាយប៉ុន្មានយោជន៍ ។

**ម. ទ្វាទស ភន្តេ យោជនានិ** បពិត្រលោកម្ចាស់ដ៏ចម្រើន អំពីទីនេះទៅក្រុងកស្មិរនោះមានប្រមាណ ១២ យោជន៍ ។

**ន. កាលសិរគាមំ ចិន្តេហិ** សូមមហាបពិត្រស្តេចទ្រង់ព្រះចិន្តានឹកអំពីទីនេះទៅកាន់ស្រុកកាលសិរ ដែលមានចម្ងាយ ២០០ យោជន៍នោះលងមើល ។

**ម. ចិន្តិតោ ភន្តេ** ខ្ញុំបាននឹកឃើញរួចហើយលោកម្ចាស់ ។

**ន. កស្មិរនគរំ ចិន្តេហិ** សូមមហារាជស្តេចនឹកទៅក្រុងកស្មិរដែលមានចម្ងាយ ១២ យោជន៍នោះទៀតមើល ។

**ម. បិត្តិតំ ភន្តេ** ខ្ញុំបាននឹករូបហើយលោកម្ចាស់ ។

**ឥ. កតមំ នុ ខោ មហារាជ** បពិត្រមហារាជ បុះកាលដែលព្រះអង្គទ្រង់ព្រះបិត្តានឹកទៅកាន់ស្រុកទាំងពីរនោះ តើនឹកទៅដល់ស្រុកណាយូរស្រុកណាឆាប់ ។

**ម. សមកំ ភន្តេ** ស្មើតែគ្នានេះឯងលោកម្ចាស់ ។

**ឥ. ឯវមេវ ខោ មហារាជ** បពិត្រសម្តេចមហារាជ សេចក្តីនេះមានឧបមាដូចម្តេចមិញ ថាមានឧបមេយ្យដូចជាមនុស្សដែលស្លាប់អំពីទីនេះ ហើយឡើងទៅកើតឯស្ថានព្រហ្មលោក និងមនុស្សដែលស្លាប់អំពីទីនេះហើយនៅកើតក្នុងកស្មិរនគរនេះវិញ មនុស្សទាំងពីរពួកនេះក៏អាចកើតព្រមគ្នាស្មើគ្នា សូមស្តេចជ្រាប ។

**ម. ភិយ្យោ ឧបមំ ករោហិ** សូមលោកម្ចាស់ប្រៀបឧបមាថែមមកទៀតមើល ។

**ឥ. យថា មហារាជ** បពិត្រមហារាជ សេចក្តីនេះប្រៀបដូចសត្វបក្សីពីររូប បណ្តាសត្វទាំងពីរនោះជាសត្វហើរទៅដោយ

អាកាសសំដៅទៅរកទីទំលើចុងឈើ តែសត្វ ១ រូបទំនៅចុងឈើដ៏ទាប សត្វ ១ ទំនៅចុងឈើដ៏ខ្ពស់ វេលាដែលចាប់ទំនៅចុងឈើនោះក៏ទំព្រមគ្នាមិនមុនមិនក្រោយ បុះស្រមោលសត្វទាំងពីរនោះ ស្រមោលសត្វណាដល់មកផែនដីនេះមុនគេមហារាជ ។

**ម. សមកំ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ឯស្រមោលសត្វទាំងពីរនោះ មកដិតប្រាកដលើផែនដីនេះស្មើគ្នាទាំងអស់មិនមុនមិនក្រោយ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រមហារាជ សេចក្ដីនេះប្រៀបដូចមនុស្សសត្វដែលធ្វើកាលកិរិយាចាកទីនេះ ហើយឡើងទៅកើតឯស្ថានព្រហ្ម និងមនុស្សសត្វដែលធ្វើកាលកិរិយាចាកទីនេះ ហើយនៅកើតក្នុងក្រុងកស្មិរនេះ ឯអ្នកទាំងពីរនោះ គង់កើតព្រម ៗ គ្នាមិនមុនមិនក្រោយ ដូចជាស្រមាលសត្វទាំងពីររូបនោះឯង ។

**ម. ភិយ្យោ ឧបមំ ករោហិ** សូមលោកម្ចាស់ប្រៀបឧបមាឱ្យវិសេសជាងនេះតទៅទៀតមើល ។

**ន. មំ មហារាជ ឱលោកេហិ** បពិត្រមហារាជ សូមព្រះអង្គស្តេចទ្រង់ទស្សនាការទតមកខ្លួនអាត្មាភាពមើល ។

**ម. ឱលោកិតោ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន ខ្ញុំបានមើលឃើញព្រះភក្ត្រលោកម្ចាស់ច្បាស់ហើយ ។

**ន. បន្ទិមសុរិយំ ឱលោកេហិ** សូមព្រះរាជសម្ភារទ្រង់ទតព្រះនេត្រទៅត្រង់បន្ទមណ្ឌលនិងសុរិយមណ្ឌលឯអាកាសឯនោះមើល ។

**ម. ឱលោកិតោ ភន្តេ** ខ្ញុំបានមើលឃើញនូវមណ្ឌលនៃព្រះបន្ទនិងព្រះអាទិត្យនោះហើយលោកម្ចាស់ ។

**ន. តយា មហារាជ** បពិត្រមហារាជ បុះកាលដែលព្រះអង្គទ្រង់ទតព្រះនេត្រមកត្រង់អាត្មាភាពដែលនៅជិតបន្ទាប់ព្រះអង្គនេះ ហើយនិងទ្រង់ទតព្រះនេត្រទៅឯព្រះបន្ទនិងព្រះអាទិត្យ ដែលមានចម្ងាយ ៤២,០០០ យោជន៍ឯនោះ តើឯណាឆាប់ឯណាយូរជាង ។

**ម. សមសមកំ សមាបិត្តំ** លោកម្ចាស់ឯកិច្ចដែលក្រឡេក

មើលត្រង់ទៅលោកម្ចាស់ ហើយនិងមើលត្រង់ទៅព្រះចន្ទនិងព្រះអាទិត្យនោះ មិនមានឃើញមិនមានរហ័សជាងគ្នាទេគឺស្មើ ៗ គ្នា ទាំងសន្ទុះរបស់ចិត្តទៀតក៏ប្រហែល ៗ គ្នាដែរ ។

**ឥ. ឯវមេវ ខោ មហារាជ** បពិត្រសម្តេចមហារាជ សេចក្តីនេះមានឧបមាដូចម្តេចមិញ ថាមានគួរនាដូចជាសត្វដែលធ្វើកាលកិរិយាចាកមនុស្សលោកនេះហើយ ឡើងទៅកើតឯស្ថានព្រហ្មលោក និងសត្វដែលស្លាប់អំពីមនុស្សលោកនេះហើយទៅកើតត្រឹមក្រុងកស្មិរនេះវិញ ក៏សត្វទាំងពីរពួកនេះគង់កើតព្រម ៗ គ្នាដូច្នោះឯង ។

**ម. កល្លោសិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន លោកម្ចាស់ឆ្លៀវឆ្លាសវាងវៃពេកណាស់ ប្រសប់ឧបមានុបមេយ្យគួរឱ្យចូលចិត្តងាយ ៗ ខ្ញុំអស់សង្ស័យហើយ ។

## បរលោកគតនីលបីតាទិវណ្ណាគតបញ្ហា ។ ទី ៦

ព្រះបាទសម្តេចមិលិន្ទរាជ ទ្រង់ព្រះរាជបុច្ឆាចំពោះទៅព្រះ-នាគសេនថេរថា **អហំ ភន្តេ នាគសេន តុរិតការណំ បុច្ឆិស្សាមិ**

បពិត្រព្រះនាគសេនដ៏ចម្រើនខ្ញុំសូមសួរលោកម្ចាស់ចំពោះហេតុនេះឱ្យប្រាកដជាក់ស្ដែងតទៅទៀត ដើម្បីនឹងអស់សេចក្ដីសង្ស័យ ក្នុងចិត្តនៃខ្ញុំនិងអ្នកឯទៀត បពិត្រព្រះនាគសេនដ៏ចម្រើនសត្វលោកដែលធ្វើកាលកិរិយាស្លាប់បាកមនុស្សលោកនេះទៅ ហើយនឹងទៅកើតក្នុងបរលោកគឺលោកខាងមុខទៀតនោះតើសត្វទាំងនោះនឹងមានពណ៌សម្បុរខៀវឬបៃតង ក្របាមស ហង្សបាទ ឬមានពណ៌ឱភាសភ្លឺផ្លេក បណ្ដាពណ៌ទាំង ៦ ប្រការនេះ តើសត្វលោកនឹងមានពណ៌យ៉ាងណា មានពណ៌ខៀវឬបៃតងជាដើម ក្នុងរវាងពាក់កណ្ដាលផ្លូវដែលសត្វកំពុងសៀនទៅនោះ ពុំនោះសោតសត្វលោកនឹងបេញទៅនោះតើមានសណ្ឋានទ្រង់ទ្រាយ បែបផែនដូចជាអ្វី ដូចសត្វដំរីឬដូចសេះដូចរទេះ លោកម្ចាស់ ។

ព្រះនាគសេនថ្វាយព្រះពរថា អបញ្ញត្តំ មហារាជ ភគវតា-តេបិដកេ ពុទ្ធវចនេ នត្ថិ បពិត្រសម្ដេចមហារាជ ឯសត្វលោកដែលធ្វើកាលកិរិយា អំពីមនុស្សលោកនេះទៅ នឹងទៅកើត

Websites: WatKhemaraRatanaram.org or WatKhmers.org

ទៀតក្នុងបរលោកនោះ នឹងមានពណ៌សម្បុរ ខៀវក្រហមបៃតង ស ហង្សបាទ ឬមានឱភាសភ្លឺផ្លេកអ្វីនីមួយ ដូចព្រះរាជឱង្ការនោះទេ ម្យ៉ាងទៀត នឹងមានសណ្ឋានទ្រង់ទ្រាយ ដូចដំរី ដូចសេះ ដូចរទេះ នោះក៏ទេទាំងអស់ ព្រះសម្មាសម្ពុទ្ធនឹងបាន សំដែងបញ្ញត្តទុកក្នុងព្រះត្រៃបិដកត្រង់កន្លែងណា ១ ក៏គ្មានគ្រប់ អន្លើ សូមមហារាជជ្រាប ។

**ម. យទិ ភន្តេ នាគសេន** បពិត្រព្រះនាគសេនដ៏បម្រើន បើព្រះសមណគោតមបរមគ្រូ ទ្រង់មិនបានសំដែងបញ្ញត្តទុកថា សត្វលោកដែលស្លាប់ទៅកាន់បរលោកនាយនោះ មិនបាន ប្រាកដដោយពណ៌សម្បុរ ខៀវ ស ជាដើម ឯណានីមួយទេ បើ ដូច្នោះមានតែសត្វទាំងនោះមិនទៅកើតក្នុងបរលោកទៀត បើ សត្វមិនទៅកាន់បរលោកហើយ ទាំងបរលោកនោះក៏គ្មានដែរ កាលបើបរលោកគ្មានហើយ ទៅសមគ្នានឹងពាក្យរបស់មិច្ឆា-ទិដ្ឋិ ដែលឈ្មោះថាគុណាជីវកនោះឯង ឯគុណាជិវកនោះពួក ជនទៃគេបានលើកតម្កើងថាជាគ្រូអាចារ្យបណ្ឌិតយ៉ាងធំ បំពួក

Websites: WatKhemaraRatanaram.org or WatKhmers.org

មួយខាងពួកឯទៀតដែរ ហើយគុណាជីវកនោះបានពោលទុកថា នត្ថិ លោកោ នត្ថិ បរលោកោ សត្តោ បរលោកំ ន គច្ឆតិ សេចក្តីថា លោកនេះមិនមាន លោកខាងមុខក៏មិនមានដែរ សត្វលោកដែលស្លាប់ទៅ មិនទៅកាន់បរលោកឡើយ យ៉ាងនេះឬអ្វីលោកម្ចាស់ ។

ន. **សុណោហិ មហារាជ មម វាក្យំ** បពិត្រមហារាជសូមព្រះរាជសម្ភារ ទ្រង់ព្រះសណ្តាប់ពាក្យរបស់អាត្មាភាពឱ្យច្បាស់សិន ។

ម. **សុណោមិ ត្វ វាក្យំ** ខ្ញុំស្តាប់ពាក្យរបស់លោកម្ចាស់បានឮច្បាស់ហើយ ។

ន. **មម វាក្យំ** បុះសូរសំដីរបស់អាត្មាភាពដែលបេញផុតអំពីមាត់អាត្មាភាពទៅ ៗ កាន់ព្រះស្រោត្ររបស់ព្រះអង្គនោះ តើនឹងទ្រង់ទស្សនាការទតព្រះនេត្រទៅឃើញ នូវពណ៌សម្បុររបស់សំដីនោះ ថាមានពណ៌ខៀវបៃតង ឬសក្នុងវាំងពាក់កណ្តាលផ្លូវ ដែលសំឡេងកំពុងបេញទៅនោះដែរឬ ។

**ម. ន បស្សាមិ ភន្តេ** បពិត្រលោកម្ចាស់បម្រើន ខ្ញុំមើលនូវពណ៌សំដីនោះមិនឃើញទេ ។

**ន. យទិ មហារាជ** បពិត្រមហារាជ ថាបើមហាបពិត្រទ្រង់ទតព្រះនេត្រទៅមិនឃើញពណ៌សម្បុរនៃសំដីនោះទេ បើដូច្នោះមានតែសំដីនោះ មិនបានចូលទៅកាន់ព្រះសោត្រនៃព្រះអង្គទេ កាលបើសំដីនោះមិនបានចូលទៅដល់ព្រះសោត្រទេ ចុះហេតុអ្វីក៏ព្រះអង្គមានព្រះរាជឱង្ការត្រាស់ថា ទ្រង់បានឮពាក្យរបស់អាត្មាភាពដែរ ប្រហែលជាព្រះអង្គទ្រង់មានព្រះរាជឱង្ការនោះ ជាពាក្យមុសាវាទទេដឹង ។

**ម. ន អលិកំ ភណាមិ** ខ្ញុំមិនបានពោលពាក្យមុសាវាទទេលោកម្ចាស់ ឯសព្ទសំដីសូរសំឡេងលោកម្ចាស់នេះ ខ្ញុំបានឮច្បាស់ប្រាកដមែន តែត្រង់ពណ៌សម្បុរនៃសំដីនោះ ខ្ញុំមិនបានឃើញទេ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រមហារាជ សេចក្តីនេះមានឧបមាដូចម្តេចមិញ ថាមានឧបមេយ្យដូចសត្វទាំងពួង

ដែលធ្វើកាលកិរិយាចាកស្ថានមនុស្សលោកនេះទៅ រមែងតែង ទៅកើតក្នុងបរលោកនាយដោយពិត តែត្រង់រូបរាងសណ្ឋាន ទ្រង់ទ្រាយឬពណ៌សម្បុររបស់សត្វ ដែលកំពុងត្រាច់ចៀនទៅ ក្នុងរវាងពាក់កណ្តាលផ្លូវនោះ មិនប្រាកដជារូបដំរីឬរូបសេះពណ៌ ខ្មៅឬសដូចម្តេចនោះបានឡើយ ឯត្រង់តួសត្វទាំងឡាយទៀង តែទៅកើតទៀតជាប្រាកដមិនខាន ប្រៀបដូចជាស្ងួរសំដីនៃអា-ត្មាភាព ដែលបេញអំពីមាត់ហើយចូលទៅក្នុងព្រះស្រោត្រថ្លៃ នៃមហាបពិត្រនោះ នឹងបានមានរូបរាងសណ្ឋានទ្រង់ទ្រាយ ឬពណ៌សម្បុរខ្មៅសដូច្នេះដូច្នោះក៏ទេ សូមថ្វាយព្រះពរ ។

**ម. អច្ឆរិយំ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន សេចក្តី វិសជ្ជនាដោះស្រាយអាថ៌ប្រស្នា របស់ព្រះករុណាម្ចាស់នេះ ជា ការអស្ចារ្យបំភ្លែកពេកណាស់ គួរឱ្យកោតឱ្យស្ញើចជាទីបំផុត លោកម្ចាស់ជាបុគ្គលមានបញ្ញាបារមី ឆ្លៀវឆ្លាសវាងវៃយ៉ាង ឆ្នើមក្នុងលោក បើតាមអានុភាពរបស់លោកម្ចាស់ដែលមាន បញ្ញាញាណឈ្វេងយល់ មានប្រតិពលបេះដឹងយ៉ាងនេះនោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

គួរតែសោយនូវមហាសម្បត្តិដ៏ប្រសើរ ដែលមាននៅក្នុងសកលជម្ពូទ្វីបទាំងមូលនេះទើបសម លុះព្រះបរមក្សត្រស្ដេចទ្រង់សរ-សើរយ៉ាងនេះហើយ ទើបទ្រង់ត្រាស់សួរទៅព្រះនាគសេនថេរតទៅទៀតថា ព្រះករុណាម្ចាស់ ញោមបូលបិត្តថាខន្ធទាំង ៥ ប្រការមានរូបក្ខន្ធជាដើម នេះជាធម្មជាតិមិនទៅកាន់បរលោកនាយទេ កាលបើខន្ធទាំង ៥ ប្រការនេះមិនទៅកើតឯបរលោកទៀតទេ មានតែបញ្ចក្ខន្ធនេះឥតមានកុសលាកុសលកម្មអ្វីនីមួយដែលសត្វធ្វើទុកនោះមកជួយតាក់តែងឡើយ វិលាត្រូវកើតក៏កើតឡើងឯង កាលបើបញ្ចក្ខន្ធនេះមិនមានកុសលនិងអកុសលតាក់តែងទេ អាចកើតបានដោយខ្លួនឯងហើយ ពាក្យដែលថាសង្សារគឺប្រទេសសម្រាប់សត្វវិលស្លាប់វិលកើតនោះក៏មិនមានដែរ នេះតាមញោមបូលបិត្តថាយ៉ាងនេះ ជាគួរឬមិនគួរទេ លោកម្ចាស់ ។

៦. **ខេត្តំ ការាបេយ្យាសិ** បពិត្រមហារាជ អាត្មាភាពសូមសួរព្រះរាជសម្ភារថា បុះមហាបពិត្រស្ដេច ដែលបានបាត់បែងឱ្យពួកពលធ្វើស្រែព្រោះស្រូវដែរឬ ។

**ម. អាម ភន្តេ** ខ្ញុំដែលឱ្យគេធ្វើដែរ ស្រែនោះលោកម្ចាស់ ។

**ន. ឧទ្ធំ សាលគ្គំ គច្ឆតិ** បពិត្រព្រះរាជសម្ភារ បុះស្រូវសាលីដែលគេដាំផ្ទាល់ទៅនឹងផែនដីនោះ នឹងមានគ្រាប់ឡើងទៅកើតជាក្ដួរឬជាផ្លែឯចុងស្រូវខាងលើនោះដែរ ឬមិនមានធម្មជាតិអ្វីឡើងទៅកើតខាងលើនោះទេ ឯក្ដួរស្រូវនៅចុងនោះគឺកើតឡើងឯង ឥតមានមនុស្សណាតាក់តែងព្រោះដាំទេឬមហាបពិត្រ ។

**ម. ភន្តេ នាគសេន** បពិត្រព្រះនាគសេនដ៏បម្រើន ឯគ្រាប់ស្រូវដែលជនដាំនៅផែនដីនោះមុខជានឹងប្រព្រឹត្តឡើងទៅឯចុងស្រូវខាងលើនោះមិនខានទេ បានជាមានផ្លែស្រូវឬក្ដួរស្រូវនៅខាងទីបំផុតនោះ មិនមែនក្ដួរស្រូវនៅចុងនោះកើតឡើងឯងឥតមានគេសាបព្រោះនោះទេ លោកម្ចាស់ ។

**ន. យទិ មហារាជ** បពិត្រសម្ដេចមហារាជ បុះបើស្រូវដែលបុគ្គលដាំនោះ កំពុងលូតលាស់ស្រួលដើម មិនទាន់មានផ្លែបេញមកខាងចុងនៅឡើយ នឹងថាជាស្រូវនោះមិនមានគេ

ដាំទេឬទើបមិនឃើញមានផ្លែចេញមកប្រាកដ ឬនឹងថាស្រូវនោះមិនមែនជាស្រូវទេ មហាបពិត្រ ។

**ម. ន ហិ ភន្តេ** បពិត្រព្រះថេរដ៏ចម្រើន ឯស្រូវដែលគេបានព្រោះដាំទុកហើយ ៗ មិនទាន់មានផ្លែចេញមកនោះនឹងថាជាស្រូវគឺមនុស្សមិនបានដាំមិនបានធ្វើនោះមិនមែនទេ គឺស្រូវនោះប្រាកដជាកើតដោយមនុស្សធ្វើ តែមិនទាន់ដល់ពេលដល់វដ្ដូវនៅឡើយ បានជាមិនទាន់មានផ្លែ ប្រការមួយទៀតឯស្រូវសាលីដែលបុគ្គលបានដាំផ្ទាល់ទៅនឹងផែនដីហើយ ទៅខាងមុខ ៗ ជានឹងមានគួរបរិបូណ៌មិនខាន ម្យ៉ាងទៀតថាបើស្រូវនោះកើតឡើង រកអ្នកធ្វើគ្មាន អ្នកដាំគ្មាន ឯបុគ្គលដែលប្រូតស្រូវមកគរជាគំនរទុក ធ្វើជាធ្មឹមនោះក៏គ្មានដែរ ទៅជាស្រូវនោះកើតឡើងឯងៗ ទៅហើយលោកម្ចាស់ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រសម្ដេចមហារាជ សេចក្ដីនេះគួរនាដូចម្ដេចមិញ ថាមានគួរនាដូចបញ្ញត្តនោះឯងបពិត្រមហារាជ ថាបើបញ្ញត្តនេះអាចនឹងទៅកើតក្នុងលោក

ទៀតបាន មនុស្សណាដែលធ្លាប់ខ្វាក់ភ្នែក ឬថ្លង់ត្រចៀកក្នុងជាតិនេះ វេលាដល់នឹងទៅកើតទៀតក្នុងបរលោកនាយ ក៏នឹងទៅជាមនុស្សខ្វាក់ភ្នែកឬថ្លង់ត្រចៀកដដែលវិញ ត្រង់កិច្ចដែលបុគ្គលបានធ្វើបុណ្យធ្វើបាបនោះ មិនមានជាប្រយោជន៍អ្វីដល់ខ្លួនឡើយ ។ ម្យ៉ាងទៀតថាបើបញ្ចក្ខន្ធនេះ អាចកើតឡើងឯងបាន ឥតមានកុសលាកុសលកម្មអ្វីជួយតាក់តែងទេ សេចក្ដីដែលថាសត្វទៅកើតក្នុងស្ថាននរកសោយទុក្ខវេទនា ព្រោះអកុសលកម្មនោះក៏ទៅជាមិនមែនមិនពិតទទេ ៗ ទៅ សេចក្ដីនេះមិនមែនដូច្នោះទេមហាបពិត្រ ឯបញ្ចក្ខន្ធនោះមិនអាចនឹងទៅកើតក្នុងបរលោកទៀតទេ តែឯសត្វដែលស្លាប់ទៅនឹងទៅកើតទៀតក្នុងបរលោក ក៏គង់អាស្រ័យនូវបញ្ចក្ខន្ធនេះដែរទើបកើតបាន ។ ម្យ៉ាងទៀតបញ្ចក្ខន្ធនេះមិនមែនកើតឯងឥតមានកុសលាកុសលកម្មជួយតាក់តែងទេ គឺកើតព្រោះផលនៃកុសលាកុសលកម្មជួយឧបត្ថម្ភទំនុកបំរុងទើបកើតបាន សូមស្ដេចជ្រាប ។

**ម. ភិយ្យោ ឧបមំ ករោហិ** សូមលោកម្ចាស់ឧបមាឱ្យប្លែកពីនេះទៅទៀតមើល ។

**ន. សេយ្យថាបិ មហារាជ** បពិត្រសម្ដេចមហារាជ សេចក្ដីនេះប្រៀបដូចជាបង្កៀងដែលបុគ្គលអុជបន្តពីគ្នា អាត្មាភាពសូមថ្វាយព្រះពរសួរព្រះរាជសម្ភារថា មានមនុស្សម្នាក់បានតាក់តែងអុជបង្កៀងទុក មានពន្លឺភ្លឺស្វាងរុងរឿងជារោចនជោតនាការ ហើយមានអ្នកឯទៀតយកបង្កៀងដទៃមកអុជបំឡុងពីគ្នាទៅ ឯអណ្ដាតភ្លើងនោះក៏អាចឆាបឆេះជាប់មកនឹងបង្កៀងឯទៀតនោះបាន បពិត្រមហារាជ បុះអណ្ដាតភ្លើងដែលឆ្លងឆេះមកបង្កៀងដទៃនោះជាឆ្លងមកឯង ឥតមានបុគ្គលបាត់បែងក្នុងការនោះឬទេ មហាបពិត្រ ។

**ម. ន ហិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន កិច្ចនោះមិនមែនដូច្នោះទេ អណ្ដាតភ្លើងដែលអាចឆ្លងពីបង្កៀងដើមទៅបង្កៀងដទៃបាននោះ ក៏ព្រោះអាស្រ័យមនុស្សបាត់បែងដែរទើបឆ្លងទៅបាន បើឥតមានមនុស្សធ្វើទេ មិនអាចនឹងឆ្លងទៅបានឡើយ ។

**ន. ឯវមេវ ខោ មហារាជ** បពិត្រសម្ដេចមហារាជ សេចក្ដី

នេះមានគ្គរនាដូចម្តេចមិញ ថាមានគ្គរនាដូចខន្ធទាំងឡាយ ៥ ប្រការ ឯខន្ធទាំង ៥ ប្រការនេះ មិនមែនទៅកើតក្នុងបរលោកទេ តែនឹងថាបញ្ចក្ខន្ធនេះកើតឡើងឯង ឥតមានកុសលាកុសលកម្មជួយឧបត្ថម្ភគាំទ្រនោះមិនមែនទេ បំពោះជាមានកុសលនឹងអកុសលទំនុកបំរុងទើបកើតបាន ប្រៀបដូចជាប្រទីបដែលគេអុជបំឡងពីគ្នានោះឯង សូមមហារាជជ្រាប ។

**ម. ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំសូមសួរលោកម្ចាស់បំពោះតែវេទនាក្ខន្ធម្យ៉ាង បុះវេទនាក្ខន្ធនោះនឹងអាចទៅកើតក្នុងបរលោកទៀតដែរឬ ។

**ឥ. យទិ មហារាជ** បពិត្រមហារាជ ថាបើវេទនាក្ខន្ធនេះទៅកើតឯបរលោកនាយទៀតនោះ សត្វដែលធ្លាប់សោយទុក្ខសោយសុខក្នុងបញ្ចក្ខន្ធសព្វថ្ងៃនេះ វេលាដែលទៅកើតទៀតនឹងត្រូវសោយវេទនាដូចដើមវិញឬ មហារាជ ។

**ម. ន ហិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន មិនមែនដូច្នោះទេ ។

**ន. តំ ការណំ មហារាជ** បពិត្រមហារាជ សូមព្រះអង្គទ្រង់ជ្រាបសេចក្ដីនេះឱ្យប្រាកដចុះ ឯវេទនាក្ខន្ធក្នុងអត្តភាពរបស់សត្វនេះ មិនបានទៅកាន់បរលោកទៀតទេ ។

**ម. ភន្តេ នាគសេន** បពិត្រព្រះនាគសេនដ៏ចម្រើន ចុះសញ្ញាក្ខន្ធនឹងត្រូវទៅកាន់បរលោកទៀតដែរឬ ដូចម្ដេច ។

**ន. យទិ មហារាជ បពិត្រមហារាជ** ថាបើសញ្ញាក្ខន្ធទៅកើតក្នុងបរលោកទៀត មនុស្សដែលធ្លាប់កំបុតដៃកំបុតជើងក្នុងជាតិនេះ វេលាដល់ទៅកើតក្នុងបរលោកទៀតនឹងទៅជាមនុស្សកំបុតដៃកំបុតជើងដដែលវិញ ព្រោះសញ្ញាគឺសេចក្ដីសំគាល់ថាខ្លួនអញជាមនុស្សកំបុតដៃ កំបុតជើង នោះទៅកើតផង យ៉ាងនេះឬអ្វី ។

**ម. នត្ថិ ភន្តេ** បពិត្រលោកម្ចាស់ដ៏ចម្រើន មិនមែនដូច្នោះទេ ។

**ន. តំ ការណំ មហារាជ** បពិត្រមហារាជ បើដូច្នោះសូមព្រះរាជសម្ភារស្ដេចជ្រាបនូវហេតុហោះដោយប្រពៃចុះ ឯសញ្ញាក្ខន្ធក្នុងអត្តភាពនេះមិនបានទៅកាន់បរលោកទៀតទេ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

**ម. ភិយ្យោ ឧបមំ ករោហិ** សូមលោកម្ចាស់ប្រៀបធៀបសេចក្ដីនេះឱ្យប្លែកតទៅទៀតមើល ។

**ឥ. អត្ថិ តេ មហារាជ** បពិត្រសម្ដេចមហារាជ ចុះព្រះអង្គស្ដេចមានកញ្ចក់សម្រាប់ឆ្លុះព្រះភក្ត្រនៅជិតនេះដែរឬ ។

**ម.** មានដែរលោកម្ចាស់ ។

**ឥ.** សូមមហារាជ ស្ដេចឱ្យយកកញ្ចក់នោះមកតម្កល់ទុកក្នុងទីនេះមើល ។

**ម.** នែលោកម្ចាស់ កញ្ចក់នោះខ្ញុំបានឱ្យយកមកហើយនេះនែ ។

**ឥ.** សូមព្រះអង្គស្ដេចទ្រង់ទតឆ្លុះ ទៅត្រង់មណ្ឌលកញ្ចក់នោះមើលមើ ទ្រង់នឹងបានឃើញព្រះនេត្រព្រះកាណ៌ព្រះនាសិកនិងព្រះទន្តរបស់ព្រះអង្គបាកដទៅក្នុងផ្ទៃកញ្ចក់នោះដែរឬ ។

**ម.** លោកម្ចាស់ឯអាការទាំងឡាយ មានភ្នែកជាដើមរបស់ខ្ញុំនោះ ខ្ញុំបានឃើញប្រាកដទៅក្នុងផ្ទៃកញ្ចក់ហើយ ។

**ឥ.** ចុះបើព្រះនេត្រព្រះកាណ៌ព្រះនាសិកនិងព្រះទន្តរបស់

ព្រះអង្គនោះរបើកទៅនៅក្នុងមណ្ឌលកញ្ចក់ហើយព្រះអង្គមិនទៅជាមនុស្សខ្វាក់ព្រះនេត្រកំបុតព្រះកាណ៌ទៅហើយ ។

**ម.** មិនមែនដូច្នោះទេលោកម្ចាស់ ឯអាការទាំងឡាយមានភ្នែកជាដើមរបស់ខ្ញុំនោះ មិនមែនរបើកចេញពីខ្លួនខ្ញុំចូលទៅតាំងនៅក្នុងផ្ទៃកញ្ចក់នោះទេ ឯភ្នែកត្រចៀកច្រមុះជាដើមដែលនៅ ៗ ក្នុងកញ្ចក់នោះ គឺជាស្រមោលនៃភ្នែកត្រចៀកដែលអាស្រ័យនៅនឹងកាយរបស់ខ្ញុំនេះឯង ។

**ន** បពិត្រសម្តេចមហារាជ សេចក្តីនេះមានឧបមាដូចម្តេចមិញ ជាមានឧបមេយ្យដូចបញ្ចក្ខន្ធនេះ ឯបញ្ចក្ខន្ធនេះមិនមែនទៅកាន់បរលោកទៀតទេ តែនឹងជាបញ្ចក្ខន្ធនេះកើតឡើងឥតមានកុសលាកុសលកម្មជួយឧបត្ថម្ភទំនុកបំរុងក៏ទេដែរ បំ-ពោះជាមានកុសលនិងអកុសលទំនុកបំរុងទើបកើតបាន ប្រៀបដូចជាស្រមោលដែលអាស្រ័យនូវរូបកាយនេះហើយឆ្លុះទៅក្នុងផ្ទៃកញ្ចក់នោះ បើប្រសិនជាឥតរូបកាយនេះទេ ក៏មិនអាចនឹងមានស្រមោលឆ្លុះចូលទៅក្នុងកញ្ចក់នោះបានឡើយ ឯសត្វ

ដែលកាន់យកបដិសន្ធិក្នុងផ្ទៃនៃមាតាបាននោះ ក៏ដោយអំណាចនៃកុសលាកុសលកម្មដែលខ្លួនបានធ្វើហើយក្នុងបញ្ចក្ខន្ធនេះឯង ។

**ម.** បូលបិត្តហើយលោកម្ចាស់ ៗ ឆ្លៀវឆ្លាសពេកណាស់ ។

## មាតុកុច្ឆិបដិសន្ធិបញ្ហា ៗ ទី ៧

ព្រះមហាក្សត្រស្ដេចទ្រង់សួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៧ នេះតទៅថា បពិត្រព្រះនាគសេនថេរដ៏ចម្រើន មនុស្សសត្វដែលនឹងកាន់យកបដិសន្ធិក្នុងផ្ទៃនៃមាតានោះ តើនឹងចូលទៅតាមទ្វារណា ទើបកាន់យកបដិសន្ធិបាន ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រមហារាជ ឯមនុស្សសត្វទាំងឡាយកាលចូលទៅកើតក្នុងផ្ទៃនៃមាតានោះឥតមានចូលទៅតាមទ្វារទេ មហាបពិត្រ ។

**ម.** បើមិនចូលទៅតាមទ្វារណាទេ ចុះហេតុដូចម្ដេចក៏មានសត្វកើតក្នុងផ្ទៃមាតា សូមលោកម្ចាស់ប្រៀបជាសេចក្ដីបន្តិចមកមើល ។

**ន.** បុះមហាបពិត្រស្ដេចមានប្រអប់កែវនៅទៀបព្រះអង្គដែរឬ ។

**ម.** ប្រអប់កែវនោះខ្ញុំមានលោកម្ចាស់ ។

**ន.** សូមព្រះរាជសម្ភារស្ដេចទ្រង់ព្រះបិន្ដាត្រិះរិះនឹកទៅខាងក្នុងនៃប្រអប់កែវនោះមើល ។

**ម.** ខ្ញុំបាទតាំងចិត្តនឹកបំពោះទៅខាងក្នុងនៃប្រអប់កែវនោះហើយលោកម្ចាស់ ។

**ន.** បុះព្រះហឫទ័យរបស់ព្រះអង្គកាលដែលចូលទៅខាងក្នុងប្រអប់កែវនោះ តើចូលទៅតាមទ្វារដូចម្ដេច ។

**ម.** ឯចិត្តរបស់ខ្ញុំកាលដែលខ្ញុំតាំងនឹកតម្រង់ទៅខាងក្នុងប្រអប់កែវនោះ ឥតមានចូលទៅតាមទ្វារណាទេ លោកម្ចាស់តែគង់ដឹងនូវវត្ថុក្នុងប្រអប់នោះបាន ។

**ន.** បពិត្រព្រះរាជសម្ភារ សេចក្ដីនេះមានគួរនាយ៉ាងណាជាមានគួរនាដូចមនុស្សសត្វ កាលដែលចូលទៅកើតក្នុងផ្ទៃនៃមាតានោះឯង ធម្មតាមនុស្សសត្វទាំងឡាយកាលដែលនឹង

ចូលទៅបដិសន្ធិក្នុងផ្ទៃនោះ ឥតមានចូលទៅតាមទ្វារណា ១ ទេ តែគង់អាចកើតបាន ព្រោះបឋមវិញ្ញាណឬបដិសន្ធិចិត្ត នោះជាធម្មជាតិមិនមានរូបរាងសណ្ឋានទ្រង់ទ្រាយទេ ប្រៀប ដូចខ្សែព្រះបិដ្ឋាឬសន្ទុះព្រះហឫទ័យរបស់ព្រះអង្គ ដែលស្ទុះចូល ទៅក្នុងខាងក្នុងនៃប្រអប់កែវនោះឯង សូមទ្រង់ជ្រាប ។

**ម. អច្ឆរិយំ ភន្តេ នាគសេន** បពិត្រព្រះនាគសេនដ៏ចម្រើន ហេតុនេះគួរជាទីអស្ចារ្យចំឡែកពេកណាស់ អព្ភុតំ ភន្តេ នាគ សេន បពិត្រព្រះនាគសេនដ៏ចម្រើន សេចក្ដីនេះមិនធ្លាប់កើត មានហើយមកមានប្រាកដ លោកម្ចាស់នេះពេញជាបុគ្គលឆ្លៀវ-ឆ្លាសក្នុងការវិសជ្ជនាដោះប្រស្នាដ៏វិចិត្រនេះ ឥតមានទើសទាល់ សល់ជំពាក់សោះ លោកម្ចាស់នេះប្រសិនបើជាព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ព្រះធរមាននៅ សមនឹងលើកនឹងសរសើរឱ្យសព្ទសា ធុការពរដោយច្រើនជាអនេកមិនខាន ។

## សត្តពោជ្ឈង្គបញ្ហា ទី ៨

ព្រះមហាក្សត្រស្ដេចទ្រង់បុច្ឆាចំពោះទៅព្រះនាគសេនថេរ

ក្នុងប្រស្នាទី ៨ នេះថា បពិត្រព្រះនាគសេនដ៏ចម្រើន សភាវ-ធម៌ដែលជាហេតុសម្រាប់ត្រាស់ដឹង ដែលហៅថាពោជ្ឈង្គនោះ តើមានប៉ុន្មានយ៉ាង ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្ដេចមហា-រាជ ឯសភាវធម៌ ដែលជាហេតុនាំឱ្យបេះដឹងនូវគុណទាំងពួងនោះមាន ៧ យ៉ាង មានសតិសម្ពោជ្ឈង្គជាដើម សូមទ្រង់ជ្រាប។

**ម.** ចុះបុគ្គលដែលនឹងត្រាស់ដឹងនូវមគ្គនិងផលនោះ តើដោយពោជ្ឈង្គណាឬដោយពោជ្ឈង្គទាំង ៧ ប្រការនោះ លោកម្ចាស់ ។

**ន.** ឯបុគ្គលដែលនឹងត្រាស់ដឹងនូវមគ្គនិងផលនោះ បំពោះដោយពោជ្ឈង្គតែ ១ ទេ មហារាជ ។

**ម.** ចុះពោជ្ឈង្គមួយនោះតើបានខាងពោជ្ឈង្គណា ក្នុងពោជ្ឈង្គទាំង ៧ ប្រការនោះ លោកម្ចាស់ ។

**ន.** **ធម្មវិចយសម្ពោជ្ឈង្គ** បពិត្រសម្ដេចមហារាជ បណ្ដាពោជ្ឈង្គទាំង ៧ ប្រការនោះ បានខាងឯធម្មវិចយសម្ពោជ្ឈង្គនោះឯង សូមទ្រង់ជ្រាប ។

**ម.** បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំមានសេចក្ដីសង្ស័យនឹងចម្លើយរបស់លោកម្ចាស់នេះពេកណាស់ ព្រោះថាហេតុដែលជាទីត្រាស់ដឹងនោះមានដល់ទៅ ៧ យ៉ាង ហៅថាសត្តពោជ្ឈង្គ ចុះហេតុដូចម្ដេចក៏លោកម្ចាស់សំដែងថា ការដែលនឹងត្រាស់ដឹងនោះបំពោះតែត្រង់ធម្មវិចយសម្ពោជ្ឈង្គម្យ៉ាងវិញ ។

**ត. បពិត្រមហារាជ** ចុះព្រះអង្គស្ដេចទ្រង់ព្រះយោបលក្នុងសេចក្ដីនេះថាដូចម្ដេចទៅ អាត្មាភាពសូមថ្វាយព្រះពរសួរមហាបពិត្រវិញថា ផ្លែដាវដែលបុគ្គលប្រកបុះទៅក្នុងស្រោមមិនបានហូតចេញចាកស្រោមឡើយ ចុះបើបុគ្គលត្រូវការនឹងកាត់នូវវត្ថុអ្វីទាំងពួងដោយផ្លែដាវព្រមទាំងស្រោម នោះតើនឹងដាច់ឬមិនដាច់ទេ មហារាជ ។

**ម.** កាត់មិនដាច់ទេ លោកម្ចាស់ ។

**ត.** សូមថ្វាយព្រះពរមហាបពិត្រ សេចក្ដីនេះមានគួរនាដូចម្ដេចមិញ ថាមានគួរនាដូចពោជ្ឈង្គទាំង ៦ ប្រការដែលតែងអាស្រ័យនូវធម្មវិចយសម្ពោជ្ឈង្គនោះឯង ឯពោជ្ឈង្គទាំង ៦

ប្រការមានសតិសម្ពោជ្ឈង្គជាដើមនេះ ថាបើវៀរចាកធម្មវិច័យ-សម្ពោជ្ឈង្គហើយ មិនអាចនឹងគាស់ដឹងនូវមគ្គនិងផលបាន ឡើយ ប្រៀបដូចស្រោមដាវដែលតែងអាស្រ័យនូវផ្លែដាវ ទើប អាចនឹងកាត់នូវវត្ថុទាំងពួងបាន ចំណែកឯស្រោមបើវៀរចាក ផ្លែហើយ មិនអាចនឹងកាត់វត្ថុទាំងពួងបានឡើយ ។

**ម.** លោកម្ចាស់មានប្រាជ្ញាឆ្លៀវឆ្លាស វាងវៃពេកណាស់ ប្រសប់ក្នុងការវិសជ្ជនាដោះស្រាយអាថ៌ប្រស្នាដែលចង្អៀតឱ្យ ទៅជាទូលាយបាន ។

## បាបបុញ្ញពហុតរបញ្ហា ។ ទី ៩

ព្រះបរមក្សត្រាធិរាជ ទ្រង់បុច្ឆាទៅព្រះនាគសេនថេរក្នុងប្រ ស្នាទី ៩ នេះតទៅថា បពិត្រព្រះនាគសេនដ៏ចម្រើន បុញ្ញកម្ម និងបាបកម្មទាំងពីរប្រការនេះ កម្មណាមានផលច្រើនដោយ វិសេសជាងកម្មណា ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ បណ្តាកម្មទាំងពីរប្រការនោះ បុញ្ញកម្មមានផលច្រើនដោយ

វិសេសជាងបាបកម្ម ឯបាបកម្មនោះជាកម្មមានផលតិចថយចុះមកជាងបុញ្ញកម្មសូមទ្រង់ជ្រាប ។

**ម.** ព្រោះហេតុអ្វីលោកម្ចាស់ បានជាបុណ្យមានផលច្រើនជាងបាប បាបបែរទៅជាមានផលតិចទៅវិញលោកម្ចាស់ ។

**ន.** បពិត្រព្រះរាជសម្ភារ ឯកម្មទាំងពីរប្រការបានជាមានផលខុសគ្នានោះ ព្រោះមានសេចក្តីអធិប្បាយផ្សេងគ្នាដូច្នេះ ថាបើជនណាជ្រុលខ្លួនទៅប្រព្រឹត្តធ្វើអំពើបាបកម្ម ជាអកុសលហើយ ជននោះឯងនឹងមានសេចក្តីក្តៅក្រហាយទោមនស្សតូចចិត្តនឹងខ្លួនជាខាងក្រោយថា អាត្មាអញបានធ្វើនូវអំពើអាក្រក់លាមកយ៉ាងនេះ បានជាមកប្រទះនូវសេចក្តីទុក្ខព្រួយដូច្នេះឯង ។ ព្រោះហេតុនេះហើយបានជាអាត្មាភាពថ្វាយព្រះពរថាបាបកម្មនោះមានផលតិចជាង មិនចម្រើនផលល្អដល់អ្នកដែលធ្វើនោះ បពិត្រមហារាជ ម្យ៉ាងទៀត ថាបើជនណាដែលបានធ្វើបុណ្យរួចហើយ ជននោះឯងនឹងមិនបានសេចក្តីតក់ស្លុតឬក្តៅក្រហាយជាខាងក្រោយទេ សឹងមានតែសេចក្តីរីករាយ

សេចក្ដីត្រេកអរ មានកាយដ៏ស្ងប់រម្ងាប់មិនបានក្រវល់ក្រវាយ បានសោយនូវសេចក្ដីសុខគ្រប់យ៉ាង ចិត្តនៃជននោះសោតក៏អាចតាំងនៅមាំមួនខ្ជាប់ខ្ជួនដោយល្អទៅបាន ព្រោះហេតុនេះហើយបានជាអាត្មាភាពថ្វាយព្រះពរមហារាជថា បុណ្យមានផលច្រើនជាងបាបនោះឯង ម្យ៉ាងទៀត បពិត្រមហារាជប្រសិនបើជាបុរសណាមួយជាមនុស្សពិការ កំបុតដៃ កំបុតជើងមិនអាចនឹងធ្វើនូវការកុសលឱ្យបានមាំមួនទៅបាន គ្រាន់តែបានថ្វាយនូវផ្កាឧប្បលចំនួន ១ ក្ដាប់ដល់ព្រះសម្ពុទ្ធជាម្ចាស់ហើយ ខ្លួនបុរសនោះគង់នឹងបានទទួលសោយនូវផលបុណ្យនោះយូរយារអស់ចំនួន ៩១ កប្បដោយពិត ព្រោះហេតុនោះបានជាអាត្មាភាពថ្វាយព្រះពរមហារាជថា បុណ្យមានផលច្រើនជាងបាប ឯបាបនោះតែងមានផលតិចជាងបុណ្យ សូមស្ដេចជ្រាប ។

**ម.** ខ្ញុំចូលចិត្តស្ដាប់បានហើយលោកម្ចាស់ ៗ ជាបុគ្គលឆ្លៀវឆ្លាសល្អហើយ ។

ព្រះបាទមិលិន្ទស្តេចទ្រង់សួរ ទៅព្រះនាគសេនថេរក្នុងប្រស្នាទី ១០ នេះថា បពិត្រព្រះថេរដ៏ចម្រើន ជនពីរនាក់ ជនម្នាក់ជានាក់ចេះដឹងស្គាល់បុណ្យបាប ហើយទៅប្រព្រឹត្តធ្វើអំពើបាប ជនម្នាក់ទៀតជាអ្នកមិនបានចេះដឹងមិនស្គាល់បុណ្យបាបទេ ហើយទៅប្រព្រឹត្តធ្វើបាបកម្មដូចគ្នា បណ្តាជនទាំងពីរនាក់នោះតើជនណាបានផលបាបច្រើនជាងជនណាលោកម្ចាស់ ។

ព្រះនាគសេនថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ ជំនុំជនទាំងពីរនោះ ជនណាដែលមិនចេះដឹង ជាអ្នកល្ងង់ខ្លៅហើយទៅធ្វើបាបកម្ម ជននោះបានផលបាបច្រើនជាងអ្នកដែលចេះដឹង សូមជ្រាប ។

**ម.** បពិត្រព្រះថេរដ៏ចម្រើន បើដូច្នោះទោសនោះប្លែកគ្នានឹងទោសក្នុងបច្ចុប្បន្ននេះលោកម្ចាស់ ឯទោសក្នុងបច្ចុប្បន្ននេះថាបើជនណាជារាជបុត្រ ឬជារាជមហាមាត្យ ជាអ្នកដឹងការខុសត្រូវធ្ងន់ស្រាល ហើយទៅប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេង ៗ ឱ្យ

ខុសបាករាជបញ្ញត្តិហើយ យើងខ្ញុំត្រូវធ្វើទោសដាក់ទណ្ឌកម្ម ដល់ជនទាំងនោះជាទ្វេគុណលោកម្ចាស់ ។

៦. បពិត្រសម្តេចមហារាជ បុះព្រះអង្គទ្រង់ព្រះយោបល ឈ្វេងយល់ក្នុងសេចក្តីនេះដូចម្តេចទៅ អាត្មាភាពនឹងប្រៀបជា សេចក្តីថ្វាយឱ្យជាក់ច្បាស់ថា ដូចជាជនពីរនាក់ ជនម្នាក់ជា អ្នកល្ងង់ខ្លៅ មិនដឹងមិនស្គាល់នូវដុំដែកដែលបុគ្គលដុតដោយ ភ្លើងកំពុងឆេះក្រហមរន្ទាលប្រាលឆ្អៅ គួរឱ្យញញើតស្ញើបជា ពន្លឹកពេក ហើយជននោះយកដៃទៅចាប់កាន់ដោយសប់សួន បំពោះត្រង់ដុំដែកនោះ ដោយសេចក្តីយល់ខុសថាជាវត្ថុឯទៀត ផ្សេង ឯជនម្នាក់ទៀតជាអ្នកដឹងប្រាកដថា ដុំក្រហមនោះ បំពោះជាដុំដែកមានភ្លើងកំពុងឆេះក្រហមរន្ទាលប្រាលឆ្អៅ តែ ត្រូវការនឹងលូកទៅចាប់យកដុំដែកនោះដែរ ក៏បណ្តាជនទាំង ពីរនាក់នោះ តើជនណានឹងត្រូវគ្រោះរលាករលួយដៃនោះច្រើន ជាងជនណា មហាបពិត្រ ។

៧. បពិត្រលោកម្ចាស់ដ៏ចម្រើន ជនណាដែលមិនដឹងមិន

ស្គាល់នូវដុំដែកដែលក្តៅហើយយកដៃទៅចាប់កាន់ដោយស៊ប់ សួន ជននោះនឹងត្រូវកំដៅយ៉ាងខ្លាំងដល់រលាករលួយដៃមិន ខាន សូមលោកម្ចាស់ជ្រាប ។

**ន.** បពិត្រមហារាជ សេចក្តីនេះមានគួរនាដូចម្តេចមិញ ថា មានគួរនាដូចជាជន ដែលជាអ្នកមិនដឹងការខុសត្រូវធ្ងន់ស្រាល ហើយទៅប្រព្រឹត្តធ្វើអំពើអាក្រក់ ជននោះឯងនឹងបានផលបាប ច្រើនជាងអ្នកដែលបេះដឹងនោះ សូមស្តេចជ្រាប ។

**ម.** លោកម្ចាស់ប្រសប់ប្រៀបប្រាយអធិប្បាយជាសេចក្តី ងាយស្តាប់ពេក ។

## ឧត្តរកុរុបញ្ហា ១ទី ១១

ព្រះបាទមិលិន្ទស្តេចទ្រង់សួរទៅព្រះនាគសេនថេរក្នុងប្រ- ស្នាទី១១ នេះថា បពិត្រព្រះនាគសេនដ៏ចម្រើន ជនឯណានីមួយ អាចនឹងទៅកាន់ប្រទេសឧត្តរកុរុទ្វីប ឬនឹងហោះទៅកាន់ស្ថាន ព្រហ្មលោកនិងទ្វីបដទៃៗ ទៀតក្រៅពីទ្វីបនេះ ទៅដោយសរីរ រាងកាយនេះបានឬទេ លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ ជនឯណាមួយមានប្រាថ្នានឹងទៅកាន់ឧត្តរកុរុទ្វីបក្តី ទៅកាន់ស្ថានព្រហ្មលោកក្តី ទៅកាន់ទ្វីបដទៃក្តី ដោយរាងកាយដែលប្រកបដោយធាតុទាំង៤ នេះបាន ឥតមានទាស់ទេមហាបពិត្រ។

**ម.** បពិត្រលោកម្ចាស់ដ៏ចម្រើន បុះហេតុដូចម្តេចក៏ជនទាំងនោះអាចនឹងទៅកាន់ស្ថានទាំងនោះបាន ដោយរូបទាំងមូលនេះលោកម្ចាស់ ។

**ន.** បពិត្រសម្តេចមហារាជ បុះព្រះអង្គអាចនឹងលោតឱ្យផុតអំពីផែនដីនេះបំណួន ១ បំអាម ឬ ១ ហត្ថទៅបានឬទេ មហារាជ ។

**ម.** លោកម្ចាស់ ខ្ញុំនេះអាចលោតឡើងបានកុំថាត្រឹម ១ បំអាម ឬមួយហត្ថ ទោះបីទីខ្ពស់ដល់ទៅ ៨ ហត្ថ ក៏គង់ខ្ញុំលោតឡើងបាន ។

**ន.** បុះហេតុដូចម្តេចក៏ព្រះអង្គទ្រង់លោតឡើងដល់ទៅ ៨ ហត្ថបាន មហារាជ ។

**ម.** បពិត្រលោកម្ចាស់ដ៏ចម្រើន ឯវិធីដែលនឹងលោតឡើងបានកម្ពស់ ៨ ហត្ថនោះ គឺខ្ញុំបានតាំងចិត្តថានឹងលោតឡើងឱ្យបានកម្ពស់ត្រឹមនោះ ៗ ហើយក៏ខ្ញុំប្រិតប្រៀនរៀនហាត់រឿយ ៗ ទៅ កាយរបស់ខ្ញុំនោះក៏ស្រាលអណ្ដែតព្រមទៅដោយចិត្តបានដូចប្រាថ្នា ។

**ន.** បពិត្រមហារាជ សេចក្ដីនេះមានឧបមាដូចម្ដេចមិញ ថាមានឧបមេយ្យដូចភិក្ខុ ដែលមានឫទ្ធិស្ទាត់ជំនាញទៅដោយឈានចិត្តហើយ លោកអាចនឹងទៅកាន់អាកាសវេហាបានដោយកម្លាំងឈាននោះឯង សូមស្ដេចជ្រាប ។

**ម.** ខ្ញុំចូលចិត្តហើយលោកម្ចាស់ ។

## ទីឃអដ្ឋិកបញ្ហា ៗ ទី ១២

ព្រះបាទក្រុងមិលិន្ទទ្រង់មានព្រះរាជឱង្ការ ត្រាស់សួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ១២ នេះថា បពិត្រព្រះថេរដ៏ចំរើន លោកម្ចាស់បានសម្ដែងថា មានឆ្អឹងអ្វីមួយវែងប្រមាណដល់ ១០០ យោជន៍ ពាក្យនេះឃើញថាកើនហួសប្រមាណពេកណាស់ កុំថាតែឆ្អឹងសត្វទាំងពួង ទោះបីដើមឈើលើផែនដី

នេះទាំងប៉ុន្មាននឹងរកឈើឯណា ឱ្យមានប្រវែងដល់ទៅ ១០០ យោជន៍នោះក៏គ្មានដែរ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ ចុះព្រះអង្គទ្រង់យោបល់ឈ្វេងយល់ នូវសេចក្តីនេះថាដូចម្តេចទៅ អាត្មាភាព សូមថ្វាយព្រះពរសួរព្រះអង្គវិញថា ចុះមហាបពិត្រទ្រង់ដែលបានឮពាក្យ ដែលគេតែងនិយាយថា មានមហាមច្ឆាគឺត្រី ១ ធំ ទំហំប្រមាណ ៥០០ យោជន៍នៅក្នុងមហាសមុទ្រនោះដែរឬ ។

**ម.** បពិត្រលោកម្ចាស់ដ៏ចម្រើន ពាក្យនេះខ្ញុំធ្លាប់បានឮមកដែរ ថាមានត្រី ១ ធំ ប្រមាណ ៥០០ យោជន៍ក្នុងមហាសមុទ្រនោះ ។

**ន.** ចុះមហាបពិត្រស្តេចនឹងទ្រង់ជ្រាបនូវហេតុនេះថាដូចម្តេចទៅ បើខ្លួនត្រីដែលមានទំហំដល់ ៥០០ យោជន៍នោះ ចំណែកខាងឆ្អឹងត្រីនោះតើមានប្រមាណប្រវែងណាទៅ ។

**ម.** លោកម្ចាស់ឆ្លាសពន្យល់ស្រួលពេកក្នុងការបុច្ឆាវិសជ្ជនានេះ ខ្ញុំចូលចិត្តហើយ ។

# អស្សាសបស្សាសបញ្ហា ។ ទី ១៣

ព្រះបាទក្រុងមិលិន្ទទ្រង់មានព្រះរាជឱង្ការត្រាស់សួរបំពោះទៅព្រះនាគសេនថេរក្នុងប្រស្នាទី១៣ នេះថា បពិត្រព្រះនាគ-សេនដ៏ចម្រើន លោកម្ចាស់បានពោលថា ខ្លួនលោកអាចនឹងអត់ដង្ហើមចេញចូលឬធ្វើដង្ហើមចេញចូលនោះមិនឱ្យប្រព្រឹត្តទៅបានហើយមិនឱ្យស្លាប់ផង ជាមែនឬទេ ។

ព្រះនាគសេនថ្វាយព្រះពរតបទៅវិញថា បពិត្រសម្តេចមហារាជ អាត្មាភាពអាចនឹងញ៉ាំងអស្សាសបស្សាសៈនោះ ឱ្យរលត់ទៅបាន ។

**ម.** បុះលោកម្ចាស់អាចញ៉ាំងអស្សាសបស្សាសៈ ឱ្យរលត់ទៅនោះដូចម្តេច ។

**ន.** បុះមហាបពិត្រស្តេចទ្រង់ព្រះតម្រិះនូវសេចក្តីនេះថាដូចម្តេចទៅ អាត្មាភាពសូមថ្វាយព្រះពរសួរព្រះរាជសម្ភារវិញថា បុគ្គលដែលដេកលក់ហើយស្រមុកនោះ តើមហាបពិត្រស្តេចដែលបានឮស្រមុកនោះដែរ ។

**ម.** ខ្ញុំធ្លាប់បានឮដែរលោកម្ចាស់ ។

**ន.** បពិត្រព្រះរាជសម្ភារសំឡេងដែលបុគ្គលស្រមុកនោះ តើប្រហែលគ្នានឹងសំឡេងមនុស្សដែលជិតស្លាប់ហើយលាន់ឮ ក្រក ៗ ឬឮងឹក ៗ នោះឬអ្វី ។

**ម.** យ៉ាងហ្នឹងហើយលោកម្ចាស់ ។

**ន.** បពិត្រព្រះរាជសម្ភារ ឯសំឡេងនៃបុគ្គលដែលជិតនឹងមរណហើយលាន់ឮងឹក ៗ នោះមិនមែនព្រោះហេតុអ្វីទេ ព្រោះតែបុគ្គលនោះឯងកាលដែលរស់នៅ មិនបានបង្ហាត់កាយឱ្យរក្សាសីលនឹងចម្រើនសមាធិចិត្តឡើយ បានជាដល់វេលាជិតស្លាប់ក៏មានខ្យល់អស្សាសបស្សាសៈលាន់ឮងឹក ៗ នោះឯង បំណែកខាងលោកអ្នកសប្បុរស ដែលបានទូន្មានកាយនិងចិត្តឱ្យតម្កល់នៅក្នុងសីលាទិគុណហើយ វេលាដល់ជិតស្លាប់លោកក៏ចូលកាន់ចតុត្ថជ្ឈាន ហើយបានរម្ងាប់ខ្យល់អស្សាសបស្សាសៈនោះ មិនឱ្យប្រព្រឹត្តទៅបាន លុះចេញចាកឈានហើយទើបសម្រេចបុតិកិច្ច ។

**ម.** បពិត្រលោកម្ចាស់ដ៏ចម្រើន សេចក្ដីឆ្លើយរបស់លោកនោះសមគួរហើយ ។

Websites: WatKhemaraRatanaram.org or WatKhmers.org

# សមុទ្របញ្ហា ។ ទី ១៤

សម្ដេចព្រះមិលិន្ទស្ដេចទ្រង់ត្រាស់ព្រះរាជឱង្ការសួរបំពោះទៅព្រះនាគសេនថេរក្នុងប្រស្នាទី ១៤ នេះថា បពិត្រព្រះថេរដ៏ចម្រើន ខ្ញុំសូមសួរលោកម្ចាស់អំពីទឹកសមុទ្រ ថាទឹកដូចម្ដេចដែលហៅថាទឹកសមុទ្រនោះ សូមលោកម្ចាស់អធិប្បាយមកមើល ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្ដេចមហារាជ ឯទឹកសមុទ្រនោះមានសេចក្ដីអធិប្បាយថា ទឹកមានចំនួនប៉ុន្មាន រសប្រៃក៏មានចំនួនប៉ុណ្ណោះ រសប្រៃមានចំនួនប៉ុន្មាន ទឹកក៏មានចំនួនប៉ុណ្ណោះដែរ ព្រោះហេតុយ៉ាងនេះហើយបានជាលោកសន្មត់ឱ្យឈ្មោះថាទឹកសមុទ្រ ៗ នោះឯង សូមស្ដេចជ្រាប។

**ម.** បពិត្រព្រះថេរដ៏ចម្រើន ចុះហេតុអ្វីក៏បានជាទឹកសមុទ្រនោះតែងមានរសជាតិប្រៃតែម្យ៉ាង លោកម្ចាស់ ។

**ន.** បពិត្រសម្ដេចមហារាជ ឯទឹកសមុទ្រនោះបានជាមានរសប្រៃតែម្យ៉ាងព្រោះទឹកនោះត្រាំនៅក្នុងទី ១ អស់កាលយូរយារ

មកហើយឥតមានផ្លាស់ផ្តូរទៅទីឯទៀតឡើយ សូមស្តេចជ្រាប។

**ម.** លោកម្ចាស់វិសជ្ជនាមកនេះសមគួរហើយ ។

## សុខុមឆេទបញ្ហា ។ ទី ១៥

ព្រះមហាក្សត្រស្តេចទ្រង់ត្រាស់សួរទៅព្រះនាគសេនថេរ ក្នុងប្រស្នាទី ១៥ នេះថាបពិត្រព្រះថេរដ៏ចម្រើន លោកម្ចាស់មានយោបល់អាចនឹងកាត់នូវវត្ថុដ៏ល្អិតជាសុខុមជាងវត្ថុទាំងពួងនោះបានឬទេ ។

ព្រះថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជអាត្មាភាពអាចនឹងកាត់ផ្តាច់ នូវវត្ថុក៏ល្អិតយ៉ាងសុខុមជាងវត្ថុទាំងពួងនោះបានឥតមានទាស់ទេ ។

**ម.** បពិត្រព្រះថេរដ៏ចំរើនចុះវត្ថុដូចម្តេចដែលជារបស់សុខុមជាងវត្ថុទាំងពួងនោះលោកម្ចាស់ ។

**ន.** បពិត្រព្រះរាជសម្ភារ ឯសភាវៈដែលជាសុខុមជាងសភាវទាំងពួងនោះមិនគឺអ្វីទេគឺលោកុត្តរធម៌នោះឯង បំណែកខាងលោកិយធម៌វិញ មិនមែនជាសភាវសុខុមសុទ្ធតែម្យ៉ាងដូច

Websites: WatKhemaraRatanaram.org or WatKhmers.org

លោកុត្តរធម៌ទេ ឯលោកិយធម៌ទាំងឡាយនោះ ជាសភាវស្អិតខ្លះ គ្រោតគ្រាតខ្លះ មិនសុទ្ធតែម្យ៉ាង មហាបពិត្រ បុគ្គលដែលនឹងកាត់នូវសុខុមធម៌ទាំងពួងបាននោះ ត្រូវកាត់ដោយលោកុត្តរបញ្ញាតែម្យ៉ាង បើនឹងកាត់ដោយលោកិយបញ្ញាវិញមិនអាចនឹងកាត់បានទេ ។

**ម.** លោកម្ចាស់វិសជ្ជនាមកនោះសមគួរហើយ ។

## បញ្ញាវិសេសបញ្ហា ។ ទី ១៦

ព្រះមហាក្សត្រស្តេចទ្រង់មានព្រះរាជឱង្ការ ត្រាស់សួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី១៦ នេះថា បពិត្រព្រះថេរដ៏ចំរើនធម្មជាតិដែលហៅថាបញ្ញា ។ នោះស្ថិតនៅត្រង់ទីកន្លែងណាលោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រព្រះរាជសម្ភារឯធម្មជាតិដែលហៅថាបញ្ញានោះ ឥតមានស្ថិតនៅត្រង់កន្លែងណានីមួយឡើយ មហាបពិត្រ។

**ម.** បពិត្រព្រះថេរដ៏ចម្រើន បើបញ្ញានេះឥតមានទីកន្លែង

សម្រាប់នៅទេ មានតែបញ្ហានោះក៏គ្មានដែរ លោកម្ចាស់ ។

**ន.** បពិត្រមហារាជបុះមហាបពិត្រស្ដេចទ្រង់ព្រះយោបល់ឈ្វេងយល់ដូចម្ដេចទៅក្នុងរឿងនេះ អាត្មាភាពសូមថ្វាយព្រះពរសួរព្រះរាជសម្ភារវិញថា បុះខ្យល់ដែលមាននៅសព្វថ្ងៃនេះ តើអាស្រ័យនៅកន្លែងណា មហាបពិត្រ ។

**ម.** បពិត្រព្រះថេរដ៏ចម្រើន ខ្យល់មិនមានទីកន្លែងសម្រាប់នៅទេ លោកម្ចាស់ ។

**ន.** បពិត្រព្រះរាជសម្ភារ បើទីកន្លែងសម្រាប់ខ្យល់នៅនោះមិនមានហើយ ទាំងតួខ្យល់នេះក៏ប្រហែលជាមិនមានដែរ មហារាជ ។

**ម.** លោកម្ចាស់ជាបុគ្គលឆ្លាសណាស់តើ ខ្ញុំចូលចិត្តបានសព្វគ្រប់ហើយ ។

## បញ្ហាទីនំនានត្តភាវបញ្ហា ៗ ទី ១៧

ព្រះបាទមិលិន្ទស្ដេចទ្រង់មានព្រះរាជឱង្ការត្រាស់សួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ១៧ នេះថា បពិត្រព្រះថេរដ៏ចំរើន

ធម៌ទាំងឡាយពីរប្រការគឺបញ្ញា ១ វិញ្ញាណ ១ ទាំងពីរនេះបាន ឈ្មោះថាជីវធម៌គឺជីវិតដែលអាស្រ័យក្នុងមហាភូតរូបយើងសព្វ ថ្ងៃនេះឬអ្វី ម្យ៉ាងទៀតធម៌ទាំងពីរប្រការគឺបញ្ញានិងវិញ្ញាណនេះ មានអត្ថផ្សេងៗ គ្នា មានព្យញ្ជនៈផ្សេងៗគ្នាឬ ។ មានអត្ថតែម្យ៉ាង មានព្យញ្ជនៈផ្សេង ៗ គ្នាលោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រមហារាជ ឯធម៌ ទាំងពីរប្រការគឺបញ្ញានិងវិញ្ញាណនោះ មិនបានកំណត់ហៅថា ជីវធម៌ទេ ហើយធម៌ទាំងពីរនេះសោតសឹងមានអត្ថក៏ផ្សេងគ្នា មានព្យញ្ជនៈក៏ផ្សេងគ្នា មិនបានដូចគ្នាទេ ដូចមានបទថា វិជានលក្ខណំ វិញ្ញាណំ បជានលក្ខណាបញ្ញា ប្រែថា វិញ្ញាណមានសេចក្តីដឹងផ្សេង ៗ ជាលក្ខណៈ បញ្ញាមានកិរិយា ដឹងច្បាស់ប្រាកដជាលក្ខណៈ សូមមហាបពិត្រជ្រាប ។

**ម.** បពិត្រលោកម្ចាស់ដ៏ចម្រើន ថាបើបញ្ញានិងវិញ្ញាណ ទាំងពីរនេះមិនបានហៅថាជីវធម៌ទេ ចុះសភាវៈដូចម្តេចដែល ហៅថាជីវធម៌នោះ ក្រៅវិញ្ញាណដែលសម្រាប់ឃើញរូបដោយ ភ្នែក ស្តាប់សំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ភ្លក់រស

ដោយអណ្ដាត ប៉ះពាល់នូវវត្ថុទាំងពួងដោយកាយ ដឹងធម៌ដោយចិត្តនោះឬអ្វីដែលហៅថាជីវធម៌ លោកម្ចាស់ ។

**ន.** បពិត្រមហារាជ ថាបើវិញ្ញាណនោះជាជីវធម៌ ជាធម្មជាតិសម្រាប់ឃើញរូបដោយភ្នែក ស្ដាប់សំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ភ្លក់រសដោយអណ្ដាត ប៉ះពាល់នូវវត្ថុទាំងពួងដោយកាយ ដឹងធម៌ដោយចិត្ត នោះមានតែជីវធម៌នោះ កាលដែលបុគ្គលបើកភ្នែកហើយ បែរមុខទៅខាងក្រៅងើយមើលទៅខាងលើ បានឃើញនូវរូបផ្កាយប្រាកដ កាលប្រុងត្រចៀកបែរទៅខាងក្រៅបានឮសំឡេងប្រាកដ ប្រុងច្រមុះបែរទៅខាងក្រៅ បានធុំក្លិនប្រាកដ ប្រុងអណ្ដាតលៀនចេញទៅខាងក្រៅ បានភ្លក់រសប្រាកដ ប្រុងកាយងាកចេញទៅខាងក្រៅ បានប៉ះពាល់នូវសម្ផស្សប្រាកដ កាលតម្រង់ចិត្តបែរទៅខាងក្រៅ បានដឹងធម៌ទាំងពួង យ៉ាងនេះឬអ្វី ដែលព្រះអង្គសម្គាល់ថាជីវធម៌នោះ ។

**ម.** មិនមែនដូច្នោះទេ លោកម្ចាស់ ។

**ន.** បពិត្រសម្ដេចមហារាជ បើដូច្នោះវិញ្ញាណនិងបញ្ញា

នោះ មិនមែនជាឈ្មោះនៃជីវធម៌ក្នុងភូតកាយនេះទេ គឺជាធម្មជាតិម្យ៉ាងសម្រាប់ដឹងផ្សេងៗ និងធម្មជាតិសម្រាប់ដឹងនូវទៅនោះឯង ឯជីវធម៌នោះជាធម្មជាតិដទៃក្រៅពីវិញ្ញាណ និងបញ្ញានោះឯង សូមទ្រង់ជ្រាប ។

**ម.** បពិត្រព្រះនាគសេនដ៏ចម្រើន លោកម្ចាស់ឆ្លៀវឆ្លាសពេកបេះដោះស្រាយ អាថ៌ប្រស្នាស្រួលបួលណាស់ ខ្ញុំអស់សង្ស័យហើយ ។

## អរូបវវត្ថភាវទុក្ករបញ្ហា ។ ទី ១៨

ព្រះនាគសេនថេរលោកតាំងផ្ដើមថ្វាយព្រះពរទៅព្រះបាទមិលិន្ទថា បពិត្រសម្ដេចមហារាជ ព្រះអង្គបានជ្រាបដែរឬ ថាព្រះដ៏មានព្រះភាគ ស្ដេចបានធ្វើនូវអំពើដែលព្រះអង្គធ្វើបានដោយកម្រក្រៃពេកនោះ មហាបពិត្រ ។

ព្រះបាទមិលិន្ទ ស្ដេចទ្រង់សួរទៅព្រះនាគសេនវិញថា បពិត្រព្រះថេរដ៏ចម្រើន បុះអំពើដែលព្រះសម្ពុទ្ធព្រះអង្គធ្វើដោយកម្រនោះតើដូចម្ដេច ។

**ន.** បពិត្រសម្តេចមហារាជ ឯអំពើដែលព្រះសម្ពុទ្ធទ្រង់ធ្វើហើយដោយកម្រនោះគឺថាព្រះអង្គបានកំណត់នូវធម៌ទាំងឡាយគឺចិត្តនិងចេតសិកដែលជាធម្មជាតិមិនមានរូប តែងប្រព្រឹត្តទៅក្នុងអារម្មណ៍ជាមួយគ្នាមិនមានភាន់ច្រឡំឡើយ ហើយទ្រង់អាចពោលកំណត់នូវធម៌ទាំងនោះថា សភាពយ៉ាងនេះហៅថាផស្ស ធម្មជាតិយ៉ាងនេះហៅថា វេទនា ធម្មជាតិយ៉ាងនេះហៅថា សញ្ញា ធម្មជាតិយ៉ាងនេះហៅថា ចេតនា ធម្មជាតិយ៉ាងនេះហៅថាចិត្ត បពិត្រព្រះរាជសម្ភារ ព្រះបរមគ្រូព្រះអង្គទ្រង់កំណត់យ៉ាងនេះបាន ៗ ជាអាត្មាភាពថ្វាយព្រះពរថា ព្រះសម្ពុទ្ធទ្រង់ធ្វើនូវអំពើដែលព្រះអង្គធ្វើបានដោយកម្រនោះឯង សូមទ្រង់ជ្រាប។

**ម.** សូមលោកម្ចាស់ឧបមាជាសេចក្តីយ៉ាងងាយបន្តិចមកនឹងបានស្តាប់ក្នុងកាលឥឡូវនេះមើល ។

**ន.** បពិត្រមហារាជ ឯព្រះសម្ពុទ្ធជាម្ចាស់នោះប្រៀបដូចជាបុរសម្នាក់ដែលជាអ្នកឆ្លាស អាចស្គាល់ច្បាស់នូវរសទឹកសមុទ្រហើយបានចុះសំពៅទៅតាមមហាសមុទ្រ បានយកដៃទៅក្បង់ទឹកសមុទ្រនោះយកមកភ្លក់ដោយអណ្តាត លុះបានភ្លក់រួចហើយ

បុរសនោះឯងអាចដឹងច្បាស់នូវរសនៃទឹកនោះថា ទឹកប៉ុណ្ណោះជាទឹកហូរមកអំពីស្ទឹងឈ្មោះគង្គា ទឹកប៉ុណ្ណោះអំពីស្ទឹងឈ្មោះយមុនា ទឹកប៉ុណ្ណោះមកអំពីស្ទឹងឈ្មោះសរភូ ទឹកប៉ុណ្ណោះមកអំពីស្ទឹងឈ្មោះអចិរវតី ទឹកប៉ុណ្ណោះមកអំពីស្ទឹងឈ្មោះមហី បពិត្រសម្តេចមហារាជ ព្រះបរមគ្រូព្រះអង្គទ្រង់ត្រាស់ដឹងនូវចិត្តនិងចេតសិកទាំងឡាយបាន ឥតមានភាន់ប្រឡំសោះនោះដូចបុរសដែលជាអ្នកស្គាល់ច្បាស់នូវរសនៃទឹកសមុទ្រនោះឯងសូមទ្រង់ជ្រាប ។

**ម.** បពិត្រព្រះថេរដ៏ចម្រើន ព្រះសម្ពុទ្ធទ្រង់ត្រាស់ដឹងនូវកិច្ចដែលព្រះអង្គធ្វើបានដោយកម្រនោះមែនហើយ ខ្ញុំចូលចិត្តអស់សង្ស័យហើយលោកម្ចាស់ ។

**ន.** បពិត្រសម្តេចមហារាជ ព្រះបរមសាស្តានោះ ព្រះអង្គមិនមែនគ្រាន់តែត្រាស់ដឹងនូវធម៌ទាំងឡាយ គឺចិត្តនិងចេតសិកដែលជាអរូបធម៌ដែលតែងប្រព្រឹត្តទៅក្នុងអារម្មណ៍ តែមួយជាមួយគ្នាថា នេះជាផស្ស នេះជាវេទនា នេះជាសញ្ញា នេះ

ជាចេតនា នេះជាចិត្តប៉ុណ្ណោះទេ គឺព្រះអង្គអាចត្រាស់ដឹងនូវកិច្ចដទៃក្រៃលែងជាងនេះតទៅ ។

**ម.** បពិត្រព្រះថេរដ៏ចម្រើន សេចក្ដីត្រាស់ដឹងរបស់ព្រះដ៏-មានព្រះភាគនេះប្រពៃពេកណាស់ ខ្ញុំមានអំណរជាទីបំផុតក្នុងរឿងនេះលោកម្ចាស់ ។

## ទុក្ករបញ្ហា ។ ទី ១៩

ព្រះនាគសេនថេរ បានថ្វាយព្រះពរទៅព្រះបាទមិលិន្ទ្រា-ធិបតីថា បពិត្រសម្ដេចមហារាជ សូមព្រះអង្គទ្រង់ជ្រាបនូវពេលវេលានេះបុះព្រោះពេលនេះជាពេលដ៏សមគួរហើយ ។

ព្រះបាទមិលិន្ទ្រាធិបតី ស្ដេចទ្រង់មានព្រះរាជឱង្ការពិតទៅព្រះថេរវិញថា បពិត្រព្រះថេរដ៏ចម្រើន មែនហើយ ញោមក៏បានដឹងច្បាស់ថាពេលនេះជាពេលដ៏សមគួរហើយ ព្រោះយាមជាដំបូងនោះកន្លងទៅហើយ ឥឡូវនេះដល់មកមជ្ឈិមយាមពាក់កណ្ដាលអាធ្រាត្រមកហើយ ប្រទីបគោមទាំងឡាយក៏ភ្លឺស្វាងរុងរឿងនៅ ហើយរាជសេវកាមាត្យទាំងឡាយ ក៏នាំយក

សំពត់ទាំងឡាយ ៤ ផាប់ អំពីព្រះឃ្លាំងដែលស្តេចទ្រង់ត្រាស់បង្គាប់ឱ្យបំរុងទុកចាំប្រគេនដល់ព្រះមហាថេរក្នុងពេលនោះផង។

បំណែកខាងយោធកាមាត្យទាំងឡាយ ក៏នាំគ្នាក្រាបបង្គំទូលមហាក្សត្រថា បពិត្រព្រះរាជសម្ភារព្រះអង្គក៏ជាបុគ្គលឆ្លៀវ-ឆ្លាសណាស់ហើយ ទាំងភិក្ខុអង្គនេះសោតលោកក៏ជាបណ្ឌិតប្រាកដមែន។

ព្រះបរមក្សត្រាធិរាជ ស្តេចទ្រង់ត្រាស់ព្រះរាជឱង្ការតបទៅពួកយោធកាមាត្យទាំងឡាយនោះថា មែនហើយយោធកាមាត្យធម្មតាមនុស្សយើង បើបានអាចារ្យមានប្រាជ្ញាប្រាកដយ៉ាងនេះហើយបានកូនសិស្សក៏ឆ្លៀវឆ្លាសយ៉ាងនេះដែរ គង់នឹងបានបេះដឹងធម៌អាថ៌អំពីសំណាក់អាចារ្យនោះដោយឆាប់មិនខាន ហើយអង្គព្រះមហាក្សត្រស្តេចក៏មានព្រះរាជចិត្តាសោមនស្សត្រេកអរចំពោះនឹងព្រះនាគសេនថេរ ដោយលោកបានវិសជ្ជនាដោះអាថ៌ប្រស្នាគ្រប់កន្លែង ត្រូវព្រះហឫទ័យឥតមានឆ្គង ទើបទ្រង់ប្រ-គេនសំពត់កម្ពលយ៉ាងល្អចំនួនថ្លៃមួយសែនដំឡឹងទៀតដល់ព្រះថេរនោះហើយស្តេចបវារណាថា បពិត្រព្រះនាគសេនថេរដ៏ចំ-

រើន ញោមសូមបវារណាប្រគេនភត្តាហារចំនួន ១០៨ សម្រាប់អំពីគេហដ្ឋានរបស់ខ្ញុំតាំងពីថ្ងៃនេះតទៅ ហើយសូមប្រគេននូវវត្ថុអ្វីនីមួយ ដែលជារបស់គួរគប្បីដែលមាននៅខាងក្នុងបុរីនៃខ្ញុំនេះដល់លោកម្ចាស់ទៀតតាមលោកម្ចាស់ត្រូវការ សូមលោកម្ចាស់ទទួលដោយសេចក្តីអនុគ្រោះដល់ញោម ។

ព្រះនាគសេនថេរថ្វាយព្រះពរទៅវិញថា បពិត្រព្រះរាជសម្ភារ អាត្មាភាពសព្វថ្ងៃនេះ មានវត្ថុសម្រាប់ចិញ្ចឹមជីវិតល្មមសមគួរហើយ សូមព្រះមហាបពិត្រស្តេចកុំព្រួយព្រះរាជហឫទ័យឡើយ ។

ព្រះមហាក្សត្រស្តេចទ្រង់ត្រាស់ទៅវិញថា បពិត្រព្រះនាគសេនម្ចាស់ដ៏ចម្រើន ញោមដឹងច្បាស់ហើយថាលោកម្ចាស់មានស្បៀងល្មមសៀងជីវិតបាន តែថាត្រូវលោកម្ចាស់រក្សានូវអង្គលោកផងរក្សានូវញោមផង ។

ព្រះនាគសេនថេរ ថ្វាយព្រះពរសួរទៅមហាក្សត្រវិញថា បពិត្រសម្តេចមហារាជ ដែលទ្រង់មានព្រះរាជឱង្ការត្រាស់ថា

Websites: WatKhemaraRatanaram.org or WatKhmers.org

ឱ្យអាត្មាភាពរក្សានូវខ្លួនអាត្មានោះតើដូចម្ដេច រក្សានូវអង្គរបស់មហាបពិត្រនោះដូចម្ដេច ។

ព្រះបាទមិលិន្ទរាជស្ដេចទ្រង់ពិតបេរវាចាទៅព្រះថេរវិញថា លោកម្ចាស់ ពាក្យដែលញោមថា ឱ្យលោកម្ចាស់រក្សានូវអង្គលោកនោះគឺញោមយល់ថាពីនេះទៅមុខក្រែងនឹងមានពាក្យបរប្បវាទពោលបំពោះមកអង្គលោកម្ចាស់ថា ព្រះនាគសេនថេរជាអ្នកប្រាជ្ញប្រាកដ អាចញុាំងស្ដេចមិលិន្ទឱ្យមានព្រះរាជហឫទ័យជ្រះថ្លាបាន តែឥតមានបាននូវសក្ការបូជាអ្វីបន្តិចបន្តួចអំពីសំណាក់នៃស្ដេចនោះសោះឡើយ ពាក្យដំណោះដំនៀលយ៉ាងនេះគង់នឹងកើតមានដល់លោកម្ចាស់មិនខាន បានជាញោមថាសូមឱ្យលោកម្ចាស់ទទួលយកនូវភត្តាហាររបស់ញោមកុំខាន ដើម្បីនឹងរក្សានូវអង្គលោកម្ចាស់យ៉ាងនេះឯង ម្យ៉ាងទៀតពាក្យដែលញោមពិតលោកម្ចាស់ថា ឱ្យរក្សានូវញោមផងនោះ គឺថានឹងមានពាក្យបរប្បវាទថា ព្រះបាទមិលិន្ទ្រាធិរាជស្ដេចមានព្រះហឫទ័យសោមនស្សជ្រះថ្លា នឹងធម៌ទេសនារបស់ព្រះនាគសេនថេរនោះពិតមែនហើយ តែថាស្ដេចឥតមានត្រូវការធ្វើនូវ

Websites: WatKhemaraRatanaram.org or WatKhmers.org

សក្ការបូជាអ្វីបន្តិចបន្តួចដល់ព្រះថេរនោះសោះទេ ហេតុនេះ ហើយបានជាញោមពិតលោកម្ចាស់ថា ឱ្យលោកទទួលនូវ ខាទនីយភោជនីយាហារ របស់ញោមដើម្បីនឹងរក្សានូវខ្លួន ញោមនេះផង ។

ព្រះនាគសេនថេរថ្វាយព្រះពរទៅវិញថា បពិត្រសម្តេច មហារាជ បើដូច្នោះអាត្មាភាពមិនហ៊ានប្រកែកទេ សូមទទួល តាមព្រះរាជអធ្យាស្រ័យ ។

លំដាប់នោះព្រះបាទមិលិន្ទ្រាធិបតី ស្តេចទ្រង់សម្តែងព្រះ- រាជអធ្យាស្រ័យរបស់ព្រះអង្គ ពិតដល់ព្រះនាគសេនថេរឱ្យ ជ្រាប សេចក្តីពិតនោះថាដូច្នេះ បពិត្រព្រះនាគសេនម្ចាស់ដ៏ បម្រើន ខ្លួនញោមសព្វថ្ងៃនេះ ពិតមែនតែជាបុគ្គលនៅគ្រប់គ្រង រក្សាវាំងដំណាក់នៅឡើយ តែត្រង់គំនិតរបស់ញោមជាបុគ្គល បែរមុខចេញទៅខាងក្រៅជាដរាបរាល់ថ្ងៃឥតមានអាល័យត្រង់ទី លំនៅនេះទេ ប្រៀបដូចជាស្តេចម្រឹគដែលហៅថាសីហរាជ ដែលជាប់នៅក្នុងទ្រុងមាសក៏ពិតមែនហើយ តែគំនិតរបស់សី- ហរាជនោះតែងបែរមុខចេញទៅខាងក្រៅជានិច្ចដូច្នោះឯង ម្យ៉ាង

ទៀត បពិត្រព្រះនាគសេនម្ចាស់ដ៏ចម្រើន បើប្រសិនណាជា-ញោមហើយចេញចាកគេហដ្ឋាន ទៅបួសក្នុងព្រះពុទ្ធសាសនា ប្រហែលជាញោមមិនបានរស់នៅយូរទេ ព្រោះថាមនុស្សទាំងឡាយដែលជាសត្រូវនឹងញោមនោះមានច្រើនពេកណាស់ ។

គ្រានោះព្រះនាគសេនថេរដ៏មានអាយុ លោកបានវិសជ្ជនាដោះប្រស្នា របស់ព្រះបាទមិលិន្ទរាជស្រេចហើយវេលាណា ក៏-ថ្វាយព្រះពរលាស្តេចក្រោកចាកទីនោះ ទៅកាន់សង្ឃារាមវិញក្នុងវេលានោះ កាលបើព្រះនាគសេនថេរត្រឡប់ទៅសង្ឃារាមនោះមិនយូរប៉ុន្មាន ព្រះចៅក្រុងមិលិន្ទស្តេចមានព្រះរាជតម្រិះថាដូច្នេះ ខ្ញុំអញបានសួរប្រស្នាដូចម្តេចខ្លះនឹងព្រះនាគសេនថេរ បំណែកព្រះនាគសេនដ៏ចម្រើន លោកបានឆ្លើយប្រស្នាដូចម្តេចខ្លះប្ញ លុះស្តេចទ្រង់ព្រះដំរិះដូច្នេះហើយទើបទ្រង់ជ្រាបថា បញ្ហាកម្មទាំងអស់ដែលអញបានសួរហើយនោះ ជាការប្រពៃពេក បំ-ណែកឯព្រះនាគសេនសោតលោកក៏បានឆ្លើយនូវបញ្ហាកម្មទាំងអស់នោះដោយល្អពិត ។

ឯអង្គព្រះនាគសេនដ៏មានអាយុ លោកបានទៅដល់ទីសំ-

Websites: WatKhemaraRatanaram.org or WatKhmers.org

យាមហើយ ក៏មានសេចក្ដីត្រិះរិះរំពឹងថាដូច្នេះ ព្រះបាទមិ-លិន្ទស្ដេចទ្រង់សួរនូវប្រស្នាដូចម្ដេចខ្លះ អាត្មាអញបានវិសជ្ជនាដោះប្រស្នានោះដូចម្ដេចហ្ន៎ លុះរំពឹងរួចហើយទើបដឹងច្បាស់ថា បញ្ហាកម្មទាំងអស់ ដែលស្ដេចមិលិន្ទទ្រង់ព្រះរាជបុច្ឆានោះជាប្រស្នាប្រពៃពេក បំណែកខាងអាត្មាអញទៀតក៏បានវិសជ្ជនាដោះប្រស្នាដោយល្អពិតឥតមានភ្លាំងភ្លាត់ឡើយ ។

លុះដល់វេលាព្រឹកឡើង ព្រះនាគសេនថេរលោកក៏ស្លៀកស្បង់ឃ្លុំចីពររួចស្រេចចាប់យកនូវបាត្រហើយ ក៏និមន្តចូលទៅឯព្រះរាជនិវេសនស្ថានដែលស្ដេចគង់នៅនោះ លុះដល់ហើយក៏ចូលទៅគង់នៅលើអាសនៈដែលស្ដេចឱ្យតែងតាំងទុកប្រគេននោះ ។

សម័យនោះព្រះបាទមិលិន្ទបរមក្សត្រាធិរាជ ស្ដេចទ្រង់ព្រះដំណើរចូលទៅកាន់ទីដែលព្រះនាគសេនគង់នៅនោះ លុះដល់ហើយក៏ក្រាបថ្វាយបង្គំចំពោះព្រះថេរ ហើយស្ដេចទ្រង់គង់នៅក្នុងទីដ៏សមគួរមួយ លុះស្ដេចទ្រង់ស្ថិតនៅស្រួលបួលហើយទើបទ្រង់ប្រារព្ធសន្ទនាការសួរទៅព្រះនាគសេនថេរថា បពិត្រ

ព្រះនាគសេនដ៏ចម្រើនសូមលោកម្ចាស់កុំមានសេចក្ដីត្រិះរិះថា ព្រះមហាក្សត្រស្ដេចបានសួរប្រស្នារួចហើយ ម្យ៉ាងទៀតសូមលោកម្ចាស់កុំឈ្វេងយល់យ៉ាងនេះថា ព្រះមហាក្សត្រស្ដេចបានផ្ដិស្ដល់អស់មួយយប់ទាំងមូល ព្រោះសេចក្ដីសោមនស្សត្រេកអរនឹងការសួរនូវប្រស្នានោះឡើយ បពិត្រព្រះនាគសេនដ៏ចម្រើនសូមលោកម្ចាស់ជ្រាបដូច្នេះថា ញោមមានសេចក្ដីត្រិះរិះរំពឹងអស់មួយយប់ទាំងមូលថា បញ្ហាកម្មដូចម្ដេចដែលញោមបានសួរចំពោះលោកម្ចាស់ហើយ បញ្ហាកម្មដូចម្ដេចដែលលោកម្ចាស់បានឆ្លើយដោយល្អប្រាប់ញោមហើយៗ ត្រូវជ្រាបឱ្យប្រាកដទៀតថា ប្រស្នាគ្រប់ចំពូកគឺញោមបានសួរលោកម្ចាស់រួចហើយ ប្រស្នាគ្រប់ចំពូក គឺលោកម្ចាស់បានឆ្លើយដោយល្អប្រាប់ញោមហើយ ដូច្នេះវិញទើបសមគួរ ។

ព្រះនាគសេនថេរ លោកបានថ្វាយព្រះពរទៅវិញថា បពិត្រសម្ដេចមហារាជ សូមព្រះអង្គកុំមានព្រះរាជតម្រិះត្រិះរិះដូច្នេះថា ខ្លួនអាត្មាភាពបានឆ្លើយដោះប្រស្នារួចហើយ ម្យ៉ាងទៀតសូមទ្រង់កុំឈ្វេងយល់ដូច្នេះថា ព្រះថេរនេះបានសឹងលក់

Websites: WatKhemaraRatanaram.org or WatKhmers.org

ដរាបដល់ព្រឹកព្រោះសេចក្ដីសោមនស្សត្រេកអរថា ខ្លួនបានដោះប្រស្នារួចហើយ បពិត្រមហារាជសូមព្រះអង្គទ្រង់ព្រះតម្រិះយ៉ាងនេះវិញថា បញ្ហាកម្មដូចម្ដេចដែលព្រះអង្គបានបុច្ឆារួចហើយ បញ្ហាកម្មដូចម្ដេចដែលអាត្មាភាពបានវិសជ្ជនារួចហើយ ៗ សូមទ្រង់ជ្រាបឱ្យប្រាកដដូច្នេះទៀតថា ព្រះអង្គស្ដេចបានទ្រង់បុច្ឆានូវប្រស្នាគ្រប់ចំពូក ហើយអាត្មាភាពបានវិសជ្ជនាដោះប្រស្នាដោយល្អគ្រប់ចំពូកហើយ យ៉ាងនេះទើបសមគួរ ។

ឯអ្នកប្រាជ្ញទាំងពីរព្រះអង្គ គឺព្រះបាទមិលិន្ទនិងព្រះនាគសេនថេរលោកបានបុច្ឆាវិសជ្ជនា ហេតុឆ្លើយអាថ៌ប្រស្នាគ្នាទៅវិញទៅមកដោយសុន្ទរវាចារួចហើយ ក៏បញ្ចប់សេចក្ដីប៉ុណ្ណោះតាមសមគួរ ។

ទុក្ករបញ្ហាទី ១៩ ក្នុងសត្តមវគ្គចប់តែប៉ុណ្ណោះ

ចប់បុច្ឆាវិសជ្ជនាមិលិន្ទបញ្ហា

បានរួបរួមប្រស្នាក្នុងមិលិន្ទបញ្ហា តាំងអំពីបឋមវគ្គរហូតដល់មកសត្តមវគ្គនេះបាន ៨៨ ប្រស្នា យកវិសេសបញ្ហា ១ មកបញ្ចូលទៀតត្រូវជា ៨៩ ប្រស្នា នៅមានប្រស្នាតទៅទៀត

Websites: WatKhemaraRatanaram.org or WatKhmers.org

ច្រើន មានមេណ្ឌកបញ្ហាជាដើម ក្នុងគម្ពីរមិលិន្ទបញ្ហានេះ ម្យ៉ាងទៀតក្នុងបាលីស្លឹករឹតមានសេចក្តីប្រាប់ថា ក្នុងមិលិន្ទបញ្ហានេះបានប្រស្នា ១០៨ ដែលព្រះគន្ថរចនាចារ្យលោកបានរៀបរៀងសម្រេចទុកក្នុងស្រុកលង្កាទ្វីបឯនោះ តែបានពិនិត្យរាប់មើលឃើញតែ ៨៨ ប្រស្នា បញ្ចូលវិសេសបញ្ហាមកផងទើបត្រូវជា ៨៩ នៅខ្វះ ១៩ ប្រស្នាទៀតទើបគ្រប់ ១០៨ ។

## វិសេសបញ្ហា

## ឬ

## គោតមីវត្ថទានបញ្ហា

ព្រះបរមក្សត្រាធិរាជស្តេចទ្រង់ត្រាស់សួរទៅព្រះនាគសេនថេរក្នុងវិសេសបញ្ហានេះថាបពិត្រព្រះនាគសេនដ៏ចម្រើន សម្តេចព្រះភគវន្តមុនី ព្រះអង្គទ្រង់មានពុទ្ធដីកា បំពោះទៅនឹងនាងមហាបជាបតីគោតមីជាព្រះមាតុច្ឆារបស់ព្រះអង្គ ក្នុងកាលដែលព្រះនាងបានយកសំពត់សាដកថ្មីមួយគូមកថ្វាយព្រះអង្គនោះ ថាបពិត្រព្រះមេព្រះមាតុច្ឆា សូមព្រះមេប្វជាន្វវសំពត់សាដកនេះដល់សង្ឃទាំងពួងចុះ កាលបើទ្រង់បានប្វជាសំពត់នោះដល់

Websites: WatKhemaraRatanaram.org or WatKhmers.org

ពពួកសង្ឃហើយ ក៏ឈ្មោះថាបានបូជាដល់តថាគតផង ដល់សង្ឃផង បពិត្រព្រះនាគសេនដ៏ចម្រើន ឯពុទ្ធភាសិតដូច្នេះ ក៏ឃើញសេចក្ដីថា ព្រះតថាគតបរមគ្រូមិនជាបុគ្គលថ្លៃថ្លាជាងព្រះសង្ឃ មិនជាគ្រូអាចារ្យនៃព្រះសង្ឃ មិនជាបុគ្គលប្រសើរជាងព្រះសង្ឃទេឬអ្វីលោកម្ចាស់ ។ ម្យ៉ាងទៀតសំពត់សាដកមួយគូនោះសោតមិនមែនជាអ្នកដទៃធ្វើឡើយ គឺជាស្នាដៃរបស់ព្រះគោតមីនាងធ្វើដោយព្រះអង្គឯង គឺទ្រង់បោះកប្បាស ច្រូបម្ងូរ រវៃ ការដាក់ខ្នារ ហើយទ្រង់ត្បាញដោយព្រះអង្គ រួចហើយទើបនាំចូលមកថ្វាយចំពោះព្រះបរមគ្រូ តែចំណែកព្រះបរមគ្រូទ្រង់មិនព្រមទទួលយក ទ្រង់បែរទៅជាបង្គាប់ឱ្យព្រះមាតុច្ឆាយកសំពត់សាដកនោះបូជាដល់ព្រះសង្ឃវិញ បពិត្រព្រះនាគសេនម្ចាស់ ថាបើព្រះសម្មាសម្ពុទ្ធព្រះអង្គ ទ្រង់មានគុណសម្បត្តិដ៏-ឧត្តមក្រៃលែងដោយវិសេសជាងសង្ឃរតនៈនោះ គួរតែព្រះអង្គទទួលយកនូវសំពត់សាដកនោះអំពីព្រះមាតុច្ឆា ហើយសមតែទ្រង់ត្រាស់ប្រាប់ទៅព្រះមាតុច្ឆានោះថា ទានដែលបុគ្គលបានបូជាដល់តថាគតហើយ ជាទានមានផលច្រើនដូច្នេះទើបសម

គួរ បុះហេតុអ្វីក៏ទ្រង់ដាក់បន្ទាបព្រះអង្គ ឱ្យទៅជាតូចទាបជាង ព្រះសង្ឃវិញ ទៅជាព្រះអង្គទ្រង់ត្រាស់ប្រាប់ទៅព្រះមាតុច្ឆាថា សូមឱ្យព្រះមេយកនូវសំពត់សាដកនោះ បូជាដល់ព្រះសង្ឃវិញ បើយ៉ាងនេះព្រះសង្ឃមិនជាធំជាងព្រះពុទ្ធហើយ លោកម្ចាស់។

ព្រះនាគសេនថេរថ្វាយព្រះពរទៅវិញថា បពិត្រសម្តេចមហារាជ ឯពុទ្ធភាសិតដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ទៅនឹងនាងមហាបជាបតីគោតមីជាព្រះមាតុច្ឆា ក្នុងកាលដែលព្រះនាងនាំយកសំពត់សាដកមកថ្វាយព្រះអង្គនោះថា បពិត្រព្រះមេសូមព្រះនាងយកសំពត់នេះបូជាទៅសង្ឃវិញ កាលបើព្រះនាងបានបូជាដល់សង្ឃហើយក៏បានឈ្មោះថា បូជាដល់តថាគតផង ដល់សង្ឃផង ម្យ៉ាងទៀតឯកិច្ចដែលព្រះអង្គមិនបានទទួលនូវសំពត់ដោយព្រះអង្គឯង ហើយទ្រង់បង្គាប់ព្រះមាតុច្ឆាឱ្យបូជាទៅសង្ឃវិញនោះនឹងថាព្រះអង្គជាទីគោរពជាងព្រះសង្ឃ ឬថាមិនជាបុគ្គលប្រសើរជាងព្រះសង្ឃ ព្រោះតែព្រះអង្គបង្គាប់ព្រះមាតុច្ឆា ឱ្យបូជាសំពត់សាដកដល់ព្រះសង្ឃប៉ុណ្ណោះនោះមិន-

មែនទេ ម្យ៉ាងទៀតបពិត្រព្រះរាជសម្ភារ ពុទ្ធអធ្យាស្រ័យ ដែលទ្រង់មិនទទួលសំពត់សាដកដោយព្រះអង្គឯង ហើយ ទ្រង់បង្គាប់ឱ្យព្រះមាតុច្ឆាបូជាទៅព្រះសង្ឃនោះ ដោយទ្រង់ព្រះ ញាណយល់ច្បាស់ទៅក្នុងអនាគតកាលខាងមុខថា ដើម្បីនឹង សង្គ្រោះដល់ព្រះសង្ឃ ទ្រង់នឹងធ្វើឱ្យជាប្រយោជន៏ដល់ព្រះ សង្ឃ ព្រោះថាកាលបើអំណើះតពីព្រះអង្គទៅ គឺព្រះអង្គ ទ្រង់ចូលនិព្វានកន្លងហួសទៅហើយ នៅតែព្រះសង្ឃ ៗ នោះ នឹងជាទីគោរពរាប់អាន ដល់សាមញ្ញជនទាំងពួងខាងក្រោយ ហេតុនេះហើយបានជាព្រះអង្គ ទ្រង់លើកសរសើរគុណព្រះសង្ឃ ឱ្យព្រះមាតុច្ឆាទ្រង់បូជាសាដកដល់ព្រះសង្ឃ ដោយព្រះពុទ្ធ-ដីកាថា បពិត្រព្រះគោតមីព្រះមាតុច្ឆា សូមព្រះនាងបូជាសំពត់ សាដកនេះដល់សង្ឃចុះ កាលបើព្រះនាងបានបូជាដល់សង្ឃ ហើយ បានឈ្មោះថាបូជាដល់តថាគតផង ដល់ព្រះសង្ឃ ផង បពិត្រសម្តេចមហារាជ សេចក្តីនេះអាត្មាភាពនឹងប្រៀប ឧបមាថ្វាយ ថាដូចជាបិតា កាលដែលមានជីវិតរស់នៅ ៗ

ឡើយ បើមានកូនឯណា ដែលមានគុណសម្បត្តិច្រើនក្នុងខ្លួន គួរនឹងលើកនឹងសរសើរកូននោះ ក្នុងសំណាក់នៃបរមក្សត្រាធិរាជក្នុងទីប្រជុំនៃរាជមហាមាត្យ ពួកនាយទ្វារនឹងពួកសេនាយោធាទាំងពួងឱ្យបានដឹងឮផង ព្រោះថាសេចក្ដីបំណងរបស់បិតានោះ ចង់ឱ្យមនុស្សទាំងឡាយ មានសេចក្ដីគោរពរាប់អាន ដល់កូនរបស់ខ្លួន ក្នុងកាលទៅខាងមុខ សេចក្ដីនេះមានគួរនាដូចម្ដេចមិញ ថាមានគួរនាដូចសម្ដេចព្រះបរមគ្រូទ្រង់ពិចារណាឃើញប្រយោជន៍ដល់សង្ឃ ក្នុងកាលទៅខាងមុខហើយ ទើបទ្រង់ប្រកាសសរសើរគុណរបស់ព្រះសង្ឃទុកឱ្យប្រាកដឡើង ដើម្បីជាប្រយោជន៍ដល់ជនជាខាងក្រោយ នឹងបានគោរពរាប់អានធ្វើសក្ការបូជាដល់ព្រះសង្ឃ ក្នុងកាលដែលព្រះអង្គទ្រង់បរិនិព្វានកន្លងទៅហើយនោះឯង មិនមែនថាសង្ឃរតនៈនោះប្រសើរជាងព្រះមហាករុណា ព្រោះតែព្រះអង្គបង្គាប់ឱ្យព្រះមាតុច្ឆាបូជាសំពត់សាដកនោះប៉ុណ្ណោះទេ ។ ម្យ៉ាងទៀតបពិត្រព្រះរាជសម្ភារ អាត្មាភាពនឹងថ្វាយសេចក្ដីឧបមា ១ ទៀត

ថាដូចជាមាតាបិតាទាំងឡាយ ដែលជាអ្នកទួត ប្រាប់ ផ្ទុតទឹក លាប ស្រឡាប ប្រស់ព្រំនឹងសម្លៀកបំពាក់សំពត់អាវឱ្យកូន ទាំងឡាយ បពិត្រព្រះរាជសម្ភារ បើមាតាបិតាទំនុកបំរុងកូន យ៉ាងហ្នឹងហើយ កូននោះមិនទៅជាបុគ្គលធំជាង ឬ ប្រសើរជាង មាតាបិតា ព្រោះតែមាតាបិតាទាំងនោះធ្វើកិច្ចទំនុកបំរុងប៉ុណ្ណោះ ទៅហើយ មហាបពិត្រ ។

ព្រះបាទមិលិន្ទស្តេចទ្រង់ពិតទៅព្រះថេរវិញថា មិនមែន ដូច្នោះទេលោកម្ចាស់ ធម្មតាមាតាបិតាទាំងឡាយ តែងធ្វើ នូវសេចក្តីទំនុកបំរុងដល់កូនទាំងឡាយនោះឯង ព្រោះកូនទាំង-កើតមកហើយអំពីខ្លួន នឹងអាចលុះបង់បោលឯណាក៏បាន តែថាកូនទាំងនោះនឹងបានជាធំឬប្រសើរជាងមាតាបិតា ព្រោះ តែមាតាបិតាទំនុកបំរុងប៉ុណ្ណោះក៏ទេ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរទៅព្រះមហាក្សត្រទៀតថា បពិត្រសម្តេចមហារាជ សេចក្តីនេះមានឧបមាដូចម្តេចមិញ ថាឧបមេយ្យដូចសង្ឃរតនៈ ឯសង្ឃរតនៈនោះនឹងថាជាធំជាង

Websites: WatKhemaraRatanaram.org or WatKhmers.org

ឬប្រសើរជាងព្រះតថាគតបរមគ្រូ ព្រោះតែព្រះអង្គទ្រង់ប្រោសប្រទាននូវសំពត់សាដកដល់ព្រះសង្ឃប៉ុណ្ណោះនោះក៏ទេ ម្យ៉ាងទៀតមហាបពិត្រ ឯសម្តេចព្រះបរមសាស្តាចារ្យជាគ្រូ ដែលទ្រង់ត្រាស់ឱ្យព្រះមាតុច្ឆា យកសំពត់សាដកបូជាដល់ព្រះសង្ឃនោះ ព្រះអង្គនឹងមានធ្វើនូវសេចក្តីគោរពកោតខ្លាចអ្វីដល់ព្រះសង្ឃនោះក៏ទេ ព្រោះតែទ្រង់យល់ទៅក្នុងអនាគតកាលខាងមុខ ថាទុកព្រះសង្ឃនេះជាទីគោរពរាប់អានដល់ជនជាខាងក្រោយប៉ុណ្ណោះទេ បពិត្រព្រះរាជសម្ភារ សេចក្តីនេះអាត្មាភាពសូមប្រៀបឧបមាថ្វាយ ថាដូចជាបុរសឯណា ១ បាននាំយកនូវស្វាយសារអាករបូលមកថ្វាយដល់ព្រះបរមក្សត្រាធិរាជ ៗ ក៏ទ្រង់ប្រោសប្រទាន នូវរាជបណ្ណាការទាំងនោះដល់ជនដទៃទៀត គឺទ្រង់ប្រទានឱ្យពួកអ្នកឈ្នួល ឬឱ្យទៅពួកពលសេនាទាហាន ឬឱ្យទៅបុរោហិត បពិត្រមហារាជ អាត្មាភាពសូមថ្វាយព្រះពរសួរព្រះអង្គថា បើមហាក្សត្រស្តេចទ្រង់ប្រោសប្រទានរាជ-បណ្ណាការដល់ជនទាំងពួងមានបុរោហិតជាដើម នោះជនទាំង

នោះមិនជាធំប្រសើរជាងព្រះមហាក្សត្រព្រោះតែទ្រង់ព្រះរាជទាន បណ្ណាការនោះឱ្យឬអ្វី មហាបពិត្រ ។

ព្រះបាទមិលិន្ទ ស្ដេចទ្រង់មានព្រះរាជឱង្ការត្រាស់តបទៅព្រះថេរវិញថា មិនមែនដូច្នោះទេលោកម្ចាស់ បពិត្រលោកម្ចាស់ដ៏ចម្រើន ឯជនទាំងពួងមានបុរោហិតជាដើមនោះមិនបានប្រសើរជាងស្ដេចទេ តែព្រះមហាក្សត្រដែលស្ដេចទ្រង់ប្រោសប្រទាននូវរាជបណ្ណាការនោះ ដើម្បីនឹងឱ្យជនទាំងនោះមានកេរ្តិ៍ឈ្មោះថា ជាអ្នកបានទទួលរង្វាន់អំពីមហាក្សត្រទ្រង់ប្រទានឱ្យប៉ុណ្ណោះទេ ។

ព្រះនាគសេនថេរ ទើបថ្វាយព្រះពរទៅមហាក្សត្រវិញថា បពិត្រមហារាជ សេចក្ដីនេះមានឧបមាដូចម្ដេចមិញ ថាមានឧបមេយ្យដូចសង្ឃរតនៈនោះដែរ ឯសង្ឃរតនៈនេះ មិនមែនជាធំជាងឬប្រសើរជាងព្រះបរមសាស្ដា ព្រោះតែព្រះសាស្ដាស្ដេចទ្រង់ត្រាស់ឱ្យព្រះមាតុច្ឆាបូជាសំពត់សាដកប៉ុណ្ណោះនោះទេ ប្រការ ១ ទៀត ឯព្រះសង្ឃនោះតែងមានព្រះសម្មាសម្ពុទ្ធជាប្រធាន

ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់លើកតម្កើងព្រះសង្ឃនោះទុកក្នុងទីជាទីបូជារបស់ព្រះអង្គ ហើយទើបទ្រង់ត្រាស់បង្គាប់ទៅនាងមហាបជាបតីគោតមី ឱ្យព្រះនាងយកសំពត់សាដកនោះបូជាដល់ព្រះសង្ឃនោះ ។

ន័យ ១ វិញទៀត បពិត្រព្រះរាជសម្ភារ សម្តេចព្រះទសពលញាណស្តេចទ្រង់មានព្រះយោបល់ឃើញយល់ថា សង្ឃ-រតនៈនេះជាវត្ថុគួរដល់ការបូជាដោយពិត បានជាទ្រង់តាំងព្រះហឫទ័យថា តថាគតនឹងបូជាចំពោះនូវសង្ឃរតនៈ ដោយវត្ថុជារបស់ព្រះអង្គ ហើយទើបទ្រង់ត្រាស់ ចំពោះទៅព្រះមាតុច្ឆាឱ្យព្រះនាងយកសំពត់សាដកនោះ ទៅប្រគេនដល់ព្រះសង្ឃក្នុងកាលនោះឯង ។

ម្យ៉ាងទៀត ព្រះរាជសម្ភារ សម្តេចព្រះទសពលញាណព្រះអង្គមិនដែលលើកសរសើរព្រះអង្គឯង ថាជាបុគ្គលគួរដល់ការបូជាទេ ទ្រង់តែងពណ៌នាសរសើរនូវបុគ្គលណា ១ ដែលមានវត្តប្រតិបត្តិល្អគួរជាទីបូជា ទើបព្រះអង្គសរសើរចំពោះបុគ្គលនោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

បពិត្រព្រះរាជសម្ភារ ឯព្រះបរមសាស្ដាបារម្យព្រះអង្គជាវិសុទ្ធិទេ-
វា កន្លងលើសនូវទេវតាទាំងពួង ព្រះអង្គទ្រង់បានត្រាស់សម្ដែង
លើកនូវភិក្ខុដែលមានវត្តប្រតិបត្តិជាអ្នកប្រាជ្ញាតិច ដោយធម្ម
ទាយាទធម្មបរិយាយ ក្នុងគម្ពីរមជ្ឈិមនិកាយថា អសុយេវ បុរិ-
មោ ភិក្ខុ ភិក្ខុឈ្មោះនោះហ្ន៎ ដែលជាភិក្ខុនៅខាងមុខនៃតថាគត
នោះ ជាបុគ្គលគួរដល់បូជាយ៉ាងវិសេស និងគួរជាទីសរសើរ
យ៉ាងក្រៃលែង តែថានឹងប្រសើរជាងព្រះអង្គនោះមិនមានឡើយ
បពិត្រព្រះរាជសម្ភារ បណ្ដាសត្តនិកាយទាំងឡាយ ក្នុងភព
ទាំងអស់នោះ នឹងរកសត្វណានីមួយឱ្យជាសត្វប្រពៃក្រៃលែង
លើសព្រះអនាវរណញ្ញាណនោះគ្មានទេ ឯសម្ដេចព្រះអនាវរណញ្ញាណ
នោះព្រះអង្គជាបុគ្គលប្រសើរខ្ពង់ខ្ពស់ ដោយវិសេសជាងសត្វ
ទាំងអស់ក្នុងត្រៃភព នឹងរកសត្វណាមកប្រៀបផ្ទឹមឱ្យត្រឹមស្មើ
ពុំបានឡើយ បពិត្រសម្ដេចមហារាជ សេចក្ដីនេះត្រូវគ្នានឹង
ពាក្យសរសើរ របស់មាណវិគាមិកទេវបុត្រពោលទុកក្នុងទីបំ
ពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ក្នុងកណ្ដាលនៃពួកមនុស្ស

និងស្ដេចនៃមនុស្សទាំងពួង ក្នុងគម្ពីរសំយុត្តនិកាយជាបទគាថា ថាដូច្នេះ

**វិបុលោ រាជគហីយានំ គិរិ សេដ្ឋោ បវុច្ចតិ**
**សេតោ ហិមវតំ សេដ្ឋោ អាទិច្ចោ អឃគាមិនំ**
**សមុទ្ទោ ឧទីនំ សេដ្ឋោ នក្ខត្តានញ្ច បន្ទិមា**
**សទេវកស្ស លោកស្ស ពុទ្ធោ អគ្គោ បវុច្ចតិ ។**

សេចក្ដីថា ភ្នំវិបុលប្រសើរជាងភ្នំទាំងអស់ក្នុងប្រទេសរាជគ្រឹះ ភ្នំកៃលាសប្រសើរជាងភ្នំទាំងអស់ក្នុងព្រៃហេមពាន្ត ព្រះអាទិត្យថ្លៃថ្លាជាងវត្ថុទាំងអស់ ដែលមាននៅក្នុងអាកាសវេហាស៍ មហាសមុទ្ររុងរឿងជាងស្ទឹងទាំងអស់ក្នុងលោកនេះ ព្រះចន្ទថ្លៃថ្លាវិសេសជាងនក្ខត្តឫក្សទាំងឡាយ ព្រះសព្វញ្ញុពុទ្ធព្រះអង្គមានគុណដ៏ប្រសើរលើសលប់ជាងទេវតានិងមនុស្សទាំងពួងក្នុងលោក បពិត្រសម្ដេចមហារាជ ពាក្យនេះជាពាក្យរបស់មាណវគាមិកទេវបុត្រពោលទុកជាគាថានេះ ឯគាថានេះគឺទេវបុត្រនោះរៀបរៀងក្រងទុកដោយល្អហើយ មិនបានរៀបរៀងដោយ

ខ្ទីឃ្លាទេ ជាគាថាសុភាសិតមិនមែនទុព្ភាសិតទេ ព្រោះព្រះសម្មា-សម្ពុទ្ធ ព្រះអង្គបានអនុមតិតាមថាត្រឹមត្រូវល្អហើយ បពិត្រព្រះរាជសម្ភារ ព្រះធម្មសេនាបតីសារីបុត្តត្ថេរ លោកបានពោលទុកថា បុគ្គល ១ ពួកបានដល់នូវត្រៃសរណគមន៍ បានបង្អោននូវអញ្ជលីកម្ម ដោយសេចក្តីជ្រះថ្លាក្នុងចិត្តថា ដើម្បីនឹងឆ្លងបាកសង្សារទុក្ខដោយការព្យាយាមនោះ ឬមិនដូច្នោះទេ មហាបពិត្រ ។ ម្យ៉ាងទៀតសម្តេចព្រះសព្វញ្ញុតញ្ញាណ ព្រះអង្គជាទេវតាវិសេសជាងទេវតាទាំងអស់ក្នុងត្រៃលោក ទ្រង់បានត្រាស់ប្រកាសសេចក្តីទុកមកថាដូច្នេះ ឯកបុគ្គលោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ នែភិក្ខុទាំងឡាយ មានបុគ្គលម្នាក់កាលដែលកើត ៗ មកក្នុងមនុស្សលោកហើយ ខំប្រព្រឹត្តធ្វើខ្លួនឱ្យជាប្រយោជន៍ដល់ជនច្រើន ឱ្យមានសេចក្តីសុខដល់ជនច្រើន ជាអ្នកអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន និងប្រយោជន៍ និងសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ កតមោ ឯកបុគ្គលោ បុគ្គលម្នាក់នោះតើគឺអ្នកណា តថាគតោ អរហំ

Websites: WatKhemaraRatanaram.org or WatKhmers.org

សម្មាសម្ពុទ្ធោ អយំ ខោ ភិក្ខវេ ឯកបុគ្គលោ ឯបុគ្គលម្នាក់នោះ មិនគឺអ្នកឯណាទេ គឺអង្គព្រះតថាគតដែលមាននាមថា អរហំ សម្មាសម្ពុទ្ធោនេះឯង ព្រះអង្គនេះទ្រង់កើតឡើងក្នុងលោក ដើម្បីសេចក្តីចម្រើន និងប្រយោជន៍ ហើយនិងសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ សេចក្តីឧបអាត្មាភាពរាប់រៀបមកនេះ សូមមហាបពិត្រស្តេចជ្រាប ។

ព្រះបាទមិលិន្ទ្រាធិបតីស្តេចទ្រង់ត្រាស់ទទួលពាក្យព្រះនាគសេនថេរថា សាធុ ភន្តេ នាគសេន បពិត្រព្រះនាគសេនដ៏ចម្រើន សេចក្តីដែលលោកម្ចាស់អធិប្បាយ រាប់រៀបមកនេះក៏ប្រពៃណាស់ហើយ ញោមក៏ចូលចិត្តស៊ប់សួនអស់សង្ស័យហើយ ខ្ញុំព្រមទទួលតាមពាក្យរបស់លោកម្ចាស់ដោយសព្វគ្រប់ប៉ុណ្ណោះឯង ។

ចប់គោតមីវត្ថទានបញ្ហាប៉ុណ្ណោះ

Websites: WatKhemaraRatanaram.org or WatKhmers.org

គោតមីវត្ថុទានបញ្ហានេះ មិនប្រាកដជាមានមកក្នុងវគ្គណា ស្រាប់តែឃើញមានមកនៅត្រង់ទីបញ្ចប់ នៃមិលិន្ទបញ្ហានេះ ហើយប្រាប់សេចក្ដីថាគោតមីវត្ថុទាននេះជាប្រស្នាទី ៣ តែម្ដង ឯត្រង់ប្រស្នាទី ១ ទី ២ និងទី ៤ ទី ៥ តទៅមិនឃើញមាន ។

## ក្នុងមិលិន្ទបញ្ហានេះ បែកបេញជា ៦ ស្ថាន

គឺ:

| | |
|---|---|
| បុព្វយោគ ១ | មិលិន្ទបញ្ហា ១ |
| មេណ្ឌកបញ្ហា ១ | អនុមានបញ្ហា ១ |
| លក្ខណបញ្ហា ១ | ឱបមាកថាបញ្ហា ១ |

ត្រូវជា ៦ ស្ថាន ។

បណ្ដាស្ថានទាំង ៦ នោះ ស្ថានទី ១ គឺបុព្វយោគ ស្ថានទី ២ គឺមិលិន្ទបញ្ហា ។ នោះ បានប្រែរៀបរៀងចប់មកហើយ នៅសល់ ៤ ស្ថានទៀត នឹងមានទៅក្នុងសៀវភៅជាន់ក្រោយ ។៚–

# និគមវចនៈ

សៀវភៅ **មិលិន្ទបញ្ហា** ដែលប្រាកដចំពោះខ្សែបក្ខុរបស់លោកអ្នកអាននេះ ខ្ញុំបាទបានវាយកុំព្យូទ័រជាថ្មី តាមសៀវភៅដើមទាំងស្រុង ដោយមានការកែប្រែខ្លះៗ ដូចតទៅនេះ

១- កែអក្ខរាវិរុទ្ធឱ្យស្របតាមអក្ខរាវិរុទ្ធ ដែលយើងប្រើសព្វថ្ងៃនេះ ដោយយកវចនានុក្រមខ្មែរ សម្តេច **ជួន ណាត** ជាគោល ។

២- ពាក្យដែលអាចសរសេរបាន ២ បែប នឹងឃើញប្រើទាំងពីរយ៉ាង ជាពិសេសពាក្យដែលមកពីភាសាបាលី ហើយត្រូវប្រើយុគលពិន្ទុ និង ពាក្យដែលជាបុរាណភាសា មានរក្សាទុកខ្លះដោយមិនបានកែឡើយ ។

៣- ភាសាបាលីដែលលោកសរសេរបែបបុរាណ គឺសរសេរជាប់គ្នា ដោយគ្មានដកឃ្លាពាក្យនីមួយៗ ឱ្យដាច់ពីគ្នា និង បាលីដែលសរសេរខុស ក៏បានសរសេរឱ្យដាច់ពីគ្នា ព្រមទាំងកែឱ្យត្រឹមត្រូវឡើងវិញ ឧទាហរណ៍ក្នុងខ្សែទី១ ទំព័រ ១២៦ ថា **អថខោអាយស្មានាគសេនោនិវាសេត្វា** (ប្រៀបដូចសរសេរអង់គ្លេសថា AndthevenerableNāgasenarobedhimselfintheforenoon) ដើម្បីឱ្យអ្នកបេះ បាលីបានស្រួលយល់ ទើបកែជា **អថ ខោ អាយស្មា នាគសេនោ និវាសេត្វា** (ប្រៀបដូចកែឱ្យត្រឹមត្រូវវិញថា And the venerable Nāgasena robed himself in the forenoon. Page 48) ដូច្នេះជាដើម ពាក្យបាលីដែលលោកសរសេរដូចបានពោលមកនេះ បានកែគ្រប់កន្លែងទាំងអស់ វៀរលែងតែពាក្យដែលលោកប្រើជាឈ្មោះគម្ពីរ ទោះបីជាគួរតែសរសេរដាច់ពីគ្នា ក៏មិន

Websites: WatKhemaraRatanaram.org or WatKhmers.org

បានកែឡើយ ព្រោះលោកប្រើដូច្នោះឯង ជាពិសេសភាគច្រើននៅក្នុងគម្ពីរព្រះអភិធម្ម គួយ៉ាងក្នុងខ្សែទី ២ ទំព័រ ១០៧ ថា **អភិជានតោសតិ** ដូច្នេះជាដើម ។

៤- ពាក្យថា **ភត្តិក** ក្នុងខ្សែទី ១ ទំព័រ ១៨៦ និងខ្សែទី ២ ទំព័រ ១២២ ខ្ញុំបាទយល់ថា ពាក្យនេះគឺ **ភតិក** ទើបត្រូវ (ព្រោះពាក្យថា **ភត្តិក** ប្រែថា អ្នកធ្វើម្ហូប, ឯពាក្យថា **ភតិក** ប្រែអ្នកឈ្នួល ឬអ្នកស៊ីឈ្នួល) ។ ព្រោះហេតុថា ពាក្យទាំង ២ នេះស្រដៀងគ្នា ដូច្នេះហើយបានជាក្នុងខ្សែទី ១ ប្រែខុសសេចក្ដី គឺលោកប្រែថា អ្នកធ្វើម្ហូប, ឯខ្សែទី ២ លោកប្រែថា អ្នកឈ្នួល ។ ក្នុងសៀវភៅមិលិន្ទបញ្ហាភាសាអង់គ្លេសភាគទី ១ ទំព័រ ៧០ ក៏ប្រែថា អ្នកស៊ីឈ្នួលដែរ (The Questions of King Milinda, translated from Pāli by T. W. Rhys Davids, first published by the Oxford University Press, 1890)

៥- កែបដិសម្ភិទា ៤ ដោយដាក់ អត្ថបដិសម្ភិទា មុនធម្មបដិសម្ភិទា ។

គម្ពីរមិលិន្ទបញ្ហានេះ មិនទាន់ចប់សព្វគ្រប់នៅឡើយទេ ដូច្នេះប្រសិនបើសប្បុរសជនណា មានភាគបន្តពីខ្សែទី ១ និងទី ២ នេះ និងមានកុសលចេតនា ចង់បំពេញនូវធម្មទាន សូមមេត្តាទាក់ទងនឹងវត្ត **ខេមររតនារាម** តាម E-mail: wat47@watkhmers.org

ខ្ញុំបាទសូមបង្អោនកាយ ទទួលនូវរាល់កំហុសខុសឆ្គង ដែលកើតដោយអចេតនា ក្នុងការវាយអក្សរកុំព្យូទ័រនេះ អំពីសំណាក់លោកអ្នក

អានគ្រប់មជ្ឈដ្ឋាន ហើយសង្ឃឹមថា លោកអ្នកអានមុខជានឹងបានក្រេប នូវធម្មរសក្នុងគម្ពីរមិលិន្ទបញ្ហានេះ ជាក់ជាមិនខានឡើយ ៕

វត្តខេមររតនារាម ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៩

ពីខ្ញុំ **ធម្មណាត ផនប្រសិទ្ធិ៍**

Websites: WatKhemaraRatanaram.org or WatKhmers.org